ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 06-Dec-2012, 15:43
CMS/CFO: Uch Arun

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២**

**ម៉ោង ០៩: ០៥នាទី**

**សវនាការលើកទី១៣៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ *(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម យូរ ឧត្តរា

ចៅក្រម ក្លូឌា ហ្វេនស៍ *(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោកស្រី សែ កុលវុឌ្ឍី

លោក ម៉ាតេអូ គ្រីប៉ា*(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ាត់

កញ្ញា សុង ឆវ័ន្ត

លោក ថារីក អាប់ឌុលឡាក់ *(Mr. Tarik ABDULHAK)*

លោក ឃីត រេយ៍ន័រ *(Mr. RAYNOR Keith)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក អេនឌ្រូ អ៊ីនូហ្ស៊ី *(Mr. Andrew INAUZZI)*

លោក ហ្សាស្ពើ ប៉ៅ*(Mr. Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ
*(Mis. Anta GUISSE)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស
*(Mr. Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក ហុង គីមសួន

លោក វ៉េន ពៅ

លោកស្រី ជេត វណ្ណលី

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ម៉ាទីន ហ្សាកកាំង
*(Ms. Martine JAQUIN)*

លោកស្រី អ៊ីស្សាបែល ឌៀរ៉ង់
*(Ms. Isabelle DURAND)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ
*(Ms. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោកស្រី ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ជេត វណ្ណលី | ខ្មែរ |
| លោកស្រី ទី ស្រ៊ីនណា | ខ្មែរ |
| លោក សុន អរុណ | ខ្មែរ |
| លោក អេនឌ្រូ អ៊ីនូហ្ស៊ី | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី ពេជ ស្រីផល (TCCP-108) | ខ្មែរ |
| លោក គឹម វ៉ាន់ឌី (TCCP-59) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី ពេជ ស្រីផល** (TCCP-108)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................................................................ទំព័រ ៦

សួរដោយលោកស្រី ជេត វណ្ណលី ផ្តើមពី..............................................................ទំព័រ ៨

សួរដោយលោក ឃីត រេយ៍ន័រ ផ្តើមពី.................................................................ទំព័រ ៤៧

សួរដោយលោក សុន អរុណ ផ្តើមពី ...................................................................ទំព័រ ៥៧

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោក គីម វ៉ាន់ឌី** (TCCP-59)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................................................................ទំព័រ ៦៦

សួរដោយលោកស្រី ទី ស្រ៊ីនណា ផ្តើមពី ............................................................ទំព័រ ៦៨

# កិច្ចដំណើរការនីតិវិធី

[០៩:០៤:៤៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តាមកាលវិភាគបានគ្រោងទុកនៅក្នុងថ្ងៃនេះ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-108។

លោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី បុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ ដោយមូលហេតុសុខភាព។ ដើមបណ្តឹងរដ្ឋប្បវេណីដែលអង្គជំនុំជម្រះកោះហៅមកស្តាប់សក្ខីកម្មថ្ងៃនេះ គឺដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-108។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។

ក្នុងសវនាការថ្ងៃនេះមានដើមបណ្តឹងរដ្ឋប្បវេណីបម្រុងមួយរូប គឺដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-59។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី TCCP-108 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ!

កុំអាលទាន់ ៗនាំមក មន្ត្រីរដ្ឋបាលតុលាការផ្អាកសិន!

សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្តីលោក លោកស្រីចៅក្រម អស់លោក លោកស្រីនៅក្នុងបន្ទប់សវនាការ និងជុំវិញបន្ទប់សវនាការ។ ខ្ញុំមានបីចំណុចខ្លី។

ទី១) ស្របទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងកាលពីម្សិលមិញ យើងមាន

មន្ត្រីគ្រប់គ្រងសំណុំរឿងលោក មូស្សេន្ទី គាត់នៅខាងក្រោមជាមួយនឹងលោក អៀង សារី ហើយគាត់ជាអ្នកកត់ត្រាសម្គាល់ទៅលើស្ថានភាពរបស់លោក អៀង សារី បន្ទាប់មកយកកំណត់ហេតុនេះមកឲ្យយើងខ្ញុំបានជ្រាប។ ការធ្វើដូច្នេះគឺដើម្បីឲ្យយើងអាចតាមដានស្ថានភាពរបស់លោកអៀង សារីបាន។

[០៩:០៧:៥២]

ចំណុចទី២ ខ្ញុំបានជួបជាមួយនឹងលោក អៀង សារី នៅក្នុងថ្ងៃនេះ តាមអ្វីដែលខ្ញុំយល់ ហើយក្នុងនាមខ្ញុំជាអ្នកមិនមែនផ្នែកវេជ្ជសាស្ត្រនោះ គឺគាត់មិនអាចតាមដាន ចូលរួមក្នុងសវនាការនេះទេ។ ហើយខ្ញុំបាននិយាយជាមួយនឹងវេជ្ជបណ្ឌិត ហើយវាពិបាកណាស់ ដែលមិនអាចកំណត់ថា តើគាត់អាចឬមិនអាចចូលរួមក្នុងសវនាការបានឬក៏អត់នោះទេ។ ខ្ញុំឃើញរបាយការណ៍ពេទ្យៗគឺបានបង្ហាញ ហើយគឺតម្រូវឲ្យគាត់អង្គុយនៅខាងក្រោម ដើម្បីអាចចូលរួមសវនាការដោយមានភាពងាយស្រួល។

ចំណុចទី៣ យើងបានដឹងថា អង្គជំនុំជម្រះបានទាក់ទងទៅនឹងក្រុមជាមួយនឹង ឌី.អេស.អេស អំពីការជំនួសមេធាវីការពារក្ដី។ ខ្ញុំសូមបញ្ជាក់ថា អន្តរជាតិ -- សហមេធាវីអន្តរជាតិៗ នៅពេលដែលខ្ញុំក្រោកឡើងនិយាយនេះ មិនមែននិយាយក្នុងនាមខ្ញុំផ្ទាល់នោះទេ គឺខ្ញុំឡើងនិយាយក្នុងនាមលោក អាង ឧត្តម និងក្នុងនាមក្រុមមេធាវីការពារក្ដី អៀង សារី ទាំងមូល។

អ្វីដែលខ្ញុំលើកឡើងកាលពីម្សិលមិញ មិនមែនក្នុងនាមខ្ញុំផ្ទាល់ទេ គឺក្នុងនាមរួម។ ដូច្នេះ ហើយប្រសិនបើអង្គជំនុំជម្រះចង់ឲ្យជំនួសមេធាវីក្រុមខ្ញុំនោះ គឺថាមិនមែនតែសូមឲ្យជ្រើសរើសជំនួសខ្ញុំមួយរូបនោះទេ គឺរួមទាំងខាងជាតិផងដែរ។ នេះជាការងារដែលយើងធ្វើរួមគ្នានៅក្នុងនេះ។

ដូច្នេះហើយ អង្គជំនុំជម្រះនោះគួរតែជម្រាបទៅ ឌី.អេស.អេស នេះមិនបាច់ខ្វាចទេថា ឲ្យរកការជ្រើសរើសមេធាវីជំនួសនោះ ទាំងអន្តរជាតិ និងជាតិផង ពីព្រោះយើងធ្វើការរួមគ្នានៅទីនេះ។

[០៩:០៩:៥០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១៤:១១]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីឆ្លើយបំភ្លឺតបទៅនឹងការលើកឡើងរបស់លោកមេធាវី ម៉ៃខល កាណាវាស។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ លោក កាណាវាស ការសង្កេតពីរ ឬបីពីអង្គជំនុំជម្រះសាលាដំបូង ឆ្លើយតបទៅនឹងការធ្វើសេចក្ដីសន្និដ្ឋានរបស់លោកប៉ុន្មាននាទីខាងមុខ -- អម្បាញ់មិញនេះ។ ទី១ គឺពាក់ព័ន្ធទៅនឹងការសង្កេតរបស់លោក ដែលថា បញ្ជូនបគ្គលិកឲ្យទៅតាមដានស្ថានភាពរបស់លោក អៀង សារី។ ថាតើលោក អៀង សារី នោះអាចចូលរួមឬមិនចូលរួមក្នុងសវនាការដែរឬទេ? លោក កាណាវាស ខ្ញុំដឹងថា លោកជាមេធាវីជើងចាស់មួយរូប ដូច្នេះ សូមឲ្យលោកក្រោកឈរឡើង!

ខ្ញុំដឹងថាលោកកំពុងតែស្ដាប់ ក៏ប៉ុន្តែគឺខ្ញុំសូមឲ្យលោកក្រោកឈរឡើង។ សូមអរគុណ។

សេចក្ដីសង្កេតទី១៖ គឺបានគូសបញ្ជាក់កាលពីម្សិលមិញថា តុលាការបានធ្វើសេចក្ដីសម្រេចពាក់ព័ន្ធទៅនឹងលទ្ធភាពរបស់លោក អៀង សារី ក្នុងការចូលរួម ហើយគឺយើងនឹងផ្ដោតសំខាន់ទៅលើរបាយការណ៍ពេទ្យ។ ចំណុចទី២ ដែលលោកបានលោកបានលើកឡើង ជាដំបូងគឺខ្ញុំសូមឆ្លើយតបខ្ញុំសូមគូសបញ្ជាក់ថា ពាក្យសុំដែលបានធ្វើឡើងដោយលោកនោះ គឺមិនមានចេតនាបំណងពីលោកនោះទេ។ ដូច្នេះគ្រាន់តែខ្ញុំបញ្ជាក់ឲ្យបានច្បាស់លាស់ ហើយខ្ញុំសន្និដ្ឋានពីការផ្ដល់យោបល់របស់លោកតែប៉ុណ្ណោះ។

[០៩:១៥:៥២]

មន្ត្រីច្បាប់ក្នុងនាមសាលាដំបូងតាមការបញ្ជាក់របស់លោក គឺថា គឺបើចេញសេចក្ដីសម្រេចនេះ គឺលោកមិនពេញចិត្ត ហើយលោកនឹងធ្វើការលាលែងពីតំណែង។ ដូច្នេះហើយ គឺយើងខ្ញុំគ្រាន់តែសួរនៅក្នុងបញ្ជីមេធាវីត្រៀមក្នុងករណីដែលលោកលាលែងពីការងារនេះតែប៉ុណ្ណោះ ហើយខ្ញុំមិនត្រូវការចង់ឲ្យលោកមានការពន្យល់អ្វីបន្ថែមនោះទេ។ អង្គជំនុំជម្រះសាលាដំបូងមិនមានបំណងចង់ឲ្យមានការផ្លាស់ប្ដូរលោក ឬក៏បញ្ជាក់សុំឲ្យមានការផ្លាស់ប្ដូរលោកដោយតាមទំនើងចិត្តនោះទេ។ ហើយខ្ញុំគិតថាវាច្បាស់លាស់ចំពោះលោកហើយ គឺខ្ញុំគ្រាន់តែសួរបញ្ជាក់ទៅលើបញ្ជីត្រៀមតែប៉ុណ្ណោះក្នុងករណីលោកលាលែង។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកស្រីចៅក្រម។ ខ្ញុំមិននិយាយថា ខ្ញុំលាលែងពីតំណែងនោះទេ។ ខ្ញុំថា ខ្ញុំនឹងដើរចេញពីបន្ទប់សវនាការនេះក្នុងករណីមានការចេញសេចក្ដីសម្រេចណាមួយលើករណីនេះ។ យើងខ្ញុំត្រៀមខ្លួនក្នុងការដើរចេញពីការចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីនេះ ដើម្បីជាប្រយោជន៍ទៅដល់កូនក្ដីរបស់ខ្ញុំ។ ខ្ញុំនឹង -- ខ្ញុំមិនមានបំណងណាមួយធ្វើការលាលែងពីការងារការពារក្ដីកូនក្ដីរបស់ខ្ញុំនោះទេ។ ខ្ញុំធ្វើយ៉ាងណា ធានាឲ្យកូនក្ដីរបស់ខ្ញុំទទួលការជំនុំជម្រះដោយយុត្តិធម៌។ ខ្ញុំត្រៀមខ្លួននឹងដើរចេញក្នុងករណី

នេះ។ ហើយនៅខាងក្រោមនោះ គឺគាត់មិនមែនតែធ្វើការវាយតម្លៃទៅលើស្ថានភាពរបស់លោក អៀង សារី នោះទេ គឺគ្រាន់តែគាត់ចូលរួមសង្កេតទៅលើស្ថានភាពរបស់លោក អៀង សារី តែប៉ុណ្ណោះ។ គឺដើម្បីឲ្យគាត់នោះ ថាតើគាត់អាចផ្តល់អារម្មណ៍ចូលរួមក្នុងនីតិវិធីនេះដែរឬទេ?

សូមអធ្យាស្រ័យដែលខ្ញុំមិនបានក្រោកឈរឡើងអម្បាញ់មិញ នៅពេលដែលលោកស្រីចៅក្រមធ្វើការឆ្លើយតបទៅនឹងយោបល់របស់ខ្ញុំ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[០៩:១៨:០៣]

**លោក ឃីត រេយ៍ន័រ៖**

អរុណសួស្តីលោក លោកស្រីចៅក្រមជាទីគោរពភាគីទាំងអស់។ ខ្ញុំសូមលើកមួយចំណុចដែលវាពាក់ព័ន្ធទៅនឹងបញ្ហាឯកសារដែលតុលាការបានទទួល គឺទទួលនេះផ្អែកទៅលើករណីមួយថ្ងៃៗ ជាពិសេសគឺរបាយការណ៍មកពីមន្ទីររង់ចាំខាងក្រោម។ លោក អៀង សារី លោកក្រុមមេធាវី កាណាវាស នោះបានលើកឡើងថា គឺមូលដ្ឋានដូចដែលយើងបានដឹងហើយ យើងត្រូវការរបាយការណ៍ពេទ្យហើយយើងត្រូវមានព័ត៌មាននៅក្នុងនុ៎ង។ ជាពិសេសរបាយការណ៍នោះ គឺត្រូវតែបញ្ជាក់ថា តើលោក អៀង សារី នេះអាចចូលរួមក្នុងនីតិវិធីនេះដែរឬទេ? មិនមែនថាគាត់អាចមានភាពងាយស្រួលអង្គុយនៅខាងក្រោមនោះឡើយ។

ដូច្នេះ ខ្ញុំសូមឲ្យតុលាការធ្វើយ៉ាងណាឲ្យរបាយការណ៍ដែលពេទ្យ ដែលបញ្ជូនមកអង្គជំនុំជម្រះនៅចំពោះមុខជារៀងរាល់ព្រឹកនេះ ត្រូវតែមានព័ត៌មានលម្អិតអំពីលទ្ធភាពចូលរួមជារៀងរាល់ថ្ងៃរបស់លោក អៀង សារី។ ដូច្នេះ ព័ត៌មានទាំងអស់នោះត្រូវតែមានលក្ខណៈលម្អិតជូនអង្គជំនុំជម្រះ ដើម្បីឲ្យអង្គជំនុំជម្រះនេះមានមូលដ្ឋានរឹងមាំ និងសុពលភាពក្នុងការចូលរួមរបស់លោក អៀង សារី ដើម្បីឲ្យនីតិវិធីរបស់យើងអាចចាប់ផ្តើមបាន។

[០៩:១៩:៣៣]

នៅពេលនេះគឺ២៥នាទីរួចមកហើយ ២៥នាទី -- ម៉ោងប្រាំបួនម្ភៃប្រាំនាទី ដែលវាចំណាយពេលវេលារបស់តុលាការយើង។ ដូច្នេះហើយ ខ្ញុំស្នើសុំអង្គជំនុំជម្រះថា ធ្វើយ៉ាងណាឲ្យរបាយការណ៍ពេទ្យដែលបញ្ជូនជារៀងរាល់ព្រឹកនោះរៀបរាប់ព័ត៌មានលម្អិតអំពីលទ្ធភាពចូលរួមរបស់លោក អៀង សារី

នៅក្នុងនីតិវិធីរបស់យើង។ សូមអរគុណ។

[០៩:២០:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី អាង ឧត្តម!

**លោក អាង ឧត្តម៖**

សូមក្រាបថ្វាយបង្គំព្រះតេជគុណ ព្រះសង្ឃដែលគង់មានវត្តមាននៅទីនេះ។ សូមគោរពលោកប្រធាន អស់លោក លោកស្រីចៅក្រម។ សួស្តីតំណាងអយ្យការ សហភាគីទាំងអស់ លោក អ្នកទាំងឡាយផងដែលចូលរួមសវនាការនេះ។

ខ្ញុំគាំទ្រលើសំណើរបស់សហព្រះរាជអាជ្ញា ដែលសុំឱ្យមានការពិនិត្យលើលទ្ធភាពចូលរួមសវ-នាការរបស់លោក អៀង សារី។ ខ្ញុំក៏ស្នើសុំផងដែរ ថាពីព្រោះលោក អៀង សារី មានបញ្ហា បើបែងចែកទៅវាមានបី៖ ជំងឺមនុស្សចាស់ គឺអ្នកឯកទេស គឺលោក ចន ខាំប៊ែល លោកឯកទេសខាងជំងឺមនុស្សចាស់។ ប៉ុន្តែយើងកុំភ្លេចនៅពីរប្រភេទ គឺជំងឺផ្លូវកាយ និងជំងឺផ្លូវចិត្ត។ របាយការណ៍ដែលលោកគ្រូពេទ្យ លឹម ស៊ីវុតថា ចេញព្រឹកនេះ គឺនិយាយ គ្រាន់តែថា "លោក អៀង សារី ហេវហត់ អស់កម្លាំងមិនអាចអង្គុយ"។ ខ្ញុំដឹងថា ពាក្យ "មិនអាចអង្គុយ" វាទាក់ទងនឹងជំងឺមនុស្សចាស់ ឬជំងឺផ្លូវកាយទេ។ ហើយអត់មាននិយាយថា "លោក អៀង សារី អាចតាមដានសវនាការ បានដោយប្រភេទណា" ពីព្រោះគាត់មានបញ្ហាសតិស្មារតី ហើយក៏ដូចជំងឺដែរ។

[០៩:២១:៣១]

អ៊ីចឹង បើយើងមានរបាយការណ៍ពេញលេញបែបនេះ ជាការល្អហើយ។ ឱ្យចេញរបាយការណ៍ថា ជំងឺមនុស្សចាស់ប្រភេទណាខ្លះ ចេញមក រៀងរាល់ព្រឹកមក ហើយចែកទាំងអស់គ្រប់ភាគីទៅ ខ្ញុំមិនយល់ទាស់ទេ។ ហើយជំងឺផ្លូវកាយរបស់គាត់ជាប្រចាំហ្នឹង ប្រភេទយ៉ាងម៉េច? ហើយនិងជំងឺសតិស្មារតីហ្នឹង យើងផ្តោតសំខាន់ជាងគេបំផុតទៅលើសតិស្មារតីរបស់គាត់អាចតាមដានសវនាការយ៉ាងពេញលេញ ឬអត់?

ចំណុចនេះ ដែលយើងត្រូវការឱ្យមានការបញ្ជាក់។ ពីព្រោះកន្លងមក បញ្ជាក់តែរឿងជំងឺផ្លូវកាយ ឬជំងឺមនុស្សចាស់តែប៉ុណ្ណឹង ហើយជំងឺសតិស្មារតីរបស់លោក អៀង សារី ដែលថា អាចតាមដានបាន ឬអត់។ អត់មានការបញ្ជាក់។ អ៊ីចឹង បើយើងមានការបញ្ជាក់ដោយគ្រូពេទ្យឯកទេសជំនាញប្រចាំថ្ងៃ

បែបនេះ ជាការប្រសើរ។ សូមអរគុណលោកប្រធាន។

[០៩:២២:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២៣:០៩]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណី 108 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[០៩:២៤:៣៣]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកស្រី ដើមបណ្ដឹងរដ្ឋប្បវេណី។ តើលោកស្រីឈ្មោះអី?

**លោកស្រី ពេជ ស្រីផល៖**

**ឆ៖** ចាស សូមគោរពលោកប្រធាន នាងខ្ញុំឈ្មោះ ពេជ ស្រីផល។

**ស៖** បាទ អរគុណ។ លោកស្រី ពេជ ស្រីផល តើលោកស្រីកើតនៅថ្ងៃខែឆ្នាំណា? លោកស្រីអាចប្រាប់ដល់អង្គសវនាការបានដែរទេ?

**ឆ៖** ចាស នាងខ្ញុំកើតនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៥២។

**ស៖** បាទ អរគុណ។ ហើយទីកន្លែងកំណើតរបស់លោកស្រីនៅទីកន្លែងណា?

**ឆ៖** នាងខ្ញុំកើតនៅភូមិស្វាយប៉ោ ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង។

**ស៖** បាទ អរគុណ។ ហើយចុះទីលំនៅសព្វថ្ងៃតើលោកស្រីរស់នៅទីកន្លែងណា?

**ឆ៖** ទីលំនៅសព្វថ្ងៃនាងខ្ញុំរស់នៅភូមិក្រោលក្របី ឃុំត្រពាំងជង ស្រុកបាកាន ខេត្តពោធិ៍សាត់។

**ស៖** បាទ អរគុណ។ ហើយសព្វថ្ងៃនេះលោកស្រីប្រកបមុខរបររកស៊ីធ្វើអ្វី ?

**ឆ៖** ចាស សព្វថ្ងៃនេះនាងខ្ញុំធ្វើការនៅជាជំទប់ទី១ ក្រុមប្រឹក្សាឃុំត្រពាំងជង ស្រុកបាកាន ខេត្តពោធិ៍សាត់។

**ស៖** ឪពុកបង្កើតរបស់លោកស្រីឈ្មោះអី?

**ឆ៖** ឪពុកបង្កើតរបស់នាងខ្ញុំឈ្មោះ ពេជ និល។

**ស៖** ចុះម្ដាយបង្កើតរបស់លោកស្រី?

**ឆ៖** ម្ដាយបង្កើតរបស់នាងខ្ញុំឈ្មោះ កែ គឹមអ៊ី។

**ស៖** បាទ អរគុណ។ ហើយចុះប្ដីរបស់លោកស្រីគាត់ឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** យើងបានបែកគ្នាហើយ។ ហើយនាងមានកូនពីរនាក់ ប៉ុន្តែបច្ចុប្បន្ននេះនៅសល់ម្នាក់ទេ ម្នាក់ទៀតបានស្លាប់បាត់ទៅហើយ។

**ស៖** បាទ អរគុណ។

**ប្រធានអង្គជំនុំ៖**

លោកស្រី ពេជ ស្រីផល ក្នុងនាមលោកស្រីជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីនេះ នៅក្នុងកិច្ចដំណើរការនៃការស្ដាប់សក្ខីកម្មរបស់លោកស្រីនៅចុងបញ្ចប់គឺលោកស្រីអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការអំពីស្ថានភាពទុក្ខវេទនា ស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោកស្រី ដែលមានជាអាទិ៍ គឺការខូចខាតខាងផ្លូវកាយ ខាងផ្លូវចិត្ត ឬក៏សម្ភារៈដែលជាព្យសនកម្មផ្ទាល់ខ្លួនដែលជាបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋ ដែលកើតមានយ៉ាងពិតប្រាកដរហូតមកដល់ពេលបច្ចុប្បន្ន ដែលនាំឲ្យលោកស្រីសម្រេចតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋទាំងឡាយដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទ ដែលប៉ះពាល់ដល់លោកស្រីនៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ។ នេះជាសិទ្ធិរបស់លោកស្រី អង្គជំនុំជម្រះជម្រាបជូនលោកស្រីឲ្យបានជ្រាបដើម្បីលោកស្រីបានត្រៀមជាមុននៅក្នុងការថ្លែងរៀបរាប់នេះនៅពេលចុងក្រោយនៃការស្ដាប់សក្ខីកម្មរបស់លោកស្រី។

[០៩:២៧:២០]

អង្គជំនុំជម្រះសូមជម្រាបជូនសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីថា អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះមុនភាគីដទៃទៀតនៃរឿងក្ដី។ ហើយក៏សូមជម្រាបដែរថា ភាគីដើម -- សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងតំណាងសហព្រះរាជអាជ្ញាគឺមានពេលកន្លះថ្ងៃក្នុងការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ ចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ លោកស្រីមេធាវី ជេត វណ្ណលី ដែលជាមេធាវីផ្ទាល់របស់លោកស្រីនឹងសួរក្នុងនាមមេធាវីនាំមុខ។ សូមអរគុណលោកប្រធាន។

[០៩:២៩:០៦]

**ប្រធានអង្គជំនុំ៖**

សូមៗអញ្ជើញបាទ!

**លោកស្រី ជេត វណ្ណលី៖**

សូមអរគុណលោកប្រធាន។ ជាដំបូង ខ្ញុំសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមដែលមានវត្តមាននៅទីនេះ និងអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** សូមជម្រាបសួរលោកស្រី ពេជ ស្រីផល, ខ្ញុំ ជេត វណ្ណលី មេធាវីដើមបណ្តឹងរដ្ឋប្បវេណីសូមសួរលោកស្រីនូវសំណួរមួយចំនួន។ សំណួររបស់ខ្ញុំផ្អែកជាសំខាន់ទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខការិយាល័យចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៩ ដែលមានលេខឯកសារ D296/10។

[០៩:២៩:៥៧]

**លោកស្រី ជេត វណ្ណលី៖**

នាងខ្ញុំសូមអនុញ្ញាតលោកប្រធាន ដើម្បីផ្តល់ឯកសារនេះជូនលោកស្រីដើមបណ្តឹងរដ្ឋប្បវេណីក៏ដូចជាសូមអនុញ្ញាតក្នុងការបង្ហាញនូវផ្នែកមួយចំនួន ដែលនាងខ្ញុំនឹងយោងនៅក្នុងសំណួររបស់នាងខ្ញុំ។ សូមអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវីយកជូនដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ជេត វណ្ណលី៖**

សូមអរគុណលោកប្រធាន។

នៅក្នុងសំណួរនាងខ្ញុំមានគោលធំៗបីចំណុច។ គឺទី១) មុនថ្ងៃ១៧ មេសា ៧៥។ ទី២) ជម្លៀសដំណាក់កាលទី១ ហើយទី៣ ជម្លៀសដំណាក់កាលទី៣ -- អ៊ូ! ទី២។

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** លោកស្រី ពេជ ស្រីផល មុនឆ្នាំ៧៥ តើលោកស្រីនៅទីកន្លែងណា?

[០៩:៣១:០១]

**លោកស្រី ពេជ ស្រីផល៖**

**ឆ៖** ចាស អរគុណលោកស្រីមេធាវី។ មុនឆ្នាំ១៩៧៥ នាងខ្ញុំរស់នៅម្តុំទួលគោក។

**ស៖** នៅភូមិអី? សង្កាត់អី? ទួលគោក?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

អត់ទាន់ -- ក្បាលមីក្រូអត់ទាន់ប្រតិបត្តិការទេ។ ចាំមើលក្បាលមីក្រូប្រតិបត្តិការសិនណ៎ះ បាននិយាយទៅ បានចូលប្រព័ន្ធសំឡេង ដែលអាចស្តាប់នៅទីនេះ និងបកប្រែភាសាទៅជាភាសាផ្សេងៗ។

**លោកស្រី ពេជ ស្រីផល៖**

**ឆ៖** ចាស អរគុណ។ ក្នុងឆ្នាំ១៩៧៥ ហ្នឹង នាងខ្ញុំរស់នៅម្តុំទួលគោក ក៏ប៉ុន្តែនាងខ្ញុំអត់ដឹងថាភូមិអី សង្កាត់អីទេ ព្រោះផ្ទះនាងខ្ញុំហ្នឹងនៅជិតម្តុំផ្ទះសូស្តែន។

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** ចុះប្តីលោកស្រីធ្វើអីដែរ?

**ឆ៖** ប្តីរបស់នាងខ្ញុំគាត់ធ្វើជាពេទ្យទាហានរបស់ លន់ នល់។

[០៩:៣២:០៥]

**ប្រធានអង្គជំនុំ៖**

អត់ទាន់ -- ក្បាលមីក្រូអត់ទាន់ប្រតិបត្តិការទេ។ បង្អង់បន្តិច សូមឆ្លើយណ៎ះ។ ការបង្អង់បន្តិចហ្នឹង គឺផ្តល់ពេលវេលាសមស្របសម្រាប់បកប្រែភាសា ហើយនិងក្បាលមីក្រូប្រតិបត្តិការ ដោយសញ្ញាភ្លើងក្រហម។

**លោកស្រី ពេជ សុផល៖**

**ឆ៖** ចាស ប្ដីរបស់នាងខ្ញុំគាត់ធ្វើជាពេទ្យទាហាន លន់ នល់ នៅកន្លែងដែលគាត់ធ្វើការហ្នឹងនៅជិតពេទ្យកាល់ម៉ែត។

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** មុនឆ្នាំ៧៥ តើលោកស្រីមានដូរទៅទីកន្លែងណាទៀតទេ?

**ឆ៖** មុនឆ្នាំ១៩៧៥ ហ្នឹង ក្រុមគ្រួសាររបស់នាងខ្ញុំបានដូរទីលំនៅពីទួលគោក មកនៅម្ដុំឃ្លាំងរំសេវ ដែលជាផ្ទះរបស់អ៊ំស្រីបង្កើត។ ព្រោះពេលនោះកុំអីក៏ក្រុមគ្រួសារខ្ញុំអត់ដូរដែរ ដោយសារសកម្មភាពនៅទីក្រុងភ្នំពេញហ្នឹងហាក់ដូចជាមើលទៅមានសភាពវឹកវរពេក។ ដូច្នេះ ដើម្បីកុំឲ្យក្រុមគ្រួសារបែកគ្នា ពួកយើងខ្ញុំក៏បានសម្រេចចិត្តថា មករស់នៅជុំគ្នានឹងផ្ទះអ៊ំបង្កើត នៅភូមិ -- នៅម្ដុំឃ្លាំងរំសេវជិតផ្សារដើមគនេះចាស។

[០៩:៣៣:៣៥]

**ស៖** តើមុនឆ្នាំ៧៥ ពេលដែលលោកស្រីរស់នៅផ្សារដើមគរ លោកស្រីបានឃើញសភាព-ការណ៍យ៉ាងម៉េចដែរនៅទីក្រុងភ្នំពេញ?

**ឆ៖** នៅទីក្រុងភ្នំពេញ មុនឆ្នាំ១៩៧៥ ដែលនាងខ្ញុំបាននាំក្រុមគ្រួសារមករស់នៅម្ដុំផ្សារដើមគ និងហៅថាផ្សារឃ្លាំងរំសេវនោះ គឺថានៅទីក្រុងភ្នំពេញហ្នឹងមានសភាពការណ៍វឹកវរណាស់ ដោយសារពេលនោះឃើញមនុស្សប្លែកមុខជាច្រើន ជម្លៀសមកតាម ពីតាមបណ្ដាខេត្តហ្នឹង មកនៅក្នុងទីក្រុង។ ការកើនឡើងរបស់ប្រជាជនមានច្រើន។ ហើយចំណុចសំខាន់មួយទៀត សេដ្ឋកិច្ចដូចថា អង្ករត្រីសាច់អីថ្នាំពេទ្យអីហ្នឹងឡើងថ្លៃទាំងអស់។ ដូច្នេះការ ភាពច្របូកច្របល់ហ្នឹង គឺមាននៅក្នុងទីក្រុង។ ហើយចំណុចមួយទៀត យើងឮសូរមានការផ្ដោងគ្រាប់ចូលទីក្រុង។ ចាស ដូចជានៅម្ដុំផ្សារដេប៉ូ នៅម្ដុំអូរបែកក្អម នៅម្ដុំជិតផ្ទះលោកសូស្ដែនហ្នឹង ហើយនៅខាងម្ដុំប៊ូខឹងហ្នឹង គឺមានគ្រាប់ផ្ដោងធ្លាក់ចុះ។ ចាស ហើយក្នុងពេលនោះដែរ ពេលដែលនាងខ្ញុំធ្វើចរាចរនៅតាមផ្លូវហ្នឹង នៅពេលដែលគ្រាប់ផ្ដោងចុះហ្នឹង យើងឃើញមានប្រជាជនស្លាប់ច្រើន។

[០៩:៣៥:០២]

ចាស អ្នកជាក់ស៊ីក្លូត្រូវដាច់ក្បាលធ្លាក់មកដី ហើយមានរបួសជាច្រើននៅកន្លែងដែលគ្រាប់ធ្លាក់នោះ។ ដូច្នេះ ដោយសារឪពុកនាងខ្ញុំគាត់ធ្វើជាគិញរបស់ទាហាន លន់ នល់ ចាស គាត់ជាអ្នក -- ចង់

និយាយថា ជា សេ.អ៊ី.អា ចុះ! គាត់ជាអ្នកដើរយកព័ត៌មាន អ៊ីចឹងព័ត៌មានភាគច្រើននៅពេលដែលគាត់ទៅផ្ទះវិញ គាត់ចេះតែប្រាប់ហើយថា កូនចៅប្រយ័ត្នណ៎ា ស្រុកទេសយើងអត់ស្រួលទេ។ កុំឱ្យដើរហេតរហូតពេកប្រយ័ត្នត្រូវគ្រាប់ផ្លោង គ្រាប់បែកអីទម្លាក់មកអ៊ីចឹងងាប់កូនងាប់ចៅអស់។ ដូច្នេះក្នុងពេលនោះ ប្អូនៗខ្ញុំដែលត្រូវទៅសាលារៀនត្រូវបានផ្អាក។ ចាស អត់ហ៊ានឱ្យទៅរៀនទេខ្លាចបែកគ្នា។ ហើយក្នុងពេលនោះដែរ យើងឃើញថាមានដូចថា ភាពវឹកវរដោយសារមានការដុតផ្សារដើមគ ដោយសារការកើនឡើងរបស់ប្រជាជន ហើយស្បៀងឡើងថ្លៃ ជីវភាពអ្នកដែលអត់ហ្នឹងខ្វះខាត អត់មានលុយទិញអង្ករហូប វាមាន ឱ្យមានចោរកម្ម មានភាពអត់ឃ្លាននៅក្នុងទីក្រុងហ្នឹង។ ហើយទន្ទឹមហ្នឹងដែរ យើងឃើញមានអង្គការសហប្រជាជាតិមួយចំនួនគាត់បានមកបោះជាតង់នៅ ៗអូរបែកក្អម ដើម្បីឱ្យជនភៀសខ្លួនមកស្នាក់នៅមានស្បៀងមានអីផ្តល់ឱ្យចាស។

[០៩:៣៦:៣២]

**ស៖** សូមអរគុណលោកស្រី។ ក្រៅពីនេះ លោកស្រីមានបានឃើញស្ថានភាពអីផ្សេងទៀតទេ? ហើយដែលលោកស្រីមានដែលឃើញអ្នករបួសច្រើនទេ នៅពេលដែលគ្រាប់ផ្លោងហ្នឹង? ហើយប្តីលោកស្រីតើមានការមមាញឹកទេនៅក្នុងមន្ទីរពេទ្យដែលគាត់កាន់កាប់ថ្នាំ កាន់កាប់អីហ្នឹង?

**ឆ៖** ចាស ក្នុងចន្លោះពេលពីថ្ងៃទី១៤, ១៥, ១៦ ហ្នឹង គ្រួសារនាងខ្ញុំអត់បានមកផ្ទះទេ។ សូម្បីតែឪពុកនាងខ្ញុំក៏អត់បានមកដែរ ចាស។ ព្រោះនៅកន្លែងដែលគាត់បើកថ្នាំហ្នឹងមានពេទ្យទាហានមកតាមបណ្តាខេត្តនុំងមកបើកច្រើនណាស់។ ព្រោះមានអ្នករបួសច្រើននៅតាមខេត្ត ហើយនៅក្នុងទីក្រុងភ្នំពេញហ្នឹងក៏មានអ្នករបួសច្រើនដែរ។ អ៊ីចឹងការងារមមាញឹកត្រូវនៅចាំកន្លែងបើកថ្នាំតាមពេទ្យ ឱ្យពេទ្យតាមបណ្តាខេត្តហ្នឹងគាត់អត់បានមកផ្ទះទេ។

[០៩:៣៧:៣៣]

ហើយចំណុចមួយទៀតនៅតាមពេទ្យក៏អ៊ីចឹងដែរ ព្រោះអង្កាល់ហ្នឹងអ៊ំខ្ញុំគាត់ឈឺមួយដែរនៅនឹងពេទ្យ។ ពេលដែលខ្ញុំយកបាយយកអីទៅឱ្យគាត់ហ្នឹង គឺថាឃើញនៅពេទ្យមានអ្នកជំងឺនៅខាងក្នុងពេទ្យក៏មាន នៅខាងក្រៅពេទ្យក៏មាន ពេញណែនទាំងបន្ទប់ ទាំងយ៉ខាងក្រៅទៀត ចាស។

**ស៖** តើពេលនោះជីវភាពរបស់លោកស្រីនៅក្នុងគ្រួសារនិងក្រុមគ្រួសារលោកស្រីយ៉ាងម៉េចដែរ?

**ឆ៖** ជីវភាពនៅក្នុងក្រុមគ្រួសាររបស់នាងខ្ញុំ គឺមានការខ្វះខាតដោយសារឪពុកធ្វើការក៏មានប្រាក់ខែតិចតួច។ ចំណែកគ្រួសារនាងខ្ញុំគាត់ជាពេទ្យទាហានមិនមានប្រាក់ខែអ្វីធំដុំទេ ហើយខ្ញុំមានបង

ប្អូនដល់ទៅ១០នាក់។ ដូច្នេះការរស់នៅរបស់ពួកខ្ញុំ គឺពឹងទៅលើម្ដាយដែលធ្វើនំអាកោ ធ្វើបង្អែមអីលក់ចាស។ អ៊ីចឹងយើងជីវភាពរបស់នាងខ្ញុំ គឺខ្វះខាតណាស់អត់មានអ្វីធំដុំទេ។ ដោយសារសេដ្ឋកិច្ចឡើងថ្លៃ អ៊ីចឹងយើងអត់មានបានទិញអង្ករទិញអីទុកដាក់ច្រើនទេចាស។

[០៩:៣៨:៤៧]

**ស៖** អរគុណលោកស្រី។ ឥឡូវយើងឆ្លងចូលទៅដល់ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ពេលដែលក្រុងទីក្រុងភ្នំពេញត្រូវបែក។ នៅថ្ងៃទី១៧ មេសា ៧៥ តើលោកស្រី និងក្រុមគ្រួសារលោកស្រីនៅឯណា?

**ឆ៖** ចាស ថ្ងៃទី១៧ មេសា ឆ្នាំ៧៥ ក្រុមគ្រួសារនាងខ្ញុំនៅផ្សារឃ្លាំងរំសេវ នៅហ្នឹងផ្ទះអ៊ំ។ ចាស នៅព្រឹកថ្ងៃទី១៧ នោះ នាងខ្ញុំបានឮស្ករមីក្រូគេប្រកាសនៅតាមថ្នល់ អាថ្នល់មុខចេនឡានេះ ថ្នល់ខាងមុខហ្នឹងឯង។ ឮស្ករមីក្រូប្រកាសហើយ ពួកយើងអត់ដឹងទេ ម៉ោងប្រហែលជាប្រាំបីប្រាំបួន។ អត់ដឹងថា គេប្រកាសអីទេចាស។ ដល់ពេលនេះនាំគ្នារត់មកឡើងមកលើ មកថ្នល់ចាំមើល មកដល់កន្លែងនោះឃើញមានកងទ័ព ខ្ញុំថាខ្មែរក្រហមទៅចុះ ព្រោះពេលនោះអត់ស្គាល់ថា ខ្មែរក្រហមទេ។ ឃើញកងទ័ពស្លៀកឈុតខ្មៅ ចាស អាវខ្មៅ ខោខ្មៅ ស្បែកជើងកង់ឡាន ហើយកងទ័ពទាំងអស់នោះ មានកាំភ្លើង។

[០៩:៤០:០០]

ហើយកាំភ្លើងហ្នឹង អាកាំភ្លើងវែងៗនោះ ហើយកាំភ្លើងហ្នឹង គេកាន់កាណុងឡើងទៅលើអ៊ីចេះ គេកាន់អ៊ីចេះចាស។ ហើយមានទាហានមួយចំនួនទៀត គាត់លីអាកាំភ្លើងដូចត្រយ៉ូងចេកអ៊ីចឹង តែអាហ្នឹងបែរមុខទៅមុខ លីអ៊ីចេះ អាគ្រាប់ហ្នឹងនៅខាងមុខចាស។ ហើយដើរជាជួរនៅតាមថ្នល់ ហើយនៅលើថ្នល់ឡានហ្នឹងដែរឃើញមានឡានហ្ស៊ីប។ នៅលើឡាននោះមានទាហានស្លៀកឈុតពណ៌កាគីចាស។ នៅពេលដែលយើងពួកយើងរត់ឡើងមកដល់ថ្នល់ហ្នឹង ឮខាងហ្នឹងគេស្រែកថា "ភ្នំពេញរំដោះបានហើយ ពួកយើងមានសន្តិភាពហើយ"។ ពួកខ្ញុំ ហើយនិងប្រជាជនដែលនៅម្ដុំផ្សារដើមគ ផ្សារឃ្លាំងរំសេវហ្នឹង និងផ្ទះអ្នកដែលនៅតាមដងផ្លូវហ្នឹងនាំគ្នារត់មកអបអរទាំងអស់គ្នា។

[០៩:៤០:៥៥]

អ្នកខ្លះអរពេកដឹងថាសន្តិភាព ព្រោះប៉ុន្មានថ្ងៃមុនហ្នឹង គ្រាប់ផ្លោងចូល ឥឡូវមកដល់ថ្ងៃនេះសន្តិភាព។ អ៊ីចឹងត្រេកអរពេកនាំគ្នារត់។ អ្នកខ្លះរកបានកំណាត់ស យកមកក្រវីទៅ។ អ្នកណារកអត់បាន

អាវសហ្នឹងយកមកស្វាគមន៍ដើម្បីទទួលអបអរជាមួយនឹងកងទ័ពខ្មែរក្រហម ដែលរំដោះប្រជាជនឲ្យផុតពីការត្រូវគេផ្គោងគ្រាប់ ផ្គោងអីចូលហ្នឹងចាស។ ក្នុងនោះដែរ នៅពេលដែលគេដើរជាខ្សែអ៊ីចឹងហើយ ស្រាប់តែមានឃើញគេបំបែក ៗក្រុមអ្នកដើរហ្នឹងមិនមែនអ្នកជិះឡាន អ្នកជិះឡានៗទៅមុខបាត់ហើយ តែក្រុមអ្នកដើរហ្នឹង គេបំបែកចូលទៅតាមច្រកផ្លូវតូចៗ ចូលទៅតាមទៅច្រកឃ្លាំងរំសេវហ្នឹងចូលទៅតាមច្រកខាងលិចហ្នឹងទៀតចាស។ ហើយអ្នកដែលចូលទៅហ្នឹងមានមីក្រូ មានកាំភ្លើង ចាស។ ហើយគេប្រកាសថា "ស្រុកទេសយើងសន្តិភាពហើយ បងប្អូនរៀបចំអីវ៉ាន់ចេញទៅ កុំនៅទៀត ចេញតែ៣ថ្ងៃទេ"។

[០៩:៤២:០២]

ក្នុងចន្លោះពេល៣ថ្ងៃនេះដើម្បីឲ្យទាហានខ្មែរក្រហមហ្នឹងរៀបចំទីក្រុង ហើយបើសិនជាយើងមិនចេញទេ ក្នុង៣ថ្ងៃហ្នឹង កងទ័ពអាមេរិកាំងនឹងមកទម្លាក់គ្រាប់បែកកម្ទេចទីក្រុងភ្នំពេញចោលហើយ។ ដូច្នេះ ដើម្បីសេចក្ដីសុខរបស់បងប្អូនទាំងអស់គ្នាដែលនៅក្នុងទីក្រុងហ្នឹង ត្រូវតែនាំគ្នាចេញឲ្យអស់ក្នុងថ្ងៃហ្នឹង ចាស។

ដូច្នេះពេលនោះ ពួកខ្ញុំចាប់ផ្ដើមភ័យហើយ។ ចេញយ៉ាងម៉េច បើប្ដីឯពេទ្យទាហានឯណោះ? ហើយប្អូនស្រី ដោយសារប្ដីរបស់ប្អូនស្រីខ្ញុំហ្នឹង គេនៅជាទាហានរបស់ សូស្ដែន។ អ៊ីចឹងប្អូនស្រីត្រូវនៅឯទួលគោក ចាស។ ចំណែកឪពុកនាងខ្ញុំ គាត់នៅធ្វើការនៅជិតដេអិន ឯណោះ។ ហើយបងថ្លៃមួយទៀតគាត់ធ្វើការនៅការ៉ាសឡាន។ ព្រលឹមឡើង គាត់ចេញទៅបាត់ហើយ។ អ៊ីចឹងយើងត្រូវបែកគ្នា។ ដូច្នេះក្រុមគ្រួសារខ្ញុំពេលហ្នឹងអត់ចេញទេ ចាស។ សុំអង្វរពួកគេថា "ចាំជុំគ្នាសិនបានចេញ"។

[០៩:៤៣:០៦]

ឈ្លបហ្នឹង គេបានប្រាប់ថា "នៅពេលដែលគេត្រឡប់មកវិញក្នុងថ្ងៃហ្នឹង ត្រូវតែឃើញចេញឲ្យអស់ បើសិនជាមិនចេញទេ គេមកវិញដឹងហើយ"។ គេនិយាយតែប៉ុណ្ណឹងឯង។ អ៊ីចឹងគេទៅបាត់អស់។ ពួកខ្ញុំនេះគិតថាទៅតាមឪពុក ប៉ុន្តែទិសដែលគេត្រូវឲ្យយើងចេញហ្នឹងគឺឲ្យចេញមកតាមផ្លូវស្ទឹងមានជ័យ ហើយបើចង់ទៅឪពុកខ្ញុំ ត្រូវទៅឯក្នុងឯណោះ។ បើចង់ទៅប្ដី មកកាល់ម៉ែតឯណោះ។ បើចង់ទៅប្អូនឡើងទៅទួលគោក។ ចាស អ៊ីចឹងនៅនោះពេលសម្រេចចិត្តថា ទៅប្អូនមុនចុះ។ ខំធ្វើដំណើរទៅជិះកង់ទៀត អត់មានអីជិះទេ។ ធាក់កង់ទៅដល់អាផ្លូវលើទួលគោកហ្នឹង មានកងទ័ពគេនៅយាមកន្លែងហ្នឹងអត់ឲ្យឆ្លងទេ។ ថាត្រឡប់ក្រោយវិញ អត់មានទេ ខាងណោះអត់មកខាងណេះ ខាងណេះអត់ទៅខាង

ណោះទេ។ ចាស ពួកយើងអត់ឆ្លងបានទាំងអស់។ អ៊ីចឹងពួកខ្ញុំ នាងខ្ញុំក៏ត្រឡប់មកវិញ ហើយនៅម៉ោងជិតបី ចាស ម៉ោងជិតបី ចាំមើលឪពុកក៏អត់ឃើញមក ចាំមើលប្ដី ចាំមើលបងក៏អត់ឃើញមក។ កងទ័ពហ្នឹងគេត្រឡប់មកមួយជុំទៀតហើយ គេសួរថា "ចេញមិនចេញ? ចេញមិនចេញ? បើមិនចេញអញបាញ់ងាប់ ចេញមិនចេញ?"។ ពេលនោះឯងដែលយើងគិតថា ភាពត្រេកអរសប្បាយរីករាយ ដែលពេលម៉ោងប្រាំបី ម៉ោងប្រាំបួនព្រឹកហ្នឹងសប្បាយណាស់ មកទល់នឹងម៉ោងបីល្ងាច គឺភ្នែកនៅកញ្ជឹង-ករៀងខ្លួនហើយ។ ស្ងាត់ អត់ដឹងថាទៅណា មកណើ មិនដឹងជាចេញទៅណា បើអត់មានកន្លែងទៅ។

[០៩:៤៤:៤០]

ក្នុងពេលនោះ មានផ្ទះមួយនៅជិតផ្ទះខ្ញុំហ្នឹង អត់ចេញដែរ ចាស អត់ចេញ ព្រោះគាត់បែកបងប្អូនអស់ អត់មាននៅ ចេញទៅណាម្នាក់ឯង។ ដល់ពេលអត់ចេញអ៊ីចឹង ខ្ញុំឃើញឈ្លបម្នាក់យកកាំភ្លើងដែលកាន់ឡើងលើអ៊ីចឹងដាក់ចុះបាន យកអា គេហៅថា អាដងកាំភ្លើង អាខ្នងវាហ្នឹង វ៉ៃទៅលើគ្រួសារហ្នឹង ចាស។ ម៉ែខ្ញុំឃើញសកម្មភាពហ្នឹង នឹកឃើញថា "កូនអើយ តែផុតគេវ៉ៃ គេបាញ់យើងហើយកូនចេញ"។ ចាស ពេលនោះឯង ដែលក្រុមគ្រួសារគ្នា ខ្ញុំណា ត្រូវគេបង្ខំឲ្យចេញតាំងភ្នំពេញតាំងពីថ្ងៃទី១៧ ខែមេសា ហើយដោយបែកបាក់ប្ដី ឪពុក បងថ្លៃ ប្អូនស្រី តាំងថ្ងៃចាកចេញហ្នឹងម្ល៉េះ ចាស។

**ស៖** អរគុណលោកស្រី។ ចុះ ដែលពេលលោកស្រីចេញនោះ ប្រហែលជាម៉ោងប៉ុន្មានលោកស្រី?

**ឆ៖** ចាស ពេលនាងខ្ញុំចេញហ្នឹង ប្រហែលជាម៉ោងបី ក៏ប៉ុន្តែអំមិញហ្នឹង ខ្ញុំនិយាយអត់អស់។ ខ្ញុំសូមសាទៅលើវិញបន្តិច ក្នុងពេលដែលកងទ័ពហ្នឹង ប្រកាសឲ្យចេញអ៊ីចឹង គេបានប្រកាសទៀតថា "បងប្អូនណាដែលមានខោអាវទាហាន មានកាំភ្លើង ឲ្យយកចេញឲ្យអស់"។ អ៊ីចឹង ខ្ញុំអត់ដឹងថា ផ្លូវហ្នឹងគេហៅផ្លូវអី តែផ្លូវមុខចេនឡាហ្នឹង។

[០៩:៤៦:០៤]

នៅលើដងផ្លូវមុខចេនឡាហ្នឹង យើងឃើញខោអាវទាហាន ហើយនិងកាំភ្លើង ដូចកូនភ្នំអ៊ីចឹងមួយកន្ទុបៗ ដាក់តម្រៀបនៅតាមហ្នឹង ជញ្ជូនមកចេញអស់ហើយ ផ្ទះអ្នកណា ក៏ជញ្ជូនយកមកដាក់ដែរ។ ហើយខ្ញុំឃើញបុរសខ្លះ គាត់ស្លៀកតែខោខ្លី ហើយនិងអាវយឺតទេ ហើយគាត់អត់មានខោអាវអីពាក់ពីលើទេ។ ហើយខ្ញុំឃើញទាហានមួយទៀត ផ្ទះគាត់មិនមែននៅនឹងផ្លូវហ្នឹងទេ តែពេលហ្នឹង គាត់ស្លៀកទាហាន។ នៅពេលដែលគាត់ធ្វើដំណើរនៅតាមផ្លូវហ្នឹង ទាហានខ្មែរក្រហមហ្នឹង គេឲ្យគាត់ដោះ

ខោដោះអាវចេញដាក់ហ្នឹង ហើយទៅតែខ្លួនទទេទៅ ទៅយកខោអាវនៅឯណា ទៅៗ ចាស។ អាហ្នឹងចំណុចមួយទៀត នៅៗក្នុងពេលដែលកងទ័ពខ្មែរក្រហមហ្នឹងចូលដល់ទីក្រុងភ្នំពេញ ចាស។

**ស៖** តើពេលដែលលោកស្រី និងក្រុមគ្រួសារលោកស្រីត្រៀមខ្លួននឹងចេញ លោកស្រីបានយកអីខ្លះទៅជាមួយ? មានប្រដាប់ប្រដាអីខ្លះ?

**ឆ៖** ចាស ក្នុងពេលចេញនោះ ដោយគិតថា ៣ថ្ងៃ។ អ៊ីចឹង ពួកខ្ញុំគិតថា ៣ថ្ងៃ យើងយកគ្រប់តែ៣ថ្ងៃបានហើយ។ ហើយបងថ្លៃខ្ញុំ គាត់មានឡានមួយ តែថ្ងៃហ្នឹង គាត់អត់យកឡានទៅទេ។ ពួកខ្ញុំបានសរសេរស្លាកមួយបិទនៅលើឡានហ្នឹង ថា "បើឪពុក ឬបងថ្លៃ ឬប្តីខ្ញុំមក ឲ្យចេញទៅតាមផ្លូវស្ទឹងមានជ័យ ពីព្រោះខ្ញុំនេះ គេឲ្យចេញទៅហើយ" ចាស។ ហើយសម្ភារៈដែលខ្ញុំយកទៅតាមខ្លួននោះ គឺអត់មានអីទេ ដោយគេថា តែ៣ថ្ងៃ។ អ៊ីចឹងយកផ្អកនោះ ម៉ែធ្វើបានមួយក្រឡដែរ យកចេញល្មមតែ៣ថ្ងៃទេ ជញ្ជូនយកទុកលើផ្ទះវិញ។ ហើយអង្ករហូបអ៊ីចឹងដែរ យកតែល្មមតែ៣ថ្ងៃហ្នឹង គិត១ថ្ងៃយើងហូបអស់ប៉ុន្មាន គុណនឹង៣ថ្ងៃ យកដាក់ទៅតាមហ្នឹង ហើយនិងខោអាវតាមខ្លួនបន្តិចបន្តួច មានជីដូនចាស់មួយទៀត។ ចាស ជីដូនចាស់មួយទៀតទៅជាមួយទៀត។ ដូច្នេះ ក្នុងការចេញហ្នឹង គឺពិបាកណាស់។ ការធ្វើដំណើរដោយឡាំប្រីតារបស់ប៉ាខ្ញុំ ដែលអត់មានសាំង។ អ៊ីចឹង ជញ្ជូនប្អូនតូចៗ ដាក់លើឡានហ្នឹង ស្បៀងអីដាក់លើឡាំប្រីតាហ្នឹង ហើយឲ្យប្អូនមួយអាយុប្រហែលជា១០ឆ្នាំហ្នឹង អង្គុយកាច់ចង្កូត ហើយពួកយើងអ្នកណាដែលមានកម្លាំងហ្នឹង នាំគ្នារុញៗ។ ចាស រុញចេញទៅតាមផ្លូវស្ទឹងមានជ័យ។

[០៩:៤៨:៤១]

**ស៖** ពេលនុ៎ង លោកស្រីមានកូនប៉ុន្មាននាក់ដែរ លោកស្រី? ហើយសមាជិកគ្រួសារដែលទៅជាមួយលោកស្រីទាំងអស់ប៉ុន្មាននាក់?

**ឆ៖** នាងខ្ញុំមានកូនប្រុសម្នាក់ តែកូនហ្នឹង ទើបតែកើតបាន៣ ឬ៤ខែទេ ចាស។ ហើយក្នុងនោះដែលសមាជិកដែលទៅជាមួយនាងខ្ញុំហ្នឹង មានសរុបទាំងអស់១៣នាក់ គិតទាំងអ៊ំៗ ទាំងពូទាំងអីទៀត ១៣នាក់ ទាំងយាយអីទៀត ចាស។

**ស៖** តើពេលដែលលោកស្រីចេញពីផ្ទះទៅ លោកស្រីទៅមុខព្រួញនៅស្ទឹងមានជ័យ ដូចលោកស្រីបានបញ្ជាក់អ៊ីចឹង តើនៅតាមផ្លូវលោកស្រីបានឃើញអីខ្លះ នៅតាមផ្លូវ ដែលលោកស្រីចេញដំណើរ?

**ឆ៖** ចាស នៅតាមផ្លូវដែលនាងខ្ញុំចេញដំណើរទៅ នាងខ្ញុំឃើញមនុស្សជាច្រើនណែនណាន់

គាន់តាប់នៅតាមពេញដងផ្លូវ។ នៅពេលដែលក្បួនប្រជាជនជម្លៀសហ្នឹង ដើរមកដល់ផ្លូវបំបែកចេញពីពេទ្យរុស្ស៊ី ចាស ខាងពេទ្យរុស្ស៊ី ក៏ឲ្យចេញមកច្រកហ្នឹងដែរ។

ខ្ញុំឃើញខាងពេទ្យរុស្ស៊ីហ្នឹងមានតាំងពីអាគ្រែពេទ្យដែលមានជើងរុញនោះ មានគ្រែពេទ្យរុញចេញមក នៅលើពេទ្យហ្នឹងមានអ្នកនៅបណ្ដោងសេរ៉ូមនៅឡើយ ហើយនៅតាមផ្លូវចេញពីពេទ្យមកហើយនៅអាផ្លូវមួយទៀត បុកពីមុខផ្សារដើមគរនោះ មកអ៊ីចេះមកប្រជុំគ្នាកន្លែងកាច់ជ្រុងហ្នឹងបុកតែមួយច្រកទៅស្ទឹងមានជ័យ។ អ៊ីចឹងមនុស្សចង្អៀតណែន។ យើងធ្វើដំណើរអត់បានលឿនទេ ហើយអ្នកខ្លះអូសម៉ូតូ អ្នកខ្លះជិះកង់ អ្នកខ្លះធាក់ស៊ីក្លូ អ្នកខ្លះហ្នឹងស្ពាយអីវ៉ាន់សំពីងសំពោង ម្នាក់ៗមានស្ពាយពីមុខពីរ ពីក្រោយពីរ អ្នកខ្លះមានមនុស្សចាស់ជរា អ្នកជំងឺហ្នឹងបណ្ដើរទ្រៗទៅតាមផ្លូវហ្នឹងជាមួយគ្នា។ ហើយសភាពការណ៍ពេលនោះ វាចង្អៀតពេកចង់ថប់បន្តិចអីបន្តិច ប្រជៀតគ្នាហើយ ខាងទាហានរបស់ខ្មែរក្រហមហ្នឹង គេមិនមែនព្រលែងឲ្យយើងដើរទៅស្រេចតែចិត្តយើងឯណា។ ចាស មកពីស្ទឹងមានជ័យក៏មាន មកពីពេទ្យរុស្ស៊ីក៏មានទាហាននៅខាងនុ៎ង មកពីអាផ្លូវផ្សារដើមគរខាងណោះក៏មាន ហើយនៅអាផ្លូវមុខច្រកខ្ញុំចេញពីចេនឡាចំមកបុកតាមស្ពានត្រង់ហ្នឹង ក៏មានទាហានខ្មែរក្រហមហ្នឹងប្រដាប់ដោយអាវុធគ្រប់ដៃហ្នឹងគេស្ពកមកជាមួយដែរ។ អ៊ីចឹងមុខព្រួញគឺៗចេញតាមស្ពានស្ទឹងមានជ័យហ្នឹង ទៅត្រង់តែម្ដងអត់ៗមាននរណាប៊ានបែកទៅខាងណាទេចាស។

[០៩:៥១:៤៣]

**ស៖** តើនៅពេលដែលលោកស្រីធ្វើដំណើរហ្នឹង លោកស្រីនៅតាមផ្លូវ លោកស្រីមានឃើញអីទៀត មានឃើញខ្មោច មានឃើញសាកសពអីទេលោកស្រី? មានឃើញព្រះសង្ឃអីទេ ពេលជម្លៀសហ្នឹង?

**ឆ៖** ចាស នៅតាមផ្លូវក្នុងពេលដែលខ្ញុំចេញទៅដល់ស្ទឹងមានជ័យហ្នឹង សាកសពដែលមានស្លាប់នោះគឺមានស្លាប់នៅក្នុងគ្រែ -- នៅលើគ្រែពេទ្យ។ ចាស ដូចថាចេញពីពេទ្យមកបែបគាត់មានបញ្ហាយ៉ាងម៉េច ដល់ពេលចង្អៀតណែនណាន់តាន់តាប់អ៊ីចឹងទៅក៏ស្លាប់នៅលើអាគ្រែពេទ្យហ្នឹង ហើយគេទុកចោលនៅតាមផ្លូវហ្នឹងឯង គេអត់រុញទាំងគ្រែហ្នឹងយកទៅទេ។ ហើយចំណុចមួយទៀត មនុស្សចាស់ៗដែលដើរអត់រួច មនុស្សចាស់ដែលដើរអត់រួចហ្នឹងកូនចៅហ្នឹងនៅគ្រា នៅលើកៗលើកគាត់ដាក់លើកង់ដាក់អីហើយគាត់ទុរន់ទុរាចឹងទៅ ណែ៎ ហើយកូនចៅរបស់គាត់ហ្នឹងថា “សូមលោក -- សូមខាងទាហានខ្មែរក្រហមហ្នឹងថា ខ្ញុំសូមសម្រាកនៅទីនេះ មើលម្ដាយខ្ញុំ មើលជីដូនខ្ញុំសិន ព្រោះគាត់ទៅអត់រួច

ទេ” ពេលនោះខាងទាហានខ្មែរក្រហម ឈ្លបគេហ្នឹងគេថា “អ្នកណាដើររួចដើរទៅ អ្នកណាដើរអត់រួច ទុកហ្នឹងហើយចាំគេមើលឲ្យ។ អត់មានឲ្យនៅអីកកស្ទះពេញផ្លូវ អ៊ីចឹងស្ទះចរាចរគេ ទៅមុខឲ្យលឿន”។ ចាស អ៊ីចឹងក្នុងពេលនោះ នាងខ្ញុំក៏យោងតែអាត្មាខ្លួនឯងអត់រួចដែរ បីកូនផង ហើយនៅសរសៃខ្ចីទៀត។ អ៊ីចឹងអត់បានទៅទេ ចេះតែខំទៅមុខទៀតអ៊ីចឹងទៀតតាមអ្នកណាដែលទៅរួចក៏ទៅ អ្នកណាទៅមិនរួច ទេគេឲ្យនៅហ្នឹងក៏នៅជាមួយគេទៅ ចាស។

[០៩:៥៣:៣៨]

**ស៖** ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ដែរថា ពួកទាហានខ្មែរក្រហមដែលលោកស្រីបានលើកឡើងហ្នឹង គឺជាទាហានតែមួយដែលលោកស្រីបានឃើញនៅក្នុងក្បួនទ័ពដែលហៃពេលជ័យជម្នះមកដល់មែនទេ?

**ឆ៖** ចាស ទាហាននោះស្លៀកពាក់ឈុតដូចគ្នា ក៏ប៉ុន្តែនាងខ្ញុំអត់ចំណាំមុខទេ ព្រោះចូលទៅ ច្រើនណាស់អត់ដឹងមុខអ្នកណា មុខអ្នកណីទេ ចំណាំបានតែខោអាវ ហើយនិងក្រមាក្រហម ម្លូកៗ អាកំប៉ិតគេហ្នឹង ហើយស្បែកជើងកង់ឡាន។ ហើយនិងអ្នកខ្លះតឺនុយកាគី តែអ្នកដែលពណ៌កាគីហ្នឹង ភាគច្រើនមានអាកាំភ្លើងនៅក្រវាត់ចង្កេះ ហើយទាហានខ្មែរក្រហមខ្លះមានអាកាំភ្លើងអី ដូចខ្សែអ៊ីចឹង ពាក់ឈាងអ៊ីចេះ ចាស ដូចធ្នូអ៊ីចឹងវែងគេពាក់អ៊ីចឹងមក អ្នកខ្លះគេក្រវាត់នៅចង្កេះគេ។ ឃើញអ៊ីចឹងតែ បើថាមុខដដែលៗនោះ នាងខ្ញុំអត់ចំណាំបានទេ។

**ស៖** អរគុណលោកស្រី។ នៅក្នុងពេលដែលលោកស្រីធ្វើដំណើរចេញពីទីក្រុងភ្នំពេញហ្នឹង តើ លោកស្រីមានឃើញប្រជាជនដែលទីក្រុងភ្នំពេញមានអ្នកណាបើក -- បកត្រឡប់ទៅក្រោយវិញទេ? ព្រោះនៅក្នុងហ្នឹងជាធម្មតាវាមានបាត់បងប្អូនអីហើយណ៎ា មានអ្នកណាបកទៅក្រោយទេ? ហើយ ទាហានខ្មែរក្រហមខ្មែរក្រហមយល់ព្រមឲ្យបកទៅក្រោយ ដែលផ្ទុយនឹងទិសមុខព្រួញរបស់គេទេ?

**ឆ៖** ចាស នៅពេលដែលក្រុមគ្រួសារនាងខ្ញុំបានឆ្លងផុតស្ទឹងមានជ័យ ឆ្លងផុតផ្សារស្ទឹងមាន-ជ័យហើយ ពេលនោះ ខ្ញុំឃើញបីនាក់ គាត់ត្រឡប់មកវិញ គាត់ថា គាត់ប្រញាប់ពេក គាត់ភ្លេចយកលុយ ហើយនិងគាត់ទៅទទួលកូនគាត់ទៀត ព្រោះកូនគាត់ គាត់ចាំនៅហ្នឹងរកអត់ឃើញ ឥឡូវគាត់សុំទៅយក កូនគាត់ទៀត។ ចាស នៅពេលដែលបីនាក់ហ្នឹងត្រឡប់បកមកក្រោយវិញ ទាហានខ្មែរក្រហមដែល យាមនៅតាមផ្លូវ ដែលស្កកពួកយើងទៅហ្នឹង គេអត់ឲ្យមកទេ គេអត់ឲ្យចេញមកវិញទេ។ ចាស ហើយ គេប្រើពាក្យគំរាមទៀត អ្នកឯងបានតែឆ្លងផុតពីកន្លែងដែលគេហាមឃាត់នេះ គេនឹងបាញ់សម្លាប់ចោល ចាស។ ដូច្នេះពួកគាត់នៅ ដូចថាមនុស្សយើងខ្លាចណាស់សេចក្ដីស្លាប់។ អ៊ីចឹងពួកគាត់អត់បានឆ្លងមក

ទេ។ ចាស ៗសូមជម្រាបប៉ុណ្ណឹង។

[០៩:៥៦:២០]

**ស៖** អរគុណលោកស្រី។ តើពីផ្ទះលោកស្រី ដែលលោកស្រីចេញដំណើរមក រហូតមកដល់មុខផ្សារស្ទឹងមានជ័យ លោកស្រីប្រើពេលប៉ុន្មានដែរ?

**ឆ៖** ចាស ពេលនោះយើងចេញមកម៉ោងបីល្ងាចហើយ ដូច្នេះមកដល់ស្ទឹងមានជ័យហ្នឹងយប់បាត់ហើយ ម៉ោងបីល្ងាចចេញពីនោះមក ព្រោះមនុស្សចង្អៀតគ្នា។ អ៊ីចឹងយប់នៅនឹងផ្សារស្ទឹងមានជ័យហ្នឹងហើយ។ ហើយនៅពេលយប់នោះ ពួកយើងសម្រាកនៅតាមចិញ្ចើមថ្នល់កៀនៗផ្សារ ក្នុងតូបគេអីដែលគេរើអីវ៉ាន់ចេញអស់ហ្នឹង នាំគ្នាឈប់រដូករណែលពេញថ្នល់ហ្នឹងឯង។ ព្រោះអត់មានឡាន មានម៉ូតូអីបើកទៀតទេ។ អ៊ីចឹងកណ្ដាលថ្នល់ហ្នឹងក៏នាំគ្នាស្នាក់នៅដែរចាស។

**ស៖** ក្រៅពីការឲ្យចេញពីទីក្រុងភ្នំពេញចំនួន៣ថ្ងៃ តើលោកស្រីមានឮមីក្រូពីការប្រកាសស្អីទៀតទេ ដែលឲ្យប្រជាជន -- មានប្រាប់ថាឲ្យទៅកន្លែងណាផ្សេងទៀតទេ? ឬឲ្យទៅស្រុកកំណើត? ឬក៏យ៉ាងម៉េចដែរលោកស្រី ពេលដែលលោកស្រីចេញមក? គេនៅតែស្រែកប្រកាសតាមមីក្រូដដែល ឬក៏គេនិយាយប្រាប់មាត់ទទេ? ថាឲ្យទៅទីកន្លែងណា ដែលទៅហ្នឹង គឺឲ្យទៅកន្លែងណា ទៅតាមមុខព្រួញដែលគេតម្រង់ទិសឲ្យ?

[០៩:៥៧:៥១]

**ឆ៖** ចាស ទៅៗហួសស្ទឹងមានជ័យឆ្ងាយបន្តិចហើយ។ ប៉ុន្តែអត់ទាន់ដល់ចំដូងទេ។ នៅពេលនោះ ខ្ញុំបានឮមីក្រូគេប្រកាសថា អ្នកណានៅស្រុកណា ឲ្យទៅស្រុកហ្នឹងវិញចុះ ប៉ុន្តែមិនឲ្យដើរបកក្រោយទេ។ ត្រូវដើរវាងទៅតាមទិសដែលគេប្រាប់ហ្នឹង តែធ្វើម៉េចទៅស្រុកវិញទៅ។ ហើយគេសួរទៀតថា អ្នកណាដែលគ្រប់៣ថ្ងៃ គេនឹងបញ្ជូនចូលទៅភ្នំពេញវិញ ចំពោះអ្នកណាដែលជាមន្ត្រីរាជការជាទាហាន ជាពេទ្យ ជាគ្រូបង្រៀន ជាកងទ័ពអីអ៊ីចឹង គេត្រូវការកម្លាំងហ្នឹងដើម្បីយកទៅបម្រើការងារនៅក្នុងទីក្រុងភ្នំពេញវិញ។ អ៊ីចឹងនៅពេលដែលគេរៀបចំទីក្រុងភ្នំពេញហើយ គេនឹងឲ្យអ្នកទាំងអស់នោះត្រឡប់ចូលទៅវិញ។ ប៉ុន្តែដើម្បីឲ្យដឹងថា អ្នកណាត្រូវទៅវិញ ត្រូវឲ្យកត់ឈ្មោះសិន ចាស។ អ៊ីចឹងនៅពេលនោះ សំណាងដែរដែលឪពុកខ្ញុំគាត់អត់ទៅ។ នៅពេលនោះ ខ្ញុំឃើញគេប្រជ្រៀតគ្នាទៅចុះឈ្មោះ តែខ្ញុំមិនដឹងថា អ្នកណាស័ក្តិប៉ុន្មាន អ្នកណាធ្វើពេទ្យ អ្នកណាធ្វើគ្រូទេ ឃើញតែប្រជ្រៀតគ្នាទៅចុះឈ្មោះនៅកន្លែងកងទ័ពខ្មែរក្រហម គេហៅថា កន្លែងស្នាក់ការដែលគេចុះឈ្មោះហ្នឹង គេមានអ្នកចាំ

កត់នៅចិញ្ចើមថ្នល់ហ្នឹង។ ឈរចាំកត់ ដែលគេមានដាក់ដូចបារ៉ាសគេអ៊ីចឹងសម្រាប់ឲ្យយើងចូលទៅកត់ឈ្មោះ។ ប៉ុន្តែមនុស្សដណ្តើមគ្នាទៅកត់ ដោយខ្លាចថា កត់មិនទាន់នឹងគេ អត់បានចូលភ្នំពេញវិញ។

[០៩:៥៩:២៨]

**សៈ** លោកស្រីមានបានសង្កេតឃើញទេ អ្នកដែលកត់ឈ្មោះហ្នឹង ក្រោយមកគេមានប្រកាសឲ្យនៅឈរនៅកន្លែងម្តុំ ហើយគេនាំទៅណាទៀតទេ? មានឃើញទេកន្លែងហ្នឹង?

**ផះ** ចាស អ្នកដែលកត់ឈ្មោះហ្នឹង គឺអត់បានដើរទៅជាមួយពួកខ្ញុំទៀតទេ។ អ្នកដែលកត់ឈ្មោះហ្នឹង គេមានកម្លាំងមកនាំ ហើយមុននឹងទៅហ្នឹង អ្នកដែលកត់ឈ្មោះហ្នឹងបានប្រាប់ប្រពន្ធកូនថា "ទៅមុនទៅ ចាំអញទៅដល់ភ្នំពេញ បានការងារធ្វើហើយ ចាំចេញមកយកវិញ។ មានប៉ុន្មានទេ ទៅតែទៅដល់ភ្នំពេញមកវិញហើយ អ៊ីចឹងកុំទៅឆ្ងាយពេកជិតៗហ្នឹងហើយ ឆាប់បានចេញមកយកទៅវិញ ចាស។ ហើយដូច្នេះក្រុមនោះ គឺអត់ឲ្យដើរទៅជាមួយពួកប្រជាជនដូចនាងខ្ញុំអីទេ អ្នកដែលចុះឈ្មោះហ្នឹងកងទ័ពខ្មែរក្រហមហ្នឹងគាត់បានប្រមូលយកទៅដាក់មួយកន្ទុបតែខ្ញុំអត់ដឹងថា គាត់ដាក់ខាងណាទេ។ ព្រោះយើងអត់បានតាមដានគេស្អិតទេ គ្រាន់តែមើលទៅឃើញសភាពគេធ្វើអ៊ីចឹង ហើយគេកាក់អ្នកទាំងអស់នោះអត់ឲ្យដើរទៅជាមួយពួកប្រជាជនដែលជម្លៀសទៅទេ ចាស។

**សៈ** តើលោកស្រីមានបានដឹងទេ? តើសមាសភាពដែលទៅចុះឈ្មោះហ្នឹងភាគច្រើនជាៗអ្នកណាជាមន្ត្រីរាជការ ឬជាទាហាន លន់ នល់ ឬជាប៉ូលិស ជាគ្រូបង្រៀន ឬក៏ជាពេទ្យ ចាស? ដែលភាគច្រើនចាស? ដែលខាងកងទ័ពខ្មែរក្រហមចង់បានជាពិសេសនោះ គឺខាងណា? ខាងក្រសួងណា? ខាងមន្ត្រីរាជការណាចាស?

[១០:០១:១០]

**ផះ** ចំណុចកន្លែងហ្នឹង បើសិនជាអ្នកខ្ញុំដឹងវិញ គឺដឹងពីក្រុមគ្រួសារគាត់ដែលអត់បានទៅចុះឈ្មោះទៅតែប្តីនោះ។ ក្រុមគ្រួសារហ្នឹងដើរជាមួយហ្វូងយើងហ្នឹង គាត់ប្រាប់ថាប្តីខ្ញុំធ្វើគ្រូ ម្នាក់ទៀតថាប្តីខ្ញុំធ្វើសាស្ត្រាចារ្យ ហើយមានមីងមួយទៀតគាត់ថា អ៊ីចេះ ប្តីខ្ញុំអត់ធ្វើអីសោះធាក់ស៊ីក្លូស្រាប់តែចុះឈ្មោះថា ធ្វើការនឹងគេដែរ ព្រោះគាត់ចង់ឆាប់បានចូលភ្នំពេញមុនគេ។ អ៊ីចឹងភាគច្រើនអ្នកដែលទៅចុះឈ្មោះហ្នឹងសុទ្ធតែអ្នកធ្វើការធំៗនៅភ្នំពេញហ្នឹងឯង។ មិនមែនប្រជាជនទេ ប្រជាជនមានដោយទៅមួយពីរទេ។

**សៈ** អរគុណលោកស្រី។ នៅតាមផ្លូវតើពួកខ្មែរក្រហមមានបានផ្តល់ស្បៀងអាហារ ថ្នាំសង្កូវ

អីដល់លោក -- ទីជម្រកអីដល់ខាងក្រុមគ្រួសារលោកស្រី និងប្រជាជនដែលជម្លៀសពីទីក្រុងភ្នំពេញទេលោកស្រី?

[១០:០២:១៤]

**ផ៖** ចាស នៅតាមផ្លូវដែលពួកយើងជម្លៀសចេញទៅនេះ គឺស្បៀងអាហារទឹកអី ជម្រកអី ខាងទាហានខ្មែរក្រហមហ្នឹងអត់បានឧបត្ថម្ភ ឬផ្តល់ឲ្យពួកយើងទេ។ ពួកយើងទាំងអស់គ្នាធ្វើដំណើរទៅដោយអត់បានព្រាងទុក ដោយអត់មានយកសម្ភារៈអីធំដុំទៅជាមួយទេ។ អ៊ីចឹងនៅពេលដែលធ្វើដំណើរទៅតាមផ្លូវយប់កន្លែងណាពួកយើងនាំគ្នាសម្រាក ដោយកាច់មែកឈើបោសដី ឬក៏ទ្រាប់មែកឈើដេកចាស។ ហើយស្បៀងដែលយើងយកចេញពីផ្ទះទៅគម្រប់តែ៣ថ្ងៃហ្នឹង វាកាន់តែខើចទៅហើយ។ ដូច្នេះនៅពេល ដល់ពេលផុតពីដាំបាយ លែងប៉ានដាំបាយហើយ នាំគ្នាបបរម្តង ថាក្រែងលោអត់គ្រប់ថ្ងៃយើងដាច់ស្បៀង។ អ៊ីចឹងនាំគ្នាដាំបបរហូបម្តង បើពាក់ព័ន្ធនឹងទាហានខ្មែរក្រហមដែលថា ត្រូវផ្តល់ជាថ្នាំសង្កូវស្បៀងអាហារជម្រកអី គឺអត់មានទាំងអស់ គឺយើងដោះស្រាយដោយខ្លួនឯងចាស។

[១០:០៣:១៩]

**ស៖** អរគុណលោកស្រី។ ចំពោះការចេញដំណើររបស់លោកស្រី លោកស្រីមានក្នុងក្រុមគ្រួសារលោកស្រីភាគច្រើនជាអ្នករដ្ឋការដែរនោះ តើក្រុមគ្រួសារលោកស្រីមានរង់ចាំ ដូចថាបង្អង់ៗការធ្វើដំណើរដើម្បីរង់ចាំថា ៣ថ្ងៃត្រឡប់មកវិញ មានបង្អង់ទេ ឬមួយក៏ស្រូតទៅមុខ?

**ផ៖** ក្រុមគ្រួសារនាងខ្ញុំ ដើរយឺតៗដែរ អត់ប៉ានទៅលឿនប៉ុន្មានទេ ក្រែងលោចាំលោកពុកហើយនិងបងអីទៅតាមក្រោយ។ ប៉ុន្តែចាំបាត់ៗ អត់ឃើញសោះ ៣ថ្ងៃហើយក៏អត់ឃើញ សំកុកចាំឲ្យគេហៅចូលភ្នំពេញវិញ៣ថ្ងៃក៏អត់ឃើញគេហៅ។ ឮតែគេថា ទៅមុខទៀតទៅអង្គការចាំទទួល។ កាលនុំងអត់ស្គាល់ទេ អង្គការ។ ស្មានតែអង្គការមនុស្សធម៌ ធ្វើតង់ចែកស្បៀងអីហ្នឹង គិតថា អូ្ន! អង្គការទទួលយើងហើយ យើងទៅដល់មានហូបមានចុកហើយអត់អីទេ។ ដើរដំអក់ៗអ៊ីចឹងរហូតមកដល់ចំការដូង ចាស មកដល់ចំការដូងហើយសុខចិត្តសម្រាកនៅហ្នឹងទៀត។ ចាំអស់៤, ៥ថ្ងៃទៀត ចាស ប៉ុន្តែលទ្ធផលនៃការ ៣ថ្ងៃចូលភ្នំពេញវិញហ្នឹង គឺអត់ឃើញមានគេឲ្យចូល ឃើញតែគឲ្យទៅមុខ។ អង្គការចាំទទួលចាស។

[១០:០៤:៥៤]

**ស៖** ហើយក្រៅពីនេះលោកស្រីឃើញពួកទាហានខ្មែរក្រហម គេមានអត្តចរិតបែបម៉េចខ្លះ?

គឺថាជំរុញឲ្យលោកស្រីទៅមុខ ឬក៏ឲ្យលោកស្រីទៅស្នាក់នៅកន្លែងណាមួយ ឬក៏បង្ខំឲ្យទៅមុខទៀត?

**ឆ៖** ចាស ទាហានខ្មែរក្រហមអត់មានឲ្យយើងស្នាក់នៅទេ គឺជំរុញឲ្យទៅមុខរហូត។ ហើយចំណុចសំខាន់មួយទៀត ក្នុងការធ្វើដំណើរនៅតាមផ្លូវហ្នឹង ដោយសារនាងខ្ញុំ ខ្ញុំចង់និយាយថា ខ្ញុំក្រមែននៅទីក្រុងភ្នំពេញ ប៉ុន្តែខ្ញុំមិនដែលបានដើររហេមរហាមដាច់បាយ ដាច់ទឹកអី បែកប្ដី បែកប្រពន្ធអីចឹងទេ។ ដល់ពេលបង្ខំអីចឹងទៅ ខ្ញុំវាត្រូវទាស់។ ចាស ដល់ពេលខ្ញុំទាស់ហ្នឹង ខ្ញុំអត់មានទឹកដោះឲ្យកូនបៅទេ។ ដូច្នេះនៅពេលនោះ ថ្នាំក៏អត់មាន ហើយអីចឹងអត់ដឹងធ្វើម៉េច អាកូនអត់ទឹកដោះបៅហ្នឹង អត់តែប៉ុន្មានថ្ងៃហ្នឹង អាជម្ងឺសចេញមកហ្នឹង។ ទឹកដោះគោក៏អត់ អីក៏អត់ យកតែទឹកបន្តក់ឲ្យកូនបៅ។ ខ្ញុំកូនខ្ញុំហ្នឹងបានត្រូវស្លាប់នៅពេលជម្ងឺសហ្នឹង។

[១០:០៦:១៤]

ហើយនៅពេលស្លាប់ហ្នឹងទៀត អត់ដឹងយកទៅណាទេ គេឲ្យយកទៅដាក់ចោលកប់ចោលនៅក្នុងព្រៃដូចសត្វធាតុ។ ហើយពេលជម្ងឺសហ្នឹង ខ្ញុំឈឺចាប់ណាស់ ព្រោះជាកូនទី១របស់ខ្ញុំដែលខ្ញុំពីរនាក់ប្ដីប្រពន្ធទើបនឹងរៀបការគ្នានៅ៧៤។ ៧៥ យើងបានកូនមួយហ្នឹង។ ហើយ៧៥ហ្នឹង ជម្ងឺសទៅ កូនហ្នឹងត្រូវស្លាប់បណ្ដោយ។ ហើយស្លាប់ហ្នឹង ជាកំហុសអ្នកណា? បើខ្ញុំមិនមែនថាខ្ញុំ ខ្ញុំក៏មានលទ្ធភាពចិញ្ចឹមកូនដែរ ប៉ុន្តែដោយសារគេបង្ខំឲ្យខ្ញុំទៅទាំងសរសៃខ្ចី កូនខ្ញុំត្រូវបានស្លាប់។

**សះ** អរគុណលោកស្រី។ នៅតាមផ្លូវ ដែលលោកស្រីធ្វើដំណើរចេញទៅ ក្រោយពីការស្លាប់កូនហើយ តើនៅតាមផ្លូវពួកទាហានខ្មែរក្រហមហ្នឹង ឬពួកកម្មាភិបាលខ្មែរក្រហមហ្នឹងមានដកហូតទ្រព្យសម្បត្តិអីជារបស់ទ្រព្យផ្ទាល់ខ្លួនរបស់លោកស្រីទេ?

**ឆ៖** ចេញទៅពីចំការដូងរាងឆ្ងាយបន្តិចហើយ ប៉ុន្តែខ្ញុំអត់ដឹងថា ភូមិអី ឃុំអី ព្រោះប៉ែកខាងហ្នឹងខ្ញុំអត់ដែរទៅទេ។ ទៅដល់កន្លែងហ្នឹង ឃើញគេដាក់បារ៉ាសមួយ ហើយបារ៉ាសហ្នឹងដាក់នៅទទឹងផ្លូវហ្នឹងឯង ហើយគេចាប់ផ្ដើមឆែក។ គេប្រាប់ថា "ពួកសក្តិភូមិត្រូវទម្លាក់អីវ៉ាន់មកឲ្យអស់ អង្គការស្នើយើងអត់ត្រូវការយកទេ ខោអាវស្អី ហូលផាមួងអី មាសប្រាក់អីហ្នឹងមិនចាំបាច់យកទៅទេ ត្រូវទុកនៅហ្នឹងទាំងអស់។ អង្គការស្នើហើយ បើសិនជាយើងមានសម្ភារៈទាំងអស់នោះ គេហៅយើងថា ជាពួកសក្តិភូមិ ចាស។ ហើយបើនៅតែមិនព្រមទម្លាក់ស្នើឲ្យគេទៀត គេថាយើងហ្នឹងក្បត់អង្គការ"។ ហើយពេលនោះគេឆែកយកអស់ហើយ ក្រុមគ្រួសារនាងខ្ញុំ បានដាក់ខោអាវ ដាក់អីទៅខ្លះដែរ ប៉ុន្តែគេដកយកអស់។ សូម្បីតែថ្នាំពេទ្យមួយកំប៉ុងដែលខ្ញុំលាក់ទុក ព្រោះប្ដីខ្ញុំគាត់ធ្វើការនៅកន្លែងឃ្លាំងថ្នាំ លាក់ទុកហ្នឹង

គេឃើញ គេដកយកទៅទៀត គេថាអាហ្នឹងរបស់ពួកក្បត់។ អាថ្នាំហ្នឹងក្បត់ជាតិពេញធឹងតែម្ដង យកអត់បានទេ។ យកទៅធ្វើអី ប្រើប្រាស់អី។ ដកទាំងអស់។ ខ្ញុំលាក់បានមួយគ្រាប់គត់មួរនឹងដៃអាវ។ នឹកឃើញថា ក្រែងលោឈឺថ្នើរណាអីបានលេបទៅ លួចមួយគ្រាប់មួរនឹងដៃអាវ គេអត់បានទម្លាក់ដៃអាវទៀត។

[១០:០៨:៤៣]

បើសិនគេទម្លាក់ដៃអាវ ដឹងថាយើងលាក់ទុកហ្នឹង ប្រហែលជាគេបាញ់ចោលតាំងពីថ្ងៃហ្នឹងបាត់ចាស។ អ៊ីចឹងគេដកយកអស់ហើយ។ ដកហួល ដកផាមួង ដកៗមាសទៀត ចាស មាសយើងហ្នឹង គេថាអាហ្នឹង របស់ហ្នឹងគេអត់ប្រើទេ។ ប្រគល់ឲ្យអង្គការទាំងអស់ ចាស។

**ស៖** នៅពេលដែលលោកស្រីធ្វើដំណើរបន្តទៅមុខទៀត តើលោកស្រីត្រូវប្រើពេលប៉ុន្មានថ្ងៃ ទើបទៅដល់ទិសដៅដែលលោកស្រីស្នាក់នៅ? នៅដល់ភូមិត្រប់ លោកស្រី?

**ឆ៖** ចន្លោះពេលចេញពីចំការដូងទៅហ្នឹង នាងខ្ញុំអត់ដឹងថា ប៉ុន្មានថ្ងៃទេ ប៉ុន្តែក្រោយពីដកស្បៀង -- ដកថ្នាំ ដកសម្ភារៈ ដកអីយើងប្រើប្រាស់អស់ហើយ ចេញទៅហួសហ្នឹងប្រហែលជា១គីឡូទៀត គេប្រកាសថា "លុយឈប់ចាយហើយ"។ ចាស អ៊ីចឹងនៅពេលនុ៎ង មុនដំបូងយើងសង្ឃឹមថា យកអីយកចុះ សល់លុយ ចាស។ ស្រាប់តែដល់មួយចំណុចទៀត គេថាលុយឈប់ចាយ។ អ្នកដែលមានហ្នឹង គាត់ដាក់លុយទាំងកាបូបទៅ គាត់សន្ធប់ជាមួយនឹងអាកាបូបលុយគាត់ហ្នឹងឯង។

[១០:១០:០៥]

ហើយក្រុមគ្រួសារខ្ញុំមានប៉ុន្មាន មានតែម្នាក់ប្អូនដប់សន្លឹកហ្នឹង។ គេថា លុយឈប់ចាយ គេឲ្យយើងទម្លាក់លុយទាំងអស់។ គេយកទៅប្រមូលដុតចោល។ នៅពេលហ្នឹង បានពួកក្រុមគ្រួសារខ្ញុំ ហើយនិងប្រជាជនដទៃទៀត គិតថា "តែប៉ុណ្ណេះងាប់ហើយ" អស់រលីងហើយ សង្ឃឹមថា បានលុយនេះ ទៅទិញអីហូបនៅមុខទៀត។ ឥឡូវ លុយគេដុតចោលអស់ទៀត សង្ឃឹមអីទៀត ចាស។ អ៊ីចឹង នៅកន្លែងនុ៎ង ដែលពួកយើងគិតថា ពួកយើងនឹងជួបនូវផលវិបាកទៅមុខទៀតជាច្រើន ដែលយើងមិនអាចស្មានដល់ ប៉ុន្តែអានេះជាការគិតឃើញទេ នៅពេលដែលគេដកអស់។ ហើយទៅដល់ភូមិត្រប់ហ្នឹង នាងខ្ញុំក៏អត់ដឹងថា ចន្លោះពេលហ្នឹងប៉ុន្មានថ្ងៃទេ ដែលដើរទៅហ្នឹង ចាស។

**ស៖** អរគុណលោកស្រី។ តើពេលដែលលោកស្រីចេញពីចំការដូងរហូតទៅដល់ភូមិត្រប់ហ្នឹង តើលោកស្រីបានជួបជុំគ្រួសារវិញទេ? ជួបប្ដី? ជួបឪពុកអីវិញទេ?

**ផ៖** ចាស ឪពុក និងប្ដី នាងខ្ញុំបានជួបឯចំការដូងឯណោះ ហើយនៅពេលដែលជួបជុំគ្នាហើយ យើងបានធ្វើដំណើរទាំងអស់គ្នា តាមការចង្អុលបង្ហាញរបស់អង្គការហ្នឹងទៅតាមទិសដៅដែលគេកំណត់ រហូតទៅដល់ភូមិព្រៃត្រប់ហ្នឹង ចាស។

**សៈ** តើទៅដល់ភូមិព្រៃត្រប់ហ្នឹង ចម្ងាយប្រហែលជាប៉ុន្មានគីឡូម៉ែត្រពីភ្នំពេញ? ហើយពេលដែលលោកស្រីទៅដល់ តើកម្មាភិបាលនៅព្រៃត្រប់ហ្នឹង សហករណ៍ខ្មែរក្រហមហ្នឹងដែលនៅព្រៃត្រប់ហ្នឹង តើគេទទួលរាក់ទាក់លោកស្រីដែលជាអ្នកជម្លៀសពីភ្នំពេញទេ?

[១០:១២:០៥]

**ផ៖** ចាស នៅមេសហករណ៍នៅព្រៃត្រប់ហ្នឹង ពេលដែលយើងទៅដល់ អ្នកជម្លៀសថ្មីហ្នឹង គេអត់ថាអីទេ នៅពេលហ្នឹង។ គេទៅដល់ គេរៀបក្រុមឱ្យហើយ គេឱ្យយើងទៅនៅតាមផ្ទះមូលដ្ឋានចាស់ មាន១ល្ហបគេ មានមេកងគេដឹកនាំថា ឥឡូវប៉ុន្មានក្រុម ប៉ុន្មាននាក់ ត្រូវទៅនៅជាមួយអ្នកនេះ នៅជាមួយអ្នកនោះ គេរៀបចំបំបែកហើយ នៅទីនុំង ចាស។ ហើយយើងអត់ដឹងថា គណៈសហករណ៍ហ្នឹង ឈ្មោះអីទេ ព្រោះទើបតែទៅដល់។

**សៈ** តើការដែលលោកស្រីចូលទៅភូមិព្រៃត្រប់ហ្នឹង លោកស្រីចូលទៅដោយលោកស្រីចូលដោយចិត្តឯង? ឬមួយក៏ខាងទាហានខ្មែរក្រហមគេតម្រង់ទិស ឬគេកំណត់ទិសដៅឱ្យលោកស្រី?

**ផ៖** ទាហានខ្មែរក្រហមជាកំណត់ទិសដៅឱ្យ។ ពួកយើងទាំងអស់គ្នាជាអ្នកជម្លៀសនេះ អត់ដឹងថា ទៅណា មកណាអីទាំងអស់។ ប៉ុន្តែទាហានខ្មែរក្រហមគេប្រាប់ថា "ហ្នឹង ភូមិព្រៃត្រប់។ មិត្តឯងទាំងអស់គ្នា ស្នាក់នៅហ្នឹងសិនទៅ ចាំអង្គការគេរៀបចំកន្លែងហើយ គេនឹងឱ្យទៅទៀតហើយ ប៉ុន្តែឥឡូវនេះ មួយដំណាក់នេះ ស្នាក់នៅនឹងព្រៃត្រប់ហ្នឹងសិនទៅ"។ ចាស មិនមែនពួកយើងចង់ទៅទេ ពួកយើងអត់ស្គាល់សោះ។ ប៉ុន្តែគេកំណត់ឱ្យនៅហ្នឹង ត្រូវតែនៅហ្នឹង អត់មានសិទ្ធិប្រឆាំងទេ អស់ហើយសិទ្ធិ។ អត់មានសល់អីបន្តិចទេ។

[១០:១៣:៤៩]

**សៈ** ខ្ញុំចង់ឱ្យលោកស្រីបញ្ជាក់ដែលថា នៅពេលដែលលោកស្រីឆ្លងកាត់ពីភ្នំពេញ ទៅដល់ភូមិព្រៃត្រប់ហ្នឹង លោកស្រីប្រហែលជាបានជួបប្រទះនៅតាមវត្តណា មានវត្តនៅតាមផ្លូវហ្នឹង ដូច្នេះលោកស្រីមានឃើញព្រះសង្ឃអីទេ នៅក្នុងវត្តអារាម ដែលនៅតាមផ្លូវដែលលោកស្រីធ្វើដំណើរ?

**ផ៖** ចាសនៅតាមផ្លូវដែលនាងខ្ញុំធ្វើដំណើរ ព្រះសង្ឃមួយអង្គអត់ឃើញទេ។ ក្នុងវត្តស្ងាត់ជ្រាប

អត់ដឹងលោកនិមន្តទៅណាអស់ទេ។ ស្ងាត់អស់រលីង។ បងប្អូនយើងតាមផ្លូវឆ្លល់ដែរហ្នឹងណ៎ា ដូចថា ពេលដែលខ្ញុំកូនស្លាប់ ខ្ញុំគិតថាបើសិនជាឃើញព្រះសង្ឃមួយ និមន្តព្រះអង្គសូត្រធម៌ឲ្យហើយ ប៉ុន្តែអត់ឃើញសោះ ក្នុងវត្តក៏ស្ងាត់ តាមផ្លូវក៏ស្ងាត់។ អត់ដឹងលោកនិមន្តទៅណាអស់ អត់ឃើញទេ។

**ស៖** នៅក្នុងវត្តហ្នឹង លោកស្រីតើមានប្រជាជនដែលជម្លៀសទៅស្នាក់នៅក្នុងវត្តហ្នឹងទេ ពេលដែលវត្តអត់មានលោកហ្នឹង តើមានប្រជាជនដែលជម្លៀសពីភ្នំពេញហ្នឹង ទៅស្នាក់នៅទីនោះច្រើនទេ?

**ផ៖** ចាស នៅតាមវត្តដែលនៅតាមដងផ្លូវដែលយើងជម្លៀសហ្នឹងមាន មិនអត់ទេប្រជាជន ព្រោះដើរអ៊ីចឹងទៅដល់ពេលត្រូវសម្រាកមានវត្ត នាំគ្នាចូលសម្រាកក្នុងវត្ត ប៉ុន្តែយើងអត់អាចចេញផុតពីផ្លូវដែលគេកំណត់ឲ្យដើរ និងវត្តដែលនៅក្បែរហ្នឹងទេ។ សូម្បីតែពួកយើងចូលទៅស្នាក់នៅតាមវត្តហើយក៏មានទាហានទៅយាមកាមតាមវត្តដែរចាស។

**ស៖** ពេលទៅដល់ -- ពេលលោកស្រីទៅដល់ភូមិព្រៃត្រប់ តើពេលលោកស្រីទៅដល់ភ្លាម លោកស្រីបានបញ្ជាក់ហើយថា គេយកលោកស្រីយកទៅផ្ញើអ្នកមូលដ្ឋាន។ ពេលដែលលោកស្រីទៅដល់ភូមិហ្នឹង តើគេមានចុះមកស្រង់ស្ថិតិ ឬធ្វើជំរឿន សួរពីការងារ សួរពីមុខរបររកស៊ីរបស់លោកស្រីនៅភ្នំពេញទេ?

[១០:១៥:៥២]

**ផ៖** ចាស ទៅដល់ភូមិព្រៃត្រប់ហ្នឹងបានប្រហែលជា ខ្ញុំថាមួយអាទិត្យចុះ ចាស ព្រោះអត់ៗបានកំណត់ថ្ងៃចាំទេ ប៉ុន្តែដឹងតែមានកិច្ចប្រជុំមួយ។ ហើយក្នុងការប្រជុំនោះគេហៅអ្នក១៧ទាំងអស់ដែលយកទៅផ្ញើតាមផ្ទះមូលដ្ឋានហ្នឹងឲ្យទៅចូលរួមប្រជុំ។ នៅពេលប្រជុំហ្នឹងគេបានសួរថា “មានបងប្អូនណាដែលធ្វើទាហាន ធ្វើការនៅភ្នំពេញ រៀនសិស្សអីបរិញ្ញាអីឯណា និស្សិតបញ្ញវន្តអីមានអត់?” គេហៅសួរ។ គេសួរទាំងអស់។ ហើយអ៊ីចឹងអ្នកណាដែលធ្វើការអ៊ីចឹង គាត់ដាក់ថាធ្វើការទៅ។ នៅតាមផ្លូវហ្នឹងគេប្រមូលអស់ម្តងហើយ អ្នកធ្វើការហ្នឹង ប៉ុន្តែមានអ្នកខ្លះទៅមុខទៀតអត់បានចូលកន្លែងហ្នឹង ទៅដល់កន្លែងហ្នឹងគេហៅសួរម្តងទៀត។ នៅពេលដែលសួរនុ៎ង ឪពុកនាងខ្ញុំគាត់មានជំងឺគាត់អត់បានទៅឆ្លើយជាមួយគេទេ។ ប៉ុន្តែក្រុមគ្រួសារខ្ញុំនេះក៏អត់សារភាពប្រាប់គេថាយើងធ្វើអីដែរ គេហៅសួរទៅគេឃើញសៗ គេថា “យួនអ្អី? ចិនអ្អី?” ថាអត់ទេ “ខ្ញុំខ្មែរ ខ្ញុំនិយាយខ្មែរច្បាស់” “ហើយគេធ្វើអី?” គេសួរយើងធ្វើអី “ខ្ញុំលក់ដូរ រកស៊ី”។ ហើយអ្នកខ្លះទៅប្រាប់ថា “ធ្វើការនៅមហាផ្ទៃ នៅអីណា ពេទ្យនៅទាហាន នៅកងទ័ពអ៊ីចឹងទៅ”។ ហើយជាពិសេសអ៊ំបង្កើតរបស់ខ្ញុំ គាត់អត់ធ្វើទាហានទេ។ អ៊ំខ្ញុំហ្នឹង

គាត់ធ្វើការនៅក្នុងវាំង ប៉ុន្តែគាត់មានកូនធម៌គាត់មួយជាទាហានម៉ាយហ្វក ទៅជាមួយគ្នាដែរ។ ដល់ពេលគាត់ថា បើគាត់ថា "អ្អឺក មីនាងអ្ហា! អញទៅប្រាប់គេថា អញមិនប្រាប់គេថាអញធ្វើការក្នុងវាំងទេវើយ អញថាអញធ្វើទាហានជាមួយអាកូនធម៌អញហើយ បានទៅជាមួយវា"។ ខ្ញុំគិតថា "អ៊ំឯងប្រយ័ត្នគេឲ្យទៅបាញ់ អ៊ំឯងអត់ចេះបាញ់ណា៎"។ "ហ៊ឺ! ទៅជាមួយអាកូនធម៌អញវាបង្រៀនតែប៉ុន្មានថ្ងៃចេះហើយ"។ អ៊ីចឹងទៅគាត់នាំទៅ -- គាត់ទៅជាមួយកូនធម៌គាត់ ទាហានម៉ាយហ្វកហ្នឹង ទៅប្រាប់គេថា "គាត់ហ្នឹងធ្វើទាហាននៅកងពលលេខប៉ុន្មានអីណា តាមអាកូនធម៌គាត់ហ្នឹង" ហើយកូនធម៌គាត់ហ្នឹងក៏ប្រាប់គេតាមហ្នឹងដែរទៅ។ ចាស ដល់ពេលអ៊ីចឹងដោយទាំងប្អូនជីដូនមួយខ្ញុំទៀត វាទើបអាយុបានបួន-ប្រាំដណ្ដប់ឆ្នាំហ្នឹង តែត្រូវជាកូនអ៊ំខ្ញុំហ្នឹង។

[១០:១៨:២០]

ដល់ពេលអ៊ំខ្ញុំទាហាន កូនហ្នឹងក៏គេចុះឈ្មោះឲ្យនៅជាមួយឪហ្នឹងដែរ។ គេសួរថា "យកកូនទៅអត់?" "យក អត់ទុកទេ ខ្ញុំទៅហើយទុកកូនធ្វើអី"។ ចាស ហើយក្នុងពេលនោះគ្រាន់តែអ្នកចុះឈ្មោះពេលដែលចុះហ្នឹងខ្ញុំអត់ដឹងថាប៉ុន្មានទេ តែមិនមែនមកតែពីភូមិព្រៃត្រប់មួយទេ។ ខ្ញុំអត់ដឹងគេហៅពីខាងណាខ្លះទៀតទេ។ ប៉ុន្តែនៅៗពេលដែលចុះឈ្មោះហើយហ្នឹង ខ្ញុំឮមេកងគេអាអ្នកដែលគេកត់ឈ្មោះហ្នឹងគេថា "អ្ហឺស! ៣ថ្ងៃ គ្រាន់តែកត់ឈ្មោះហ្នឹង ៣ថ្ងៃហើយ។ ឥឡូវ បាន ៦០នាក់ហើយ គេប្រាប់គ្នាគេអ៊ីចឹង"។ ហើយដោយសារអត់មានអ្នកណាមកចុះឈ្មោះទៀត គេក៏បញ្ឈប់នៃការចុះឈ្មោះហ្នឹងទៅ។

**ស៖** ហើយតើលោកស្រីដឹងទេថា អ្នកដែលកត់ឈ្មោះចំនួន ៦០នាក់ហ្នឹងគេយកទៅណាទៀត?

**ឆ៖** អ្នកដែលកត់ឈ្មោះចំនួន ៦០នាក់ហ្នឹង ពេលដែលកត់ឈ្មោះហើយគេប្រាប់ថា "ស្នាក់នៅហ្នឹងហើយកុំទៅណាអី ចាំគេយកឡានមកដឹក មកធ្វើការនៅភ្នំពេញ។ អ្នកណានៅធ្វើការកន្លែងណាចូលកន្លែងហ្នឹងវិញទៅ"។ ចាស អ៊ីចឹងពួកគាត់រង់ចាំមែន គាត់អត់ទៅណាទេ។ ហើយគេអត់មានចាប់ចង អត់មានអីទាំងអស់ គេឲ្យនៅធម្មតា។ ចិត្តសាស្ត្រស្អាត នៅធម្មតា អត់មានធ្វើអីទេ។ អត់មានបំភ័យ បង្អើលអីទាំងអស់។ ដល់ពេល ២ថ្ងៃក្រោយមក យើងឃើញអាឡានដំរីទឹកហ្នឹងបើកចូលទៅក្នុងភូមិហ្នឹងហើយ។ ទៅដល់គេពិបាកដើរហៅ គេលើកអាមីក្រូដៃហ្នឹងដាក់លើក្បាលឡាន គេប្រកាស។ ពួកខ្ញុំអនឹងគេដែរ ស្មានគេដើរហៅ ខំរត់មកនឹងគេដែរហ្នឹង មកមើលឡានហ្នឹង ព្រោះនឹកផ្ទះសឹងអីហើយហ្នឹង។

[១០:២០:០៨]

ស្រាប់មកដល់គេប្រកាសថា "អត់ទេអ្នកដែលអត់មានឈ្មោះអត់យកទេ យកតែអ្នកមានឈ្មោះ។ ឥឡូវអ្នកមានឈ្មោះឡើងឡានមកទៅភ្នំពេញវិញ ព្រោះរៀបចំហើយហើយ ស្អាតបាតអស់ហើយ។ អីចឹងកន្លែងធ្វើការអីមានត្រឹមត្រូវទាំងអស់ហើយ។ បងប្អូននាំគ្នាឡើងឡានមកទៅវិញ"។ អីចឹងគេហៅឈ្មោះហើយ ឈ្មោះដែលគេកត់ហ្នឹងគេហៅ ហៅឡើងៗ។ ចាស ឡើងអីចឹងទៅ គេដឹកៗទៅហើយ។ គេដឹកចេញទៅ អត់ដឹងយកទៅឯណាទេ។ ដឹកទៅបាត់មួយសន្ទុះ ឃើញមានឡានមកមួយទៀត ព្រោះមួយឡានហ្នឹងដាក់អត់អស់ទេ៦០។ ចាស មានឡានចូលមកមួយទៀត គេហៅឈ្មោះត ឡើងទៀត។ តឡើងទៀត ក៏ដឹកចេញយកទៅទៀត។ ប៉ុន្តែសយនឹងក្រុមគ្រួសារខ្ញុំនោះ កុំអីក្រុមគ្រួសារខ្ញុំក៏អត់បានត្រូវជាប់ដែរ។ ប៉ុន្តែដោយលោកពុកខ្ញុំនេះ គាត់អត់ចោលអាតេអូ អារ៉ាដ្យូអីហ្នឹង គាត់អត់ចោលទេ គាត់នៅតែ សេ.អ៊ិ.អា គាត់ស្តាប់ព័ត៌មាន អង្គរគាត់ម៉េចក៏អត់ស្តាប់ដែរ ឲ្យតែយប់ឡើងគាត់លួចបើកហើយ។ ដល់ប្រហែលជាគេស៊ើបដឹង ដល់ហើយគេមកប្រមូលក្រុមគ្រួសារខ្ញុំទាំងអស់ មានប៉ុន្មាននាក់ទាំងអស់យកទាំងអស់។ "គ្រួសារអ៊ីឯងអត់បានចុះឈ្មោះទេ តែអ៊ីឯងហ្នឹងឡើងឡាំប្រើតាអ៊ីឯងទៅ ហើយបើកៗទៅតាមក្រោយឡានខ្ញុំទៅ!"។ ដល់ពេលនេះ ឡាំប្រើតាប៉ាខ្ញុំមានសាំងឯណា អត់មានទេ។ ដល់ពេល -- គេចាក់ឲ្យកន្លះលីត្រ គេបូមសាំងពីអាដំរីទឹកគេហ្នឹង ចាក់ឲ្យកន្លះលីត្រ។ គេថា "អ៊ីឯងនាំក្រុមគ្រួសារហ្នឹងឡើងទៅតាមគេទៅ បើគេដល់ភ្នំពេញថ្ងៃហ្នឹង អ៊ីឯងស្អែកអីដល់ហើយ។ ទៅរ៉ិៗតាមគេអីចឹងទៅ! ខ្ញុំទៅផ្លូវណា អ៊ីឯងទៅផ្លូវហ្នឹងទៅ!" ក្រុមគ្រួសារខ្ញុំពេលហ្នឹងក៏អត់ដឹងថា គេយកទៅណាដែរ។ នាំគ្នាហៅកូន ហៅចៅមានប៉ុន្មានដាក់ទាំងអស់។ ចាស ដល់ពេលបើកចេញតាមគេអីចឹងមក បានប្រហែលពាក់កណ្តាលផ្លូវ អាឡាំប្រើតាហ្នឹងវាស៊ីសាំង ឡាំប្រើតាចាស់ហើយនោះ អស់អាសាំងហ្នឹងទៅ។ ដល់ពេលសាំងហ្នឹងអស់ នាំៗគ្នានៅអង្គុយរញ្ជង់លើឡាំប្រើតាហ្នឹងឯង អត់ទៅណាទេ។ ស្រាប់តែឃើញអាឡានដែលដឹកទៅហ្នឹងវាបកមកវិញ។ វាឈប់ វាសួរថា "ចុះមិត្តឯងនៅធ្វើអីក៏មិនទៅ?" ថា "អ្ហឺ! អស់សាំងហើយមិត្តអើយ!" "អ៎! អីចឹងចាំហ្នឹងហើយ។ នៅសល់បីគ្រួសារទៀតនៅក្នុងភូមិ –ចាំគេទៅដឹកបីហ្នឹង អាហ្នឹងមេឃជិតល្ងាចហើយ ម៉ោងប្រាំជាងហើយ– ចាំគេទៅដឹកបីហ្នឹង មកវិញខ្ញុំសណ្តោងឡាំប្រើតាមិត្តឯងហ្នឹងយកទៅដែរ"។ នាំគ្នានៅចាំគេហ្នឹងទៅ។ ចាំគេសណ្តោង។

[១០:២២:៣៥]

តែគុណាបុណ្យអី កំពុងចាំៗ លេងឃើញតូម្នាក់ អត់ដឹងគាត់មកពីណាទេ ប្រហែលជាមូលដ្ឋានហើយ។ គាត់បរទេះគោមកពីណា គាត់ឃើញនាំគ្នានៅអីចឹង គាត់សួរ "ហើយបងឯងទាំងអស់គ្នាហ្នឹង

ចាំអី?" "អ្ហ៎! ចាំឡាន គេទៅភូមិណ៎ា គេទៅដឹកបីគ្រួសារទៀត គេយកពួកខ្ញុំទៅភ្នំពេញវិញ"។ តាហ្នឹង គាត់មើលលិចមើលកើត គាត់ខ្សឹបប្រាប់ប៉ាខ្ញុំ គាត់ថា "នាំគ្នារត់ទៅ! នៅចាំអីទៀតគេយកទៅវ៉ៃចោលអស់ហើយ អាប៉ុន្មានឡានមិញហ្នឹងនោះ។ គ្មានអ្នកណាយកទៅភ្នំពេញទេ ឆាប់រត់ទៅ!" ដល់ពេលអ៊ីចឹង គាត់ឱ្យនំអាកោ ៗ គាត់មាននំអាកោអាដូចយើងដាក់ក្នុងចានចង្កឹះអ៊ីចឹង ប៉ុនៗនេះ។ គាត់ឱ្យនំអាកោបួនប្រាំ គាត់ថា "នាំគ្នាយក ហើយរត់ទៅ!"។ លោកពុកខ្ញុំគាត់ថា "អត់ដឹងរត់ទៅណាទេ"។ អត់ដឹងទៅខាងណា អត់ស្គាល់ទិសតំបន់ទាំងអស់។ អ៊ីចឹងគេក៏ប្រាប់ថា "នេះអ៊ំឯងទៅតាមផ្លូវហ្នឹង ទៅតែតាមផ្លូវហ្នឹងទៅ កុំបែកពីផ្លូវហ្នឹងឱ្យសោះ មានព្រៃកាត់ព្រៃ មានអីកាត់ហ្នឹង ទៅៗអត់មានទ័ពអត់មានអីនៅតាមហ្នឹងទេ ទៅចុះ"។ អ៊ីចឹងដល់ខ្ញុំអ៊ីចឹង ក្រុមគ្រួសារខ្ញុំភ័យ លើកជីដូន លើកចៅ អីវ៉ាន់អីទម្លាក់ចោលនៅហ្នឹង យកតែបន្តិចៗតាមខ្លួន រត់តាមការចង្អុលរបស់តាម្នាក់ហ្នឹង ដើម្បីកុំឱ្យគេយកទៅសម្លាប់។ ចុះបើគេប្រាប់ថា អាទៅប៉ុន្មានមិញហ្នឹងស្លាប់អស់ហើយ។ នៅចាំអីទៀត។ ចាស ពួកខ្ញុំរត់រត់ចេញមកអ៊ីចឹងមក។

[១០:២៣:៥៨]

នៅពេលដែលក្រុមគ្រួសារខ្ញុំរត់ រត់មករហូតដល់ជិតពាក់កណ្ដាលអាធ្រាត្រហើយ ចាស ផ្លាយទៅជួបបឹងមួយ។ តែពួកខ្ញុំអត់ស្គាល់ថាបឹងអីទេ។ ទៅដល់បឹងហ្នឹងមួយ ឪពុកខ្ញុំគាត់ថា យើងឆ្លងបឹងអត់រួចទេទឹកជ្រៅណាស់ ហើយប្អូនៗតូចៗទៀត យាយចាស់ទៀត។ អ៊ីចឹងឥឡូវកូនឯងត្រូវនៅខាងនេះសិន យកប្ដីខ្ញុំហ្នឹង ហើយគាត់ ហើយម៉ែខ្ញុំអីហ្នឹង បងស្រីខ្ញុំហ្នឹងចម្លងកូនគាត់។ កូនគាត់ពីរតូចៗទៀត។ ចាស ចម្លងគ្នាទៅខាងនោះ--

**ស៖** សូមទោសលោកស្រី សូមលោកស្រីនិយាយយឺតៗបន្តិចណ៎ា! ចាស ខ្លាចអ្នកបកប្រែបកប្រែមិនទាន់។

**ផ៖** ចាស នៅពេលដែលទៅដល់បឹងអ្នកតាប្រាំរយហ្នឹង ក្រុមគ្រួសាររបស់ខ្ញុំអត់មានលទ្ធភាពនឹងឆ្លងបឹងហ្នឹងទេ ដូច្នេះ ត្រូវបណ្ដាក់គ្នាឆ្លង។ លោកពុកខ្ញុំជិះកប្អូនមួយ អៀវអាមួយពីក្រោយទៀត បងស្រីខ្ញុំលីកូនវាមួយ ប្ដីខ្ញុំជួយលីក្មួយប្រុសមួយ។ ហើយអ៊ីចឹងអ្នកដែលដើររួច គេដើរទៅ។ ចំណែកខ្ញុំខ្ញុំអត់ប៉ានចុះទឹកទេ តាំងពីកើតពីពោះម៉ែមួយដល់ប៉ុននេះ បើថាចុះទឹក គឺងាប់បណ្ដោយ មិនបាច់អ្នកណាសម្លាប់ទេ អត់ប៉ានចុះទេ។ អ៊ីចឹងខ្ញុំនៅចាំជាមួយជីដូននៅមាត់បឹង ឱ្យប្ដីចុះទៅសិនចាំមកយកវិញ។ ពេលនោះ ពេលដែលប្ដីខ្ញុំ ឪពុកខ្ញុំអត់ទាន់ចុះផង ស្រាប់តែយើងឃើញភ្លើងពិល ៗឆ្វេចឆ្វាចនៅ

ក្នុងព្រៃ ចុះយប់ហើយឃើញភ្លើងពិល។ ហើយឮមាត់គេស្រែកថាអ៊ីចេះ “មាត់បឹងហ្នឹង មានមនុស្សហើយ មាត់បឹងហ្នឹងមានអ្នករត់ហើយ។ ពួកយើងឆាប់ទៅឲ្យលឿន ហើយពួកហ្នឹងក៏បាញ់ផេសផូសៗ”។ ភ្លើងពិលសំដៅមក នៅពេលដែលភ្លើងពិលសំដៅមក ឪពុកខ្ញុំ ប្ដីខ្ញុំអីហ្នឹង គាត់ថានៅអត់បានទេ ប៉ាដើរទៅមុនហើយ កូនឯងធ្វើម៉េចយកយាយទៅលាក់ត្រង់ណា លាក់សិនទៅ។

[១០:២៦:០៣]

ពេលនោះប្ដីខ្ញុំក៏អត់ដាច់ចិត្តទេ។ គាត់ដាក់អាក្អួយខ្ញុំចុះសិន គាត់មកយកខ្ញុំទៅញាត់នៅក្នុងគុម្ពោតព្រៃល្អាក់មួយ។ ហើយនៅពេលដែលគេបាញ់ផូសផេសហ្នឹង ជីដូនខ្ញុំ គាត់ភ័យស្លុតពេកគាត់ចាស់ហើយ គាត់អាយុ៧០ជាងហើយ គាត់ភ័យស្លុតពេក គាត់ដាច់ខ្យល់ស្លាប់បាត់ទៅហើយ។ ប៉ុន្តែមិនអាចទុកគាត់នៅនឹងវាលបានទេ។ បើទុកនៅនឹងវាល គេមកឃើញ។ អ៊ីចឹងប្ដីខ្ញុំហ្នឹង អូសយាយខ្ញុំហ្នឹងទៅជាមួយខ្ញុំ យកទៅញាត់ក្នុងគុម្ពោតហ្នឹង ហើយឲ្យខ្ញុំចាំនៅហ្នឹងហើយ គាត់នាំគ្នាឆ្លងទៅ។

នៅពេលដែលពួកគេបាញ់ផូសផស អ្នកចុះទឹក ចុះទៅ ខ្ញុំគិតថា គ្រួសារខ្ញុំស្លាប់អស់ហើយ។ អ៊ីចឹងពេលហ្នឹង ដោយភ័យពេក ខ្ញុំក៏សន្លប់នៅជាមួយសពយាយខ្ញុំអ៊ីចឹងទៅ។ ខ្ញុំអត់ដឹងថា អ្នកណាបាញ់អ្នកណា អ្នកណាអីអ្នកណាទេ។ ចាស នៅពេលដែលខ្ញុំសន្លប់បាត់រហូតដល់យប់ជ្រៅម៉ោងប្រហែលជារំលងពីរអធ្រាត្រ។ ខ្ញុំដឹងខ្លួននៅពេលសន្សើមធ្លាក់ចុះ ពេលនោះប្ដីខ្ញុំត្រឡប់មកវិញ ហើយគាត់ប្រាប់ថាម៉ែខ្ញុំ ប៉ាខ្ញុំ កូនបងប្អូនខ្ញុំអីឆ្លងផុតអស់ហើយ។ ឥឡូវយើងអត់អាចឆ្លងបានទេ បើសិនជាយើងសម្រេចចិត្តថាឆ្លងទៀត យើងនឹងស្លាប់។ ដូច្នេះត្រូវតែបកក្រោយវិញ។

[១០:២៧:២០]

ក្នុងចន្លោះពេលនោះ សពជីដូនខ្ញុំស្លាប់ទាំងអាណោចអធ័មញាត់ចូលទៅក្នុងព្រៃល្អាក់។ ហើយខ្ញុំនិងប្ដីខ្ញុំត្រូវធ្វើដំណើរត្រឡប់ថយក្រោយវិញ ដោយកាត់តាមព្រៃរហូតចាស។

**ស៖** សូមអរគុណលោកស្រី។ ហើយក្រោយដែលពេលចាកចេញពីសពជីដូនលោកស្រីហើយ លោកស្រីតម្រង់ទៅទិសណា? ហើយលោកស្រីសូមនិយាយបំព្រួញបន្តិច ចាស?

**ឆ៖** នៅពេលដែលពួកខ្ញុំចាកចេញពីសាកសពយាយខ្ញុំមកវិញ យើងដើរបានតែពេលយប់ទេ ពេលថ្ងៃអត់ប៉ានដើរទេ។ ដើរពេលយប់ ដើរយប់ហ្នឹងរយៈពេល៧ថ្ងៃ ដៃជើងខ្ញុំមុតសុះដោយបន្លាដោយសារយើងដើរកាត់ព្រៃ។ ហើយមុខសញ្ញារបស់ខ្ញុំហ្នឹង គឺទៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ ព្រោះស្រុកនោះជាស្រុកឪពុកក្មេករបស់ខ្ញុំ។ អ៊ីចឹងយើងអត់ដឹងទៅខាងណាទេ មានតែទៅកន្លែងហ្នឹងហើយ ព្រោះឪពុក

ក្មេកខ្ញុំគាត់ជាមូលដ្ឋានចាស់។ អ៊ីចឹងយើងពឹងថា ទៅដល់ឪពុកច្បាស់ជាបានសុខ។ ដូច្នេះទាំងថ្ងៃ ទាំងយប់រយៈពេល៧យប់ ដោយដើរកាត់ក្នុងព្រៃ បេះតែស្លឹកឈើហូប អត់មានអីហូបទេ។ ផឹកទឹកដងអូរ ហូបស្លឹកឈើ បើមានផ្លែឈើអីក៏ហូបទៅ ហើយនាំគ្នាដើរយប់ថ្ងៃលួចពួនក្នុងព្រៃ យប់ឡើងដើររហូតមកដល់ស្រុកគង -- ភូមិព្រៃក្រឡាញ់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

[១០:២៩:00]

មកដល់ទីនោះ ប្ដីខ្ញុំហ្នឹងក៏អត់ប៉ានយកខ្ញុំចេញទៅដែរ។ គាត់ឲ្យខ្ញុំពួននៅក្នុងព្រៃ ចំណែកគាត់ គាត់ទៅជួបឪពុកគាត់។ ចាស នៅបាត់មួយសន្ទុះធំ បានឃើញគាត់ត្រឡប់មកវិញ គាត់មានខោ សំពត់ខ្មៅ អាវខ្មៅ ស្បែកជើងកង់ឡានឲ្យខ្ញុំផ្លាស់។ ផ្លាស់ហើយ ឲ្យខ្ញុំយកអាក្រមាក្រហមហ្នឹងរុំមុខទុកតែភ្នែកមើលបានហើយ។ ហើយគាត់ដឹកខ្ញុំហ្នឹងទៅជួប ឪគាត់នៅនឹងផ្ទះរបស់ឪគាត់ហ្នឹងឯងចាស។

**ស៖** តើភូមិដែលលោកស្រីទៅជួបនឹងឪពុកក្មេកហ្នឹងឈ្មោះភូមិអីលោកស្រី ហើយលោកស្រីស្នាក់នៅប៉ុន្មានថ្ងៃនៅកន្លែងនុ៎ង?

**ឆ៖** ភូមិឪពុកក្មេកខ្ញុំហ្នឹង ឈ្មោះភូមិព្រៃក្រឡាញ់ ឃុំពពេល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ នាងខ្ញុំស្នាក់នៅទីនោះបានរយៈពេលតែ៥ថ្ងៃទេ។ មូលហេតុអី បានខ្ញុំថាបាន៥ថ្ងៃ? ក្នុងពេលនោះ អង្គការគេហ្នឹង គេចាប់ផ្ដើមដើររកអ្នក១៧។ គេស្រាវជ្រាវពេញភូមិ អ្នក១៧ដែលជម្លៀសចូលមកនៅហ្នឹង មានប៉ុន្មាននាក់? ឲ្យបញ្ចេញអ្នក១៧ឲ្យអស់។ ឪពុកក្មេកខ្ញុំ យកខ្ញុំទៅលាក់ដាក់ចងមុង ហូបបាយ ក៏ឲ្យនៅក្នុងមុងដែរ ព្រោះខ្លាចគេឃើញ។ ក៏ប៉ុន្តែក្នុងរយៈពេល៥ថ្ងៃហ្នឹង គាត់លាក់ខ្ញុំអត់បានទេ។ អ៊ីចឹងមកអង្វរខ្ញុំថា "កូនអើយ! ឪអស់លទ្ធភាពនឹងជួយកូនឯងហើយ។ កូនឯងទៅតាមកម្មព្រេងវាសនារបស់កូនឯងទៅ" ចាស។ អ៊ីចឹង ក្នុង៥ថ្ងៃហ្នឹង ពួកខ្ញុំក៏ត្រូវបានបង្ហាញខ្លួននៅមុខអង្គការខ្មែរក្រហម ដោយប្រាប់ថា "យើងនេះជាអ្នកជម្លៀសមកពីភ្នំពេញ ដែលបានស្នាក់នៅ" ប៉ុន្តែអត់ប្រាប់គេថា គាត់នោះ ជាឪពុកក្មេកទេ បានស្នាក់នៅផ្ទះមូលដ្ឋានឈ្មោះ ឡុង ម៉ែន អ៊ីចឹងទៅ ហើយឥឡូវបើអង្គការត្រូវការឲ្យពួកខ្ញុំទៅកន្លែងណា ពួកខ្ញុំទៅ ចាស។

[១០:៣១:១៤]

**ស៖** បន្ទាប់ពីការបញ្ជាក់របស់លោកស្រីហើយ តើពួកក្រុមខ្មែរក្រហមដែលចាប់ប្រមូលពួក១៧មេសា នោះ នាំលោកស្រីទៅកន្លែងណាទៀត លោកស្រី?

**ឆ៖** ចាស នៅពេលដែលក្រុមទាហានខ្មែរក្រហមស្រង់អ្នក១៧ មេសា បានអស់ហើយ ពួកគេរៀបចំឱ្យនៅមួយកន្លែងអ៊ីចឹងទៅ ហើយគេយកឡើងទៅភ្នំស្រូក់។ ភ្នំស្រូក់ នៅក្នុងខេត្តកំពង់ស្ពឺហ្នឹងដែរ ចាស គេប្រាប់ថា "ពួកអ្នកឯង ជាពួក១៧ អ៊ីចឹង ដើម្បីឱ្យអង្គការមានការទុកចិត្ត ត្រូវតែអ្នកឯងទាំងអស់គ្នាហ្នឹង ទៅធ្វើការលត់ដំ នៅលើភ្នំស្រូក់ ចាស នៅលើភ្នំស្រូក់ ពេលណាកសាងខ្លួនបាន លត់ដំខ្លួនបានហើយ អង្គការនឹងទទួលស្គាល់ហើយ និងឱ្យបន្តទៅធ្វើការទៀត" ចាស។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីអ្នកជំនាញដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក ហើយនិងឱ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញ នៅម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣២ នាទី ដល់ម៉ោង ១០:៥៤ នាទី)*

[១០:៥៤:៣៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សូមអញ្ជើញលោកមេធាវី អាង ឧត្ដម!

**លោក អាង ឧត្ដម៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមសាថ្មី។ សូមគោរពអង្គសវនាការទាំងមូល។ ខ្ញុំមានកត់កំណត់សម្គាល់មួយទាក់ទងនឹងសុខភាពលោក អៀង សារី នៅព្រឹកមិញនេះ ហើយតាមដែល

ខ្ញុំសង្កេតឃើញ និង*ខេសមេណេជ្ជឺ* របស់ខ្ញុំបាននៅតាមដាននៅទីនោះ។ លោក អៀង សារី សម្រាន្តលក់តាំងពីម៉ោងដប់និងដប់នាទី មកទាល់ពេលនេះមិនទាន់បានដឹង -- ក្រោកមកវិញទេ។ ហើយពេលយើងសួរគ្រូពេទ្យដែលប្រចាំការនៅទីនោះឲ្យជួយសន្និដ្ឋាន វាយតម្លៃ ថាតើលោក អៀង សារី អាចចូលរួមសវនាការបានឬអត់? គ្រូពេទ្យមិនប៊ានអះអាងថាយ៉ាងណាទេ ពីព្រោះអះអាងថាគាត់មិនមែនជា -- មានឯកទេសខាងៗសរសៃរប្រសាទ ឬខាងជំងឺផ្លូវចិត្តទេ។ អាស្រ័យដោយថាលោក អៀង សារី មិនអាចបន្តតាមដានស្តាប់សវនាការបាន សហមេធាវីលោក អៀង សារី ស្នើសុំតុលាការ ឬមួយហៅអញ្ជើញគ្រូពេទ្យមកសួរ បើមិនដូច្នេះទេយើងស្នើសុំផ្អាកសវនាការនេះរហូតដល់លោក អៀង សារី គាត់អាចដឹង អាចក្រោក និងតាមដានសវនាការនេះជាថ្មីនៅពេលណាដែលគាត់អាច យើងនឹងជូនដំណឹងមកសវនាការ -- មកអង្គជំនុំជម្រះសាលាដំបូងវិញ។ សូមអរគុណ។

[១០:៥៦:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:០០:០៩]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីឆ្លើយតបទៅនឹងការលើកឡើងរបស់មេធាវីជាតិការពារក្តីលោក អៀង សារី ដែលបានលើកឡើងអម្បាញ់មិញនេះ។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ សូមអរគុណដែលបានលើកយោបល់ឡើងលោក អាង ឧត្តម។

អង្គជំនុំជម្រះសាលាដំបូងដូចដែលលោកបានឃើញហើយ ហើយបានពិភាក្សាគ្នាអម្បាញ់មិញនេះ យើងខ្ញុំសូមលើកឡើងថា ការចាប់ផ្តើមនៅក្នុងការវាយតម្លៃទៅលើលោក អៀង សារី ជាពិសេសលើសម្បទារបស់គាត់ ក្នុងការចូលរួមក្នុងសវនាការ គឺផ្អែកទៅលើរបាយការណ៍របស់អ្នកជំនាញ។

[១១:០០:៥៨]

វាជាការចាប់អារម្មណ៍ដែលថា លោកបានលើកឡើង ថាលោក អៀង សារី កំពុងតែសម្រាន្តលក់នៅព្រឹកមិញនេះ។ យើងមានដំណោះស្រាយងាយស្រួលទេ ឲ្យមន្ត្រីគ្រប់គ្រងសំណុំរឿងនោះ គឺដាស់គាត់ឲ្យភ្ញាក់មក។ វាមិនមែនជាបញ្ហាសុខភាពរបស់គាត់នោះទេ។ អ្នកជំនាញបានបញ្ជាក់ច្បាស់

ហើយថា លោក អៀង សារី ខ្លួនឯងមិនដែលអះអាងថា ខ្លួនឯងមិនមានបញ្ហាស្មារតីមិនគ្រប់គ្រាន់នោះឡើយ។ ម្យ៉ាងវិញទៀត ការគេងលក់នោះ គឺគ្រាន់តែបង្ហាញថា គាត់មិនចាប់អារម្មណ៍នៅក្នុងការស្ដាប់សក្ខីកម្ម -- សេចក្ដីប្រកាសរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះឡើយ។

អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា គ្រូពេទ្យព្យាបាលនឹងចេញរបាយការណ៍មកឲ្យអង្គជំនុំជម្រះសាលាដំបូង ប្រសិនបើសង្កេតឃើញមានការនឿយហត់អស់កម្លាំងណាមួយខ្លាំងចំពោះលោក អៀង សារី នោះ។

លោកប្រធាន ខ្ញុំគិតថា អ្វីដែលខ្ញុំបានលើកឡើងនេះ គឺបានសង្ខេបទៅលើអ្វីដែលយើងបានពិភាក្សា និងសម្រេចគ្នារួចហើយ។ សូមអរគុណលោកប្រធាន។

[១១:០២:១០]

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីចៅក្រម។

សូមអញ្ជើញ!

**លោក អាង ឧត្តម៖**

សូមអរគុណលោកស្រីចៅក្រម ខាតវ៉ាយច៍។ យើងអត់ដឹងថា លោក អៀង សារី សម្រាន្តនេះដោយសារគាត់ចង់សម្រាន្ត ឬគាត់ងងុយ ឬដោយអាការៈសុខភាពថមថយ ដែលអាការៈថមថយខ្សោយអស់កម្លាំងនេះ វាទាញឲ្យគាត់មិនអាចស្ដាប់--

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចរួចហើយ បញ្ហាដែលលោកលើកឡើងអម្បាញ់មិញនេះ ហើយយើងយកបច្ចេកទេសនៃកិច្ចការច្បាប់វេជ្ជសាស្ត្រ និងអ្នកជំនាញធ្វើជាមូលដ្ឋាន។ យើងមិនគប្បីយក -- ប្រើប្រាស់នូវហេតុផលការយល់ដឹង ការឃើញផ្ទាល់ភ្នែករបស់យើងម្នាក់ៗ យកទៅ មកលើកដើម្បីធ្វើការអះអាងនោះទេ។ ហេតុផលគឺបើសិនជាមានការប្រែប្រួល គឺអង្គជំនុំជម្រះនឹងធ្វើជាបន្តបន្ទាប់។ ករណីដែលយើងបានធ្វើរបៀបនេះរួចហើយ គឺករណីលោកស្រី អៀង ធីរិទ្ធ គឺយើងបានធ្វើច្រើនលើកច្រើនសា ក្នុងការចាត់តាំងអ្នកជំនាញដើម្បីពិនិត្យ។ អ៊ីចឹងហើយបានជាអង្គជំនុំជម្រះបានពិនិត្យធ្វើដូច្នេះ។

**លោក អាង ឧត្តម៖**

បាទ សូមអរគុណ។ សូមអរគុណលោកប្រធាន អ៊ីចឹងដើម្បីឲ្យជ្រះស្រឡះ ដើម្បីឲ្យច្បាស់ ខ្ញុំស្នើ

សុំឱ្យតុលាការចាត់តាំងគ្រូពេទ្យពិនិត្យលោក អៀង សារី ជាបន្ទាន់។ ពីព្រោះដំណាក់កាលនេះគាត់ -- ដោយសារយើងមិនមែនអ្នកជំនាញ ខ្ញុំកត់សម្គាល់ឃើញផ្ទាល់ភ្នែក ខ្ញុំចុះទៅឃើញអ៊ីចឹង គាត់កំពុងសម្រាន្តអ៊ីចឹង។ តើយើងនឹងបន្តនីតិវិធីការដំណើរការស្ដាប់សក្ខីកម្មនេះយ៉ាងម៉េច ក្នុងខណៈពេលដែលគាត់មិនអាចចូលរួមបាន? អ៊ីចឹងមានតែកុំឱ្យការនេះរំលងហួស គួរតែអញ្ជើញលោកគ្រូពេទ្យជំនាញដែលប្រចាំការទាំងនោះមកសួរទៅ តើស្ថានភាពហ្នឹងយ៉ាងម៉េច? បើមិនធ្វើដូច្នេះទេ នឹងដំណើរការទៅរំលងគាត់អត់បានចូលរួមសវនាការ។ អានេះជាការខុសនីតិវិធីទៅហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី មានអីប្លែកទេ? បញ្ហាដដែលយើងមិនឱ្យលើកទេ ព្រោះអង្គជំនុំជម្រះបានសម្រេចរួចហើយ។ លើកលែងតែបញ្ហាផ្សេងទៀត ដទៃពីនេះ នោះយើងនឹងអនុញ្ញាតឱ្យលោកធ្វើការលើកឡើងនូវមតិយោបល់។

[១១:០៥:០១]

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ សួស្ដីអស់លោក លោកស្រី ខ្ញុំសូមឱ្យមានការបញ្ជាក់បំភ្លឺមួយចំណុចដោយសារតែកូនក្ដីរបស់ខ្ញុំនោះ ពេលខ្លះទៅក៏ងោកងងុយគេងផងដែរ។ ការសង្កេតរបស់ចៅក្រម ខាតវ៉ាយថ៍ ទើបតែលើកឡើង លោក អៀង សារី គាត់គេងនោះ ដោយសារតែគាត់ហ្នឹងអត់ចាប់អារម្មណ៍។ គឺជាមតិយោបល់ការសង្កេតរបស់យើងជាអ្នកដែលមិនមែនជំនាញ។ ដូច្នេះហើយ សូមឱ្យបញ្ជាក់ឱ្យបានច្បាស់ វា -- យើងដឹងហើយថា បើសិនជាគាត់គេង គឺគេង។ ក៏ប៉ុន្តែការដែលលើកឡើងថា គេងដោយសារតែគាត់មិនចាប់អារម្មណ៍នោះ គឺមិនមែនជាមតិរបស់អ្នកជំនាញនោះទេ។ លោកស្រីចៅក្រម ខាតវ៉ាយថ៍ មិនមែនជាវេជ្ជបណ្ឌិតនោះឡើយ។

[១១:០៥:៥១]

**ប្រធានអង្គជំនុំ៖**

អស់លោកមេធាវីការពារក្ដីសុទ្ធតែមានបុគ្គលិកជំនួយការ ប្រសិនបើឃើញកូនក្ដីរបស់លោកដេក ដាស់កូនក្ដីរបស់លោកឡើង ឱ្យភ្ញាក់ឡើងដើម្បីស្ដាប់នូវការជជែកពិភាក្សាដេញដោលនៅក្នុងកិច្ចដំណើរការសវនាការ។

អង្គជំនុំជម្រះប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោកស្រី-- អ៎! នាំមុខតំណាងដើម

បណ្ដឹងរដ្ឋប្បវេណី ដើម្បីបន្តការតាំងសំណួរដេញដោលបាទ។ អំមិញខាតពេលច្រើនដែរ អង្គជំនុំជម្រះនឹងបន្ថែមពេលវេលាឱ្យសមស្របទៅតាមនេះដែរ។

សូមអញ្ជើញ!

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

*(គ្មានការបកប្រែ)--*

**ប្រធានអង្គជំនុំ៖**

យើងមិនឱ្យនិយាយទៀតទេ។ ឥឡូវយើងបានសម្រេចរួចហើយ បើសិនជាមានការដេក សូមដាស់ ៗកូនក្តីរបស់លោកឡើង។ ដេក គឺដាស់កូនក្តីរបស់ឡើង ចប់ហើយ។

[១១:០៧:១១]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

លោកប្រធាន ខ្ញុំសូមលើកឡើង ប្រសិនបើ--

**ប្រធានអង្គជំនុំ៖**

យើងបានជម្រាបហើយ ឱ្យធ្វើអ៊ីចឹងទៅណា៎ះ! យើងដូចមិនដែលឮថាមានវេជ្ជបណ្ឌិតវាយតម្លៃរឿងមនុស្សដេកទេ។

សូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ជេត វណ្ណលី៖**

សូមអរគុណលោកប្រធាន។ នាងខ្ញុំសូមបន្តសំណួរដល់លោកស្រី ពេជ ស្រីផល បន្តទៀតចាស។

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** លោកស្រី មុនពេលសម្រាក លោកស្រីបានបញ្ជាក់ថា ឪពុកក្មេកលោកស្រីបានប្រាប់លោកស្រីថា គាត់អស់លទ្ធភាពដើម្បីលាក់លោកស្រីតទៅទៀតហើយ ហើយលោកស្រីក៏បានសម្រេចចិត្តបង្ហាញខ្លួននៅមុខអង្គការនៃមូលដ្ឋានដែលលោកស្រីស្នាក់នៅ។ បន្ទាប់មកគេយកលោកស្រីណាទៀត?

[១១:០៨:១៥]

**លោកស្រី ពេជ ស្រីផល៖**

**ផ៖** ចាស បន្ទាប់មក នៅពេលដែលនាងខ្ញុំបានបង្ហាញខ្លួនហើយ អង្គការខ្មែរក្រហមសរុបទៅ

អ្នក១៧ ដែលនៅក្នុងភូមិព្រៃក្រឡាញ់ហ្នឹង មានទាំងអស់៥០នាក់ចាស។ ក្នុង៥០នាក់នោះ អង្គការខ្មែរក្រហមបានឲ្យឡើង ជម្លៀសឲ្យឡើងទៅនៅលើភ្នំស្វក់ ចាស។ គេជូនទៅដល់ជើងភ្នំស្វក់ហើយ ហើយគេឲ្យពួកយើងឡើងទៅនៅលើភ្នំ។ នៅលើភ្នំនោះ អត់មានជម្រក អត់ទឹក អត់ស្បៀង អត់មានថ្នាំអ្វីទាំងអស់។ អ្នកឯងរស់យ៉ាងម៉េចកើតក៏រស់ទៅចាស។ ដូច្នេះពួកយើង៥០នាក់ដែលជាអ្នក១៧នេះ នៅពេលដែលទៅដល់លើភ្នំស្វក់ហើយ នាំគ្នាកាប់ព្រៃ កាប់អីហ្នឹងធ្វើជម្រកនៅ។ ពួកទាហានខ្មែរក្រហមអត់មានប្រើពួកយើងឲ្យធ្វើអ្វីទាំងអស់ គឺយកទៅដាក់ចោលទីនោះរស់យ៉ាងម៉េចកើតក៏រស់ទៅចាស។ ស្បៀងក៏អត់ អ៊ីចឹងនៅពេលនោះ ពួកអ្នកនៅ អ្នក១៧ ថ្មីទាំងអស់រស់នៅលើភ្នំស្វក់ គឺនាំគ្នារស់ទៅតាមលទ្ធភាពដែលអាចរកបាន។ ទឹកអត់មានទេ អ៊ីចឹងពេលយប់ឡើងនៅលើភ្នំសំបូរសន្សើមណាស់។ ពេលយប់ពួកខ្ញុំ យកក្រមាលាតដាក់ហាលតាមសន្សើម មានអាវមានអ៊ីចឹង ដាក់ហាលទៅ ពាក់កណ្ដាលយប់អ៊ីចឹងរើបពូតម្ដងយកទឹក ហើយលាតហាលទៅទៀត។ ភ្លឺឡើងពូតម្ដងទៀត ដើម្បីបានទឹកនោះទុកហូប។

[១១:០៩:៥៨]

ចំណែកស្បៀងវិញ ដែលយើងអាចរស់បាន ទី១ យើងបេះស្លឹកឈើស្លឹកព្រៃហូប។ ទី២ ជ្រូកព្រៃៗ ដែលនៅលើភ្នំហ្នឹង អាណាតូចៗ យើងនាំគ្នាព័ទ្ធវ៉ៃបាន។ ជ្រូកប៉ះចំអាហ្វូងអាជ្រូកធំ វាវ៉ៃពួកយើងស្លាប់ធ្លាយពោះនៅលើភ្នំហ្នឹងទៅ។ ចាស ហើយអ្នកដែលសេសសល់ប៉ុន្មានពីស្លាប់ហ្នឹង ដែលអាចរស់បាន ហើយអាចចុះពីភ្នំបាននេះ ដោយសារមាន ដូចខ្ញុំអ៊ីចឹង មានឪពុកក្មេកជាអ្នក១៨ អ្នកមូលដ្ឋាន ហើយអ្នកខ្លះ ក៏មានបងប្អូនគេនៅមូលដ្ឋាន គេលួចយកអង្ករទៅផ្លូវដែលគេស្គាល់។ ចាស លួចឡើងយកទៅឲ្យអ៊ីចឹងទៅ ក៏ចែកគ្នាហូប។ យើងរស់បានតាម ដូចថា តាមសម្នាអជីវោ ក្បាលណា សក់ហ្នឹងរស់ម៉េចកើតរស់ទៅ។ មានតែស្បែកដណ្ដប់ឆ្អឹងទេ ដែលចុះពីភ្នំមកវិញនោះ។ ចាស នៅលើភ្នំរយៈពេលប្រហែលជាជិត២ខែដែរ ដល់ពេលនោះ មានការប្រកូកប្រកាសពីអង្គការហ្នឹង គេឡើងទៅប្រកាសថា “ឥឡូវ មិត្តឯងទាំងអស់គ្នាហ្នឹង កសាងបានហើយ។ អ៊ីចឹង ចុះពីភ្នំទៅធ្វើការនៅកន្លែងថ្មីទៀត”។

[១១:១១:១៣]

ដូច្នេះ ពួកយើងដែលចុះពីភ្នំមកហ្នឹង អ្នកខ្លះក៏មានជំងឺដែរ ព្រោះនៅលើភ្នំ ខ្មោចជ្រូកព្រៃក៏ងាប់ខ្មោចមនុស្សក៏ងាប់ ហើយភ្នំសុទ្ធតែថ្ម អត់មានដីកប់ទេ។ អ៊ីចឹង ស្អុយក៏នៅហ្នឹង ក្រអូបក៏នៅហ្នឹង ចាស ដាច់បាយដាច់ទឹក។ អ៊ីចឹង អ្នក២០ អ្នកដែលចុះមកហ្នឹង ចាដូចមនុស្សព្រៃអ៊ីចឹង សក់ក្បាលវែងអ៊ីចឹង

ទៅ រឹងដូចឫស្សី អត់មានសាប៊ូ មានអីទេ ចាស--

**ស៖** អរគុណលោកស្រី។ ខ្ញុំចង់បញ្ជាក់លោកស្រី ចង់បញ្ជាក់ថាមុននឹងឡើងភ្នំហ្នឹង គេប្រាប់លោកស្រីថាម៉េចដែរ?

**ឆ៖** ចាស មុននឹងឡើងភ្នំ អង្គការបានប្រាប់ថា "មិត្តឯងទាំងអស់គ្នានេះ ត្រូវគេយកទៅកសាង"។ ចាស កសាងលត់ដំដើម្បីឲ្យត្រូវទៅតាមទិសរបស់អង្គការ។

**ស៖** អរគុណលោកស្រី។ ហើយហេតុអី ក៏គេយកតែអ្នក១៧មេសា លោកស្រី? គេបែងចែកអ្នកប្រជាជនចាស់ និងប្រជាជនថ្មី ហើយគេចាត់ទុកប្រជាជនថ្មី ជាមនុស្សបែបណាដែរ នៅទីនោះ?

[១១:១២:២៩]

**ឆ៖** ចាស នៅទីនោះ ប្រជាជនថ្មី គេចាត់ទុកដូចជាពួកក្បត់ ដូចជាអ្នកស៊ី សក្តិភូមិ។ ពួកនាយទុន។ ពួកថ្មី គេមិនទទួលស្គាល់ទេ គេថា ពួកយើងនេះ ចេញពីភ្នំពេញទៅ សុទ្ធតែពួកសក្តិភូមិ និន្នាការអីសេ.អ៊ី.អា របស់ លន់ នល់ អីណា។ កាលពិតសុទ្ធតែប្រជាជនទាំងអស់ហ្នឹង។ ចាស ហើយគេចោទអ៊ីចឹង ហើយគេឲ្យយកទៅកសាងខ្លួន។ យកទៅលត់ដំ។

**ស៖** អរគុណលោកស្រី អរគុណ។ ខ្ញុំចង់បញ្ជាក់មួយទៀតដែរ លោកស្រី ។ លោកស្រីបានបញ្ជាក់ថា "ពេលដែលឡើងទៅលើភ្នំហ្នឹង មានមនុស្ស៥០នាក់" ប៉ុន្តែដល់ចុងបំផុត ក្រោយដែលនៅបានប៉ុន្មានខែ តើនៅសល់ប៉ុន្មាននាក់ដែលវាឲ្យចុះមកវិញចាស?

**ឆ៖** ចាស ចុះពីភ្នំមកវិញ នៅសល់តែ ២០នាក់ទេ។ ៣០នាក់ទៀត គាត់ស្លាប់ដោយជ្រូកព្រៃវ័ធ។ ស្លាប់ឲ្យដាច់អាហារ ស្លាប់ដោយអត់ទឹក ស្លាប់ដោយមានជំងឺគ្មានថ្នាំព្យាបាល នៅហើមពេញព្រៃហ្នឹងឯង ចាស។

[១១:១៣:៤១]

**ស៖** អរគុណចាស។ ហើយចុះអ្នក ២០នាក់ហ្នឹង ដែលចុះមកហ្នឹង តើស្ថានភាពគាត់យ៉ាងម៉េចដែរ?

**ឆ៖** ស្ថានភាពអ្នកដែលនៅសល់ពីរស់២០នាក់ហ្នឹង ស្គម សក់ក្បាលរឹង ក្រញែងក្រញង់ អត់ដែលស្គាល់ក្រាស់ ស្គាល់ទឹក មានទឹកណា រកទឹកហូបបានផង ដែលមានទឹកណាងូត ចាស។ ក្អែលរុំរករន្ធញើសអត់ឃើញទេ ហើយក្បាលជង្គង់ចង់ធំជាងក្បាលទៅទៀត ព្រោះអត់អីហូប។ ហូបស្លឹកឈើស្លឹកព្រៃ ធ្វើម៉េចឲ្យពីមួយថ្ងៃទៅថ្ងៃ តែប៉ុណ្ណឹងឯងចាស។

**ស៖** អរគុណលោកស្រី។ ក្រោយពីការចុះពីលើភ្នំមក តើគណៈ -- កន្លែងដែលលោកស្រីរស់នៅហ្នឹង កន្លែងមូលដ្ឋានដែលលោកស្រីរស់នៅហ្នឹង គេឲ្យពួកដែលនៅសល់២០នាក់ហ្នឹង បញ្ជូនទៅណាទៀតលោកស្រី?

[១១:១៤:៤៤]

**ឆ៖** ចាស នៅពេលដែលក្រុមពួកនាងខ្ញុំចុះពីលើភ្នំមក នៅសល់២០នាក់ហ្នឹង មកដល់ជើងភ្នំយើងមិនមែនឃើញតែ២០នាក់ហ្នឹងទេ យើងមានឃើញអ្នក១៧ទៀត ប៉ុន្តែអត់ដឹងគេយកមកពីខាងណាទេ។ នៅចាំនឹងជើងភ្នំហ្នឹងឯង។ ហើយពេលដែលចុះមកដល់ជើងភ្នំហ្នឹងគេប្រាប់ថា "នាំគ្នាឡើងឡានទៅ គេដឹកយកទៅភ្នំពេញ ទៅធ្វើការកន្លែងថ្មីទៀត"។

**ស៖** តាមលោកស្រីឃើញ តើចំនួនមនុស្សទាំងអស់ដែលគេដាក់ឡានទៅហ្នឹងចំនួនប៉ុន្មានឡាន? ហើយចំនួនមនុស្សសរុបទាំងអស់ប្រហែលប៉ុន្មានដែរចាស?

**ឆ៖** ចាស ឡានដែលដឹកចេញពីជើងភ្នំស្វក់មកកាន់ទីក្រុងភ្នំពេញហ្នឹងមានឡានចំនួនពីរ។ ឡានមួយនោះ អាដំរីទឹកដែរតែរាងធំបន្តិច ឡានមួយទៀតតូចជាងអាដំរីទឹកហ្នឹងបន្តិចដែរ ហើយអ្នកដែលត្រូវឡើងលើឡានហ្នឹងចេញពីភ្នំស្វក់មកភ្នំពេញហ្នឹងមាន ៦០នាក់។

[១១:១៥:៥៥]

**ស៖** ពេលមុននឹងឡើងឡាន តើគេប្រាប់លោកស្រីថាម៉េច ថាយកណាដែរ? ថាដឹកទៅភ្នំពេញហ្នឹងយកទៅកន្លែងណា? ទៅធ្វើអី? មានប្រាប់ទេ?

**ឆ៖** គេអត់មានប្រាប់អីទេ គេគ្រាន់ប្រាប់ថាឡើងឡានទៅៗធ្វើការកន្លែងថ្មីទៀត។ ប្រាប់តែប៉ុណ្ណឹង។

**ស៖** ពេលមកដល់ភ្នំពេញ គេដាក់លោកស្រីនៅកន្លែងណា? អ្នកដែលទាំង ៦០នាក់ហ្នឹងគេយកទៅដាក់នៅកន្លែងណា នៅភ្នំពេញ?

**ឆ៖** ចាស ពេលមកដល់ភ្នំពេញ បើតាមខ្ញុំចាំគឺដាក់នៅហ្នឹងរ៉ាភ្នំពេញយើងហ្នឹងឯង។ ដាក់នៅហ្នឹងរ៉ាហ្នឹង ហើយនៅហ្នឹងរ៉ាហ្នឹងចំនួន ២យប់នៅហ្នឹងរ៉ាហ្នឹង។ នៅហ្នឹងរ៉ា ២យប់ហើយបានឃើញក្បាលរទេះភ្លើងគេតចេញមកហើយឃើញមនុស្សមាននៅក្នុងរថភ្លើងហ្នឹងស្រេច តែមិនដឹកមកពីខាងណាទេ ទើបឲ្យពួកខ្ញុំហ្នឹងឡើងទៅលើរថភ្លើងហ្នឹង ហើយដឹកបញ្ជូនទៅខាងកំពង់ឆ្នាំង។ នៅលើរថភ្លើងនោះទៀត នៅពេលដែលលើកដាក់ឡើងទៅ គឺជាទូរថភ្លើងទទេៗ មិនមែនទូរដែលមានកៅអីមនុស្ស

អង្គុយទេ។ នៅក្នុងទូហ្នឹងគេញាត់មនុស្សឡើងណែនៗ ហើយអាប្រឡោះទូរទេះភ្លើងដែលយើងឡើងហ្នឹងមានទ្វារចូលសងខាងគេមានរនុកឈើប៉ប៉ុនកំភ្លួនជើងវែងៗស៊កឃាំងទៀត។ ស៊កឃាំងទាំងសងខាង បែបគេខ្លាចមនុស្សធ្លាប់ហើយមើលទៅ។ ចាស ស៊កឃាំងហើយ ក្នុងទូនីមួយៗមានទាហានខ្មែរក្រហមហ្នឹង បីនាក់។ បើទូខ្ញុំមានបីនាក់ តែទូគេអត់ដឹងមានប៉ុន្មានទេ។ ទូខ្ញុំហ្នឹងមានបីនាក់ហើយទាហានទាំងបីហ្នឹងមានកាំភ្លើងគ្រប់ដៃចាស។

[១១:១៧:៥២]

**ស៖** លោកស្រីមានបានសង្កេតឃើញទេ តើចំនួនដែលដាក់ហ្នឹង ភាគច្រើនជាអ្នក១៧ ឬក៏លាយឡំជាមួយនឹងអ្នកមូលដ្ឋានដែរ? ហើយទូដែលដាក់យកទៅហ្នឹងទាំងអស់ប៉ុន្មានទូ? អាទូរថភ្លើងមួយៗហ្នឹងប៉ុន្មាន?

**ឆ៖** ទូរថភ្លើងម៉ុំដែលពួកខ្ញុំឡើង ហើយនិងម៉ុំដែលខ្ញុំឃើញគេដឹកមកហ្នឹង ទូដែលមានមនុស្សពេញៗហ្នឹងមានបួនទូ ប៉ុន្តែក្បាលខាងមុខទៀតដឹងមានអត់ទេ ព្រោះគេអត់ឲ្យយើងដើរទៅមុខទេ យើងនៅម៉ុំកន្លែងណាគេឲ្យឡើងកន្លែងហ្នឹង។ អ៊ីចឹង បួនទូនៅជាប់ខ្ញុំដែលទូទទេអត់មានអីសោះហ្នឹង គឺដឹកមនុស្សទាំងអស់ តែក្បាលខាងមុខមិនដឹងជាមានមនុស្សឬអត់ខ្ញុំអត់ដឹងទេ។ ហើយចំនួនប្រជាពលរដ្ឋដែលឡើងទៅលើទូរថភ្លើងនោះគឺអត់មានមូលដ្ឋានទេ សុទ្ធតែអ្នកថ្មីទាំងអស់ គឺថាអ្នក១៧ទាំងអស់ អ្នកខ្លះជម្លៀសចេញពីភ្នំពេញ អ្នកខ្លះជម្លៀសចេញពីខេត្តណាខេត្តណីនៅច្របូកច្របល់ពេញហ្នឹងឯងចាស។

**ស៖** អរគុណលោកស្រី។ តើពេលដែលអ្នកទាំងនោះឡើងនៅគ្រប់ទូរទាំងអស់ហើយ តើគេរទេះភ្លើងហ្នឹងគេតម្រង់ទៅខាងណា? ហើយចុងក្រោយបំផុតគេយកលោកស្រីទៅដាក់នៅកន្លែងណា?

**ឆ៖** នៅពេលដែលគេរៀបចំដាក់មនុស្សចូលណែនពេញទូអស់ហើយ រថភ្លើងហ្នឹងបានបើកទៅខេត្តកំពង់ឆ្នាំង។ ពួកខ្ញុំហ្នឹងទៅចុះនៅខេត្តកំពង់ឆ្នាំង។ ទៅដល់កំពង់ឆ្នាំងហ្នឹង គឺយើងនៅទីនោះតែមួយរយៈប៉ុណ្ណោះ បន្ទាប់មកមានឡានមកខាងពីខេត្តពោធិ៍សាត់ គេមកជួបជាមួយខាងខេត្តកំពង់ឆ្នាំងហ្នឹង ហើយខាងពោធិ៍សាត់បាននិយាយជាមួយខាងយោធាអី ឈ្លបអីនៅខាងកំពង់ឆ្នាំងហ្នឹងថា "ខេត្តពោធិ៍-សាត់ខ្វះមនុស្សធ្វើការ ត្រូវការដឹកប្រឡាយមានស្រែច្រើន មានប្រឡាយច្រើន ភ្លឺស្រែច្រើន"។ អ៊ីចឹងត្រូវមកស្នើកម្លាំងហ្នឹងពីខាងខេត្តកំពង់ឆ្នាំង។ ពេលនោះក្រុមពួកនាងខ្ញុំហ្នឹង ដោយទាំងនាងខ្ញុំទៀតត្រូវបានខាងកំពង់ឆ្នាំងតម្រូវឲ្យនាងខ្ញុំនេះ ទៅធ្វើការនៅខេត្តពោធិ៍សាត់ដោយជិះតាមរថយន្តចាស។

[១១:២០:២៥]

**ស៖** ខ្ញុំចង់បញ្ជាក់លោកស្រីដែរថា ពេលដែលលោកស្រី គេដាក់នៅលើរទេះភ្លើងហ្នឹងណ៎ា តើគេមានចែករបប ចែកខោអាវ ចែកអីទេលោកស្រី?

**ផ៖** នៅលើរថភ្លើង របបអត់មានទេ ខោអាវអត់មានទេ ចែកអីក៏អត់ដែរ។ ដែលពួកយើងបាននេះដោយសារបាយក្រៀម ៗដែលសាច់ញាតិឲ្យពីភូមិក្រៀមៗហ្នឹង ដាក់លួចត្រាំទឹកហើយ នាំគ្នាបៀម។ ជួនណាអត់មានទឹកទេ ដាក់បាយក្រៀមហ្នឹងចូលទៅក្នុងមាត់បៀមឲ្យរីក ហើយលេបទៅ។ អត់មានចែកអីទាំងអស់។

**ស៖** លោកស្រីមានបានសង្កេតឃើញទេនៅពេលដែលធ្វើដំណើរតាមរថភ្លើងហ្នឹង? មានអ្នកស្លាប់ ឬមួយមានអ្នកលួចរត់អីទេ?

**ផ៖** នៅតាមរថភ្លើងនោះ លួចរត់អត់រួចទេ ព្រោះគេនៅយាមនឹងមាត់ទ្វារហ្នឹង ហើយខ្នោះឈើដាក់ឃាំងមាត់ទ្វារទៀត បើលោតទៅក៏លោតអត់រួចដែរ។ បើលោកក៏ស្លាប់ដែរ ព្រោះរថភ្លើងអត់បើកយឺតទេចាស ហើយអ្នកដែលស្លាប់នៅលើរទេះភ្លើងហ្នឹង គឺស្លាប់ដោយពួកគាត់ហែវហាត់មកហើយ យកទៅញាត់ឲ្យណែនទៀត។ អ៊ីចឹងអ្នកដែលស្លាប់នៅលើរទេះភ្លើងនោះ គេអត់បានឲ្យរទេះភ្លើងនោះឈប់ដើម្បីយកសាកសពហ្នឹងទៅទុកដាក់ត្រឹមត្រូវទេ។ បើថាស្លាប់អ៊ីចឹង ឈ្លប អ្នកដែលនៅប្រចាំការក្នុងទូហ្នឹង អូសសពហ្នឹងមក អូសខ្មោចហ្នឹងមកហើយ ទម្លាក់ទៅតាមមាត់ច្រករទេះភ្លើង ព្រោះអត់មានទ្វារបិទទេ ប្រហោងប៉ុនៗណាណីនោះ។ រុញទម្លាក់អ៊ីចឹងទៅ សាច់ញាតិបងប្អូនអ្នកណាក៏ដោយ អត់គិតទេទៅ។ ស្លាប់ហើយ ទុកអត់ចំណេញ បោះចោល។ ចាស ហើយអ្នកដែលរស់ ត្រូវគេដឹកបន្តទៅទៀត។

[១១:២២:២១]

**ស៖** លោកស្រីបានបញ្ជាក់ថា លោកស្រីទៅដល់កំពង់ឆ្នាំង តើពេលនោះទៅឈប់នៅវ៉ាណាមួយលោកស្រី? លោកស្រីមានចាំឈ្មោះវ៉ាហ្នឹងទេ?

**ផ៖** ចាទ ទៅដល់កំពង់ឆ្នាំង ឈប់នៅវ៉ាបំណក់។

**ស៖** លោកស្រីរស់នៅកំពង់ឆ្នាំងហ្នឹងប៉ុន្មានថ្ងៃ ប៉ុន្មានខែដែរ មុននឹងទៅខេត្តពោធិ៍សាត់?

**ផ៖** មុននឹងទៅខេត្តពោធិ៍សាត់ រស់នៅកំពង់ឆ្នាំងនេះតែមួយរយៈតូចទេ អត់នៅៗបានយូរប៉ុន្មានទេចាស។

**សៈ** តើនៅកំពង់ឆ្នាំងហ្នឹងគេឲ្យអ្នកដែលទៅហ្នឹង អ្នកដែលយកតាមរថភ្លើងទៅហ្នឹង គឺគេឲ្យធ្វើអីលោកស្រី?

**ផៈ** នៅកំពង់ឆ្នាំងអ្នកដែលយកទៅតាមទូរថភ្លើងហ្នឹង គេឲ្យធ្វើស្រែដកស្ទូង ធ្វើការងារស្រែចម្ការទាំងអស់អត់មានឲ្យធ្វើអីក្រៅពីធ្វើស្រែ លើកភ្លឺ ដកស្ទូង។

**សៈ** ខ្ញុំចង់បញ្ជាក់លោកស្រីម្តងទៀតដែរថា នៅលើទូរថភ្លើងហ្នឹង ដែលពេលគេដាក់ហ្នឹងគឺញាត់តែម្តង មនុស្ស អត់មានកៅអីឲ្យអង្គុយទេ? គឺញាត់មនុស្សចូលក្នុងទូហ្នឹងតែម្តង ឬក៏យ៉ាងម៉េច? សូមបញ្ជាក់កន្លែងហ្នឹងបន្តិចលោកស្រី។

[១១:២៤:០០]

**ផៈ** ចាស នៅក្នុងទូរថភ្លើងហ្នឹងអត់មានកៅអីទេ ជាទូទំនេរ អាទូហ្នឹងបើពីដើមមកគេដាក់ជ្រូក គេដាក់គោ គេដាក់អីទូហ្នឹងនោះ មិនមែនឲ្យមនុស្សជិះទេចាស។ អ៊ីចឹងក្នុងទូហ្នឹងចាប់ឲ្យឡើងៗញាត់ធ្វើម៉េចឲ្យណែន មើលតែនៅល្មមអាចយើងដកដង្ហើមស្រួលអង្គុយស្រួលគេឲ្យមនុស្សឡើងទៀត។ ឡើងធ្វើម៉េចឲ្យណែន ហើយបានគេដាក់អាឃ្នងដូចយើងធ្វើក្រោលគោហ្នឹង បានគេដាក់អាហ្នឹងមកបានគេរៀបចំចេញ។

**សៈ** អរគុណលោកស្រី។ ហើយនៅតាមផ្លូវរទេះភ្លើងហ្នឹងមានឈប់ទេ នៅតាមផ្លូវ? ហើយឧទាហរណ៍ថា ដូចមានអ្នកណាចង់បត់ជើង ចង់អី ធ្វើម៉េចដែរ?

**ផៈ** នៅតាមរថភ្លើង បើសិនជាអ្នកឈឺពោះចង់បត់ជើង ត្រូវប្រាប់ទាហានឈ្លបយោធាគេហ្នឹងចាស អត់អាចបត់ជើងដាក់លើរទេះភ្លើងបានទេ។ បើសិនជាអ្នកណាមិនប្រាប់ហើយ ហើយទៅលេចដាក់លើរទេះភ្លើងគឺបាញ់ចោលនៅក្នុងហ្នឹងតែម្តង ព្រោះវាអត់ -- ពួកគេហ្នឹងអត់គិតថា យើងជាអ្នក១៧ហ្នឹងធុំក្លិនមិនល្អទេ។ តែគេគិតថា គេហ្នឹងធុំក្លិន។ អ៊ីចឹងរឿងពួកគេធុំក្លិនអត់បានទេ។ ចំណែកពួកយើងធុំម៉េចធុំទៅ។ ដូច្នេះ បើសិនជាយើងឈឺពោះត្រូវបត់ដៃ បត់ជើង ត្រូវប្រាប់ឈ្លបគេហ្នឹង។ ពេលណាដែលប្រាប់ឈ្លបហើយ មិនមែនឈ្លបហ្នឹងបញ្ជាឲ្យរទេះភ្លើងឈប់បានភ្លាមទេ ទម្រាំតែគេដឹង គេប្រាប់ទៅក្បាលរទេះភ្លើងតាមរយៈណា ខ្ញុំអត់ដឹង។ ប៉ុន្តែបើសិនជារទេះភ្លើងឈប់នៅពេលដែលយើងឈឺបត់ដៃបត់ជើងចុះទៅហ្នឹង គឺឈ្លបហ្នឹងតាមយើងទៅ ខ្លាចយើងរត់។ តាមយើងទៅក្នុងព្រៃអ៊ីចឹង យាមកាមយើងអ៊ីចឹងទៅ។ ដល់ពេលយើងបត់ហើយ បានគេជំរុញយើងឲ្យឡើងមកវិញ។

[១១:២៦:០០]

**ស៖** អរគុណលោកស្រី។ លោកស្រីបានបញ្ជាក់ដែរអំមិញថា លោកស្រីនៅខេត្តកំពង់ឆ្នាំងបានមួយរយៈ ហើយបន្ទាប់មកបានមានឡានគេមកដឹកយកទៅពោធិ៍សាត់ ដើម្បីទៅធ្វើការនៅពោធិ៍សាត់។ តើឡានដែលដឹកលោកស្រីយកទៅហ្នឹងជាឡានប្រភេទណា? ហើយមនុស្សដែលយកទៅហ្នឹងចំនួនប៉ុន្មាននាក់ដែរ? ឬក៏យកទាំងមនុស្សដែលជិះរទេះភ្លើងទាំងអស់ហ្នឹងយកទៅនោះទាំងអស់ ឬមួយក៏នៅសល់កំពង់ឆ្នាំងខ្លះដែរ?

**ឆ៖** មនុស្សដែលចុះពីលើរថភ្លើងទាំងអស់នោះ មិនបានដឹកទៅខេត្តពោធិ៍សាត់ទាំងអស់ទេ។ មួយចំនួននៅនឹងកំពង់ឆ្នាំង មួយចំនួនទៀតត្រូវឡើងឡានទៅខេត្តពោធិ៍សាត់ចាស។ ឡានដែលមកដឹកជញ្ជូនពីកំពង់ឆ្នាំងទៅខេត្តពោធិ៍សាត់ ថ្ងៃដែលពួកខ្ញុំចេញទៅ គឺជាថ្ងៃទី១ មានឡានមកបី។ ព្រោះប្រជាពលរដ្ឋ បើតាមខ្ញុំប្រមាណមើលទៅ ទៅខេត្តពោធិ៍សាត់ហ្នឹង គឺទាបបំផុតក៏ ២.០០០នាក់ដែរចាស។ ដូច្នេះ ២.០០០នាក់អ៊ីចឹង ដឹក -- ថ្ងៃដែលមកដឹកពួកខ្ញុំហ្នឹង គឺទៅឡានបី ប្រជាជនទៅអត់ទាន់អស់ទេចាស។ គេយកពួកខ្ញុំបីឡានទៅដាក់ដល់ពោធិ៍សាត់ហើយ ទើបគេដំណើរការត្រឡប់មកវិញ។ តែគេមកដឹកប៉ុន្មានជើងទៀត ខ្ញុំអត់ដឹងទេ ដោយសារខ្ញុំទៅដល់ពោធិ៍សាត់មុនហើយ។

**ស៖** ពេលដែលលោកស្រីទៅពោធិ៍សាត់ តើលោកស្រីគេចាត់តាំងឲ្យទៅនៅភូមិណា? នៅភូមិណា នៅស្រុកណា? ហើយគេឲ្យលោកស្រីធ្វើអីខ្លះ?

[១១:២៧:៤២]

**ឆ៖** ពេលនាងខ្ញុំទៅដល់ពោធិ៍សាត់ គេបំបែកហើយ។ ប្ដីនាងខ្ញុំគាត់ទៅធ្វើការនៅកន្លែងកងភ្ជួរ ចំណែកនាងខ្ញុំវិញគេដាក់ឲ្យទៅនៅភូមិស្ទឹង ៦សហករណ៍វត្តហ្លួងចាស។ នៅទីនោះ នាងខ្ញុំចូលទៅក្នុងក្រុមដកស្ទូង ចំណែកគ្រួសារគាត់ចូលទៅនៅក្រុមភ្ជួរ។ ខែវស្សាគេប្រើឲ្យដកស្ទូង ខែប្រាំងគឺត្រូវលើកភ្លឺ។ អ៊ីចឹងនៅក្នុងរដូវវស្សាដែលយើងដកស្ទូងនោះ នៅខាងខេត្តពោធិ៍សាត់គេគិតថា ស្អីរបស់គេនោះមហាលោតផ្លោះ មហាអស្ចារ្យ មួយហិកតាប៉ុន្មានទេ ប្រាំបួនប្រាំតោនអ៊ីចឹងទៅ គេធ្វើជាលក្ខណៈស្ទូងជាបន្ទាត់។ អ៊ីចឹងក្នុងមួយហិកតាឲ្យស្ទូង ១០នាក់ ហើយមានអ្នកលើកខ្សែបន្ទាត់ហ្នឹងនៅសងខាងស្រែហ្នឹង។ នៅពេលដែលកងឈ្លប ឬក៏ទាហានគេហ្នឹង ផ្លុំកញ្ចែច្រេច អ្នកលើកហ្នឹងត្រូវលើក ហើយអ្នកស្ទូងហ្នឹងត្រូវខិនស្ទូងឲ្យលឿន ហើយដើបឲ្យលឿន។ ក្នុងម្នាក់មុខមួយម៉ែត្រចាស។ ហើយស្ទូងឲ្យបានបួនចង្កូត។ ដូច្នេះបើអ្នកណាស្ទូងហើយដើបមិនទាន់ នៅពេលដែលអ្នកលើកខ្សែគេលើកឡើង ហើយខ្សែ

គេហ្នឹងប្រភេទភាគច្រើនជាខ្សែលួស ជាខ្សែអារឹងៗនោះ វល្លិ៍មែន -- ជ័រមែន ប៉ុន្តែជ័ររឹងចាស។ គេលើកខ្វាច់ដាក់ចុះ លើកដាក់ចុះ ៗអ៊ីចឹង។ បើយើងដើបមិនទាន់ ខ្សែហ្នឹងចួនណាវាត់ត្រូវភ្នែក។ ថ្ងៃមួយនោះខ្ញុំស្ទូង វាត់មកត្រូវភ្នែកអ្នកនៅជិតខ្ញុំ។ វាត់ឆ្វាច់ ចំភ្នែកបែកចេញឈាមចាស។ នៅពេលដែលគ្នាបែកភ្នែកចេញឈាមហើយ មិនដួល ចាសនៅពេលដែលដួលទៅ វាខូចសន្ទូងនៅក្នុងស្រែនោះ អាស្ទូងហើយហ្នឹងវាខូច។ អ៊ីចឹង ឈ្លប យោធា ទាហានខ្មែរក្រហម ដែលគេនៅយាម គេមើលការខុសត្រូវអ្នកដែលស្ទូងហ្នឹង គេចុះមក គេវ៉ៃយើងថែមទៀត។ គេថា “សតិអារម្មណ៍ ពុត ធ្វើការមិនប្រឹងប្រែង ឲ្យខូចសន្ទូងរបស់គេ”ចាស។ ហើយគេប្រាប់ទៀតថា “អ្នកឯង មិត្តឯងទាំងអស់គ្នាមើល បើអ្នកណាយកគំរូហ្នឹងទៀតត្រូវធ្ងន់ជាងហ្នឹងទៀត”។ អ៊ីចឹងពួកយើងម្នាក់ៗខ្លាចគេណាស់ អត់ប៉ានទេ ទោះតែហត់នឿយប៉ុន្មានក៏ដោយ ប្រឹងតែជ្រមុជ ត្រចៀកហ្នឹងចាំតែស្ដាប់ឲ្យតែច្រេចដើបឲ្យលឿន បើមិនលឿនត្រូវរបស់គេហើយចាស។

[១១:៣០:១៨]

**ស៖** អរគុណលោកស្រី។ តើនៅក្នុងមូលដ្ឋានដែលលោកស្រីនៅហ្នឹង របបហូបចុកយ៉ាងម៉េចដែរ ការងារយ៉ាងម៉េចដែរ? ហើយក្រុមគ្រួសារលោក តើនៅជុំគ្នាទេ ឬក៏គេបំបែកបងប្អូន?

**ឆ៖** នៅពោធិ៍សាត់ ខ្ញុំនៅតែពីរនាក់គ្រួសារខ្ញុំទេ។ ឪពុកម្ដាយបងប្អូនខ្ញុំបានទៅតាមឡានផ្សេងទៀត ទៅខេត្តបន្ទាយមានជ័យអស់ហើយ។ នៅពោធិ៍សាត់ហ្នឹងមានតែពីរនាក់ទេ ហើយបើគិតទៅលើរបបហូបវិញ មួយកំប៉ុង៣០នាក់។ ម្នាក់ខ្ញុំអត់ដឹងបានប៉ុន្មានគ្រាប់ទេ។ ឆ្អែត មិនឆ្អែត គេអត់ដឹងទេ។ គេដឹងតែមួយកំប៉ុង៣០នាក់ ដួសមួយវែកដាក់ចាន លើកទាំងចានហ្នឹងហុតមួយគ្រុកអស់ ហើយដើរទៅធ្វើការទៀត។

ហើយបើសម្លវិញមានតែគល់ចេក ស្អី! ត្រកួន ឫស អាដើមកំប្លោកគេនោះ ចាស ស្លអ៊ីចឹងមកដាក់មកមួយចានអ៊ីចឹង បបរមួយវែកៗម្នាក់ ហុតទៅដើបធ្វើការ។ អត់មានអ្នកណាតវ៉ាទេ តែបើគេសួរថា”ឆ្អែតអត់? ឆ្អែត។ឆ្ងាញ់អត់? ឆ្ងាញ់” តែប៉ានថា មិនឆ្អែត ខ្លាំងទៀត។ ចាស អ៊ីចឹងរបបមានតែមួយកំប៉ុង៣០នាក់ មួយខ្ទះហ្នឹងចែកគ្នាហុតទៅ។

**ស៖** អរគុណលោកស្រី។ ចុះក្រៅពីពេលធ្វើការ មានពេលឈឺថ្កាត់ តើយើងអាចមានពេលឈប់សម្រាក ឬក៏មានឲ្យរបបអីត្រឹមត្រូវទេអ្នកដែលឈឺថ្កាត់?

[១១:៣២:០៧]

**ឆ៖** ពេលមានជំងឺ ខ្ញុំចង់និយាយលើខ្លួនខ្ញុំផ្ទាល់ចុះ។ ពេលដែលខ្ញុំឈឺ ខ្ញុំកើតអាច្ឆសសំណាប នោះ ពងពេញជើងទាំងអស់។ ទៅស្ទូងអត់កើតទេ។ ដើរដូចគេកើតទាមឡាអ៊ីចឹង ចាស។ ដល់ពេលទៅស្ទូងអត់កើត យើងប្រាប់ចុងភៅថាយើងឈឺ នៅពេលនោះទៅស្ទូងអត់រួចនៅដេកកន្លែង។ គណៈតំបន់គេហ្នឹង គេឲ្យនីរសារហ្នឹងទៅមើលនៅកន្លែង។ មានមនុស្សនៅកន្លែងប៉ុន្មាននាក់? ប្រាប់ចុងភៅថា "កុំឲ្យរបបហូបឲ្យសោះ។ អ្នកដើរឈឺហ្នឹង ឲ្យដើរទៅហូបបាយនៅកន្លែងគេធ្វើការ បានមានបាយហូប។ បាយឲ្យយកទៅទាំងអស់"។ អ៊ីចឹងតែប៉ុណ្ណានឈឺ គឺអត់ហើយ អត់ឲ្យទេ ព្រោះតែឈឺធ្វើការអត់កើត មិនបាច់ហូបទេ។ ឈឺអត់ឃ្លានទេ។ យករបបទាំងអស់ហ្នឹងទៅកន្លែងទាំងអស់ ទៅកន្លែងធ្វើការទាំងអស់។

[១១:៣២:៥៧]

អ៊ីចឹងបើសិនជាយើងសម្រេចចិត្តថា យើងដើរពីការដ្ឋានដែលយើងដេកនេះទៅយករបបយើងហូបនៅកន្លែងធ្វើការ គេថាយើងរិតតែសតិអារម្មណ៍ទៀត អ្នកឯងដើរមកយកបាយបាន មកយកបបរបាន តែអ្នកឯងធ្វើការអត់កើត អ្នកឯងគឺជាខ្មាំងពេញទី ត្រូវតែកម្ទេច។

ហើយនៅចំណុចមួយទៀត នៅពេលដែលឃើញយើងឈឺអ៊ីចឹងហើយ ថាអត់ឲ្យនៅហ្នឹងកន្លែងទេ យកទៅដេកពេទ្យ។ ទៅដល់ពេទ្យ គេចាត់នីរសារហ្នឹងឲ្យមកយកចេញពីពេទ្យបណ្ដើរយកទៅទាំងអស់ ចាស។

**ស៖** អរគុណលោកស្រី។ តើ -- អំមិញខ្ញុំឮលោកស្រីពាក្យមួយថា "កម្ទេច" វាន័យយ៉ាងម៉េចដែរលោកស្រី "កម្ទេច"ហ្នឹង?

**ឆ៖** ចាស "កម្ទេច" ហ្នឹង-- *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

[១១:៣៣:៤៤]

**ស៖** ចុះក្រៅពីពាក្យ "កម្ទេច" តើមានពាក្យអីផ្សេង--

**ប្រធានអង្គជំនុំ៖**

ឆ្លើយសិន រឿង "កម្ទេច" អំមិញ។ គាត់ឆ្លើយ ក្បាលមីក្រូអត់ទាន់ប្រតិបត្តិការទេ។

**លោកស្រី ពេជ ស្រីផល៖**

**ឆ៖** ចាស "កម្ទេច" គឺសម្លាប់។ ច្បាស់អ៊ីចឹងតែម្ដង ខ្ញុំធានា ស្បថ "កម្ទេច" គឺ "សម្លាប់" អត់មានទុកទេ។ ចំណែកពាក្យដែលថា "កសាង" វិញ មានអ្នកខ្លះកសាង ក៏សម្លាប់ដែរ ប៉ុន្តែក្នុងលក្ខណៈ

កសាងហ្នឹង កសាងខ្លះទៅយកទៅលត់ដំ បង្អត់បាយ បង្អត់ទឹក ធ្វើទារុណកម្មក្នុងស្នឹមន្ទីររបស់គេហ្នឹង ឲ្យឆ្អែតឆ្អន់ទៅ បើនៅអាចរស់បាន គេលែងមកវិញបានខ្លះ។ តែបើ "កម្ទេច" គឺ "សម្លាប់" ហើយចាស។

**ស៖** អរគុណលោកស្រី។ តើចំពោះរបប របបអាហារដែលចែកឲ្យ គេមានបែងចែករវាងប្រជាជនថ្មី និងប្រជាជនចាស់អីទេ ឬមួយក៏សុទ្ធតែប្រជាជនថ្មីទាំងអស់ កន្លែងដែលលោកស្រីរស់នៅ?

[១១:៣៤:៤៨]

**ឆ៖** កន្លែងដែលនាងខ្ញុំរស់នៅ មានប្រជាជនចាស់ និងប្រជាជនថ្មី។ ប្រជាជនចាស់របបហូបគេ បាយពូត ដូចថាប្រាំបីនាក់អីចឹង ធ្វើម៉េចក៏បានមួយដុំៗប៉ុណ្ណោះម្នាក់ដែរក្នុងមួយឆ្នាំង មិនដឹងដាំប៉ុន្មានកំប៉ុងទេ តែឆ្នាំងប៉ុណ្ណោះ ពូត។ ចំណែកប្រជាជនថ្មី បបរ។ មូលហេតុដែលនាងខ្ញុំហ៊ានថាហ្នឹងដោយសារថ្ងៃមួយនោះ ខ្ញុំឃ្លានពេក ខ្ញុំលួចលូនទៅលួចបាយរបស់ពួកមូលដ្ឋាន។ ខ្ញុំលួចទាំងអាត្រីដែលគេរកទុកស្ដុស្ដែកទៀត ខ្ញុំវារលូកយកមកឆ្អិនឆៅ ខ្ញុំអត់ដឹងទេ ខ្ញុំលួចយកមក លួចទាំងបាយ លួចទាំងអីគេយកមកហូប។ ហ្នឹងបើគេទាន់ថ្ងៃហ្នឹងងាប់បាត់ហើយ តែគេអត់ទាន់។

[១១:៣៥:៣១]

**ប្រធានអង្គជំនុំ៖**

ពេលវេលាមានកំណត់ ហើយបញ្ហាពីរ។ ទី១ គឺសូមមេធាវីតម្រង់សំណួរឲ្យចំទៅនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការ ជម្លៀសទី១ និងទី២។ មិនឃ្លាតឆ្ងាយពេកទេ គឺទៅដល់ ហើយនិងបច្ច័យទាំងឡាយនៃការទៅដល់នៃដំណើរការជម្លៀសទី២។ ហើយនិងបញ្ហាទី២ សូមបញ្ជាក់អំពីពេលវេលាជាមួយនឹងតំណាងសហព្រះរាជអាជ្ញាក្នុងការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន យើងខ្ញុំបានជជែកជាមួយខាងតំណាងសហព្រះរាជអាជ្ញារួចហើយ។ តំណាងសហព្រះរាជអាជ្ញាអាចនឹងត្រូវការរយៈពេលពី១០ ទៅ ១៥នាទី តែប៉ុណ្ណោះ។ បាទ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

**សួរដោយលោកស្រី ដេត វណ្ណលី៖**

**ស៖** សូមឲ្យលោកស្រីបញ្ជាក់នៅចំពោះមុខអង្គជំនុំជម្រះ ថាតើលោកស្រីបានឃើញអីខ្លះៗ? បានឮអីខ្លះនៅកន្លែងដែលលោកស្រីរស់នៅ នៅជាពិសេសនៅខេត្តពោធិ៍សាត់?

[១១:៣៦:៤៩]

**លោកស្រី ពេជ ស្រីផល៖**

**ឆ៖** ចាស នៅខេត្តពោធិ៍សាត់ បើគិតមកលើខ្លួននាងខ្ញុំផ្ទាល់ នាងខ្ញុំត្រូវបានឈ្លបខ្មែរក្រហមធ្វើទារុណកម្ម ឲ្យទៅរែកដីដំបូកនៅពេលដែលខ្ញុំលួចស្រូវគេលីងហូបចាស។ ក្នុង១ថ្ងៃ ខ្ញុំម្នាក់ឯងហ្នឹង ក្នុង១ថ្ងៃឲ្យបាន២០០អម្រែកចាស។ បន្ទាប់មកទៀត ដោយសារខ្ញុំមិនគោរពតាមគោលការណ៍របស់អង្គការ គេបានយកខ្ញុំទៅឲ្យបោកកណ្ដាប់១យប់ឲ្យបាន១.០០០កណ្ដាប់។ នៅពេលដែលខ្ញុំបោកអត់បាន ខ្ញុំសន្លប់ទៅ គេបានជះទឹកទៅលើខ្ញុំ នៅពេលដែលខ្ញុំដឹងខ្លួន គេប្រើឲ្យខ្ញុំបោកបន្តទៀត។ ជិតភ្លឺឡើង ខ្ញុំបោកអត់រួច ឈ្លបទាហានខ្មែរក្រហមហ្នឹងបានបណ្ដើរខ្ញុំយកទៅសម្លាប់ចោលនៅទួលថ្ម។ ប៉ុន្តែនៅពេលមកតាមផ្លូវហ្នឹង ខ្ញុំបានជួបតាពាណិជ្ជនៅចម្ការសំភី គាត់បានសួរទៅឈ្លបហ្នឹងថា "យកមិត្តហ្នឹងទៅណា?" ឈ្លបក៏បានប្រាប់ថា "ខ្ញុំនេះក្បត់អង្គការ គេត្រូវយកទៅកម្ទេចហើយ"។ អ៊ីចឹង តាមាន ដែលជាពាណិជ្ជរបស់ចម្ការសំភីហ្នឹងថា "សុំឲ្យទុកនៅទីហ្នឹងសិនហើយ គាត់ទៅណោះមួយភ្លែត ចាំគាត់មកវិញ ចាំយកទៅណាយកចុះ"។ គាត់ទៅបាត់អស់មួយសន្ទុះធំ នៅពេលដែលគាត់ត្រឡប់មកវិញ ដោយមានឈ្លបមួយមកជាមួយ គេបានប្រាប់ថា "មិត្តហ្នឹងត្រូវបានដោះស្រាយចប់ហើយ។ ឥឡូវឲ្យមិត្តហ្នឹងទៅតាមាន ដែលជាពាណិជ្ជចម្ការសំភី គាត់យកទៅចុះ"។ អ៊ីចឹងនាងខ្ញុំក៏បានរួចពីនោះចាស។ អាហ្នឹង ដែលខ្ញុំបានឮ និងបានឃើញទី១។

[១១:៣៨:៣៣]

ទី២ -- ចំណុចមួយទៀត ពួកប៉ូព៌ា ដែលមានក្រមាខៀវ ត្រូវបានឈ្លប និងទាហានខ្មែរក្រហមហ្នឹងចងទាំងខ្សែបណ្ដើរទៅលើស្ពាន ទៅលើទំនប់កន្លែងព្រហស្បតិ៍ក្បាល កន្លែងទួលថ្មហ្នឹង បណ្ដើរយកទៅព្រៃជើងហ្នឹង ហើយចុះភៅបានប្រាប់ខ្ញុំថា "នេះជាប្រពន្ធរបស់ពួកប៉ូព៌ាដែលសល់ពីប្ដីដែលគេបានយកទៅសម្លាប់ហើយហ្នឹង គេយកទៅសម្លាប់បង្ហើយហើយ។ អ៊ីចឹងប្អូនឯងហ្នឹង កុំឲ្យនៅយូរ ឆាប់ចេញទៅប្រយ័ត្នគេច្រឡំយកទៅជាមួយ"។ ក្នុងនោះមានកុមារីម្នាក់ ដែលជាកូនរបស់ប៉ូព៌ា តែនាងនៅឯជាមួយការដ្ឋានកុមារ ត្រូវបានឈ្លបទៅបណ្ដើរយកមក ដើរសួររកម្ដាយ។ កុមារហ្នឹងប្រាប់ថា "ម្ដាយ

នៅកន្លែងកិនស្រូវ នៅកន្លែងចុងភៅ" ប៉ុន្តែដើររកម្តាយអត់ឃើញ ម៉ោងប្រហែលជាបួនល្ងាច ត្រូវបានឈ្លបនោះនាំយកទៅសម្លាប់នៅក្រោយមន្ទីរពេទ្យទួលថ្ម។

[១១:៣៩:៣៩]

ចំណុចមួយទៀត មិត្តសំ និងមិត្តនី ខ្ញុំអត់ដឹងថាគេខូចសីលធម៌គ្នាយ៉ាងម៉េចទេ ប៉ុន្តែថ្ងៃមួយហ្នឹងខ្ញុំបានដើរបេះស្លឹកថ្នឹងយកទៅឲ្យចុងភៅនៅខាងជើងពេទ្យទួលថ្ម។ នៅពេលដែលខ្ញុំបេះនោះ ខ្ញុំឮសូរស្រែក ខ្ញុំក៏វែកអារព្រៃរបាំងជិតហ្នឹង វែកមើលទៅ ខ្ញុំឃើញឈ្លបចាប់ដោះខោអាវមិត្តសំ ហ្នឹងទាំងអស់ចងបញ្ច្រាសហើយ វះពោះយកប្រមាត់។ ចំណែកមិត្តនារី នី នោះ គេបានសម្រាតខោអាវអស់ហើយគេអារកសម្លាប់ ហើយខ្ញុំមិនដឹងថាមុននឹងអារ-កហ្នឹង គេរំលោភ ឬក៏អត់ទេ។ ព្រោះហេតុការណ៍ហ្នឹងខ្ញុំទៅទាន់ នៅពេលដែលគេវះពោះ និងដោះខោអាវនាងនោះ ចងនាងនោះរួចហើយចាស។ ហើយចំណុចដែលគួរឲ្យនាងខ្ញុំឈឺចាប់មែនទែននោះគឺថា គ្រួសារនាងខ្ញុំនៅធ្វើការជាមួយនឹងកងពិសេស នៅជើងភ្លើង ត្រូវបានគណៈតំបន់ឈ្មោះ ភួន នោះ គាត់បានប្រមូលយកទៅដាក់នៅក្នុងការដ្ឋាន មីងសេក ហើយឲ្យយោធាបាញ់រះពីខាងក្រៅការដ្ឋានហ្នឹង សម្លាប់ចោលទាំងអស់ ប៉ុន្តែអ្នកដែលស្លាប់ក្នុងនោះមានតែពីរនាក់ទេ អ្នករបួសប្រាំបីនាក់ ហើយអ្នកដែលរត់រួចអត់ដឹងប៉ុន្មានទេ ព្រោះ៧៥នាក់ ពួកហ្នឹងធាក់ជញ្ជាំងរត់ ត្រូវគេបាញ់ស្លាប់តាមផ្លូវម៉េចក៏អត់ដឹងដែរ។

[១១:៤០:៥៩]

អ៊ីចឹង គណៈសហករណ៍ឈ្មោះ ភួន ខ្ញុំឃើញគាត់នៅលលក-ស ក៏ឃើញគាត់ នៅវត្តហ្លួងក៏ឃើញ នៅព្រហស្បតិ៍ក្បាលក៏ឃើញ នៅទួលព្រះថ្មក៏ឃើញ ដោយឃើញគាត់នៅច្រើនកន្លែងអ៊ីចឹងខាងនាងខ្ញុំក៏កំណត់ថា គាត់ជាអ្នកធ្វើធំបំផុតនៅទីនោះ ចាស។

**សៈ** អរគុណលោកស្រី។ ក្រៅពីនាយ ភួន ដែលលោកស្រីបានលើកឡើងឈ្មោះអំមិញហ្នឹង តើមានអ្នកដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមណាខ្លះ ដែលលោកស្រីស្គាល់? ដែលលោកស្រីបានឮ?

**ឆៈ** អ្នកដឹកនាំខ្មែរក្រហមដែលនាងខ្ញុំបានឮ តែនាងខ្ញុំអត់ដែលបានឃើញទេ។ ធ្លាប់តែបានឮមាន តាម៉ុក មាន អៀង សារី មាន ខៀវ សំផន នួន ជា ចាស។ ហើយខ្ញុំបានតែឮទេ ឮគេនិយាយ ឮឈ្លប ឮមេកងគេនិយាយថា "ថ្ងៃនេះ លោក ម៉ុក ហ្នឹង ទៅធ្វើការនៅឯណា" ចាស ឮតែប៉ុណ្ណឹង។ តែមុខម៉េច ខ្ញុំអត់ស្គាល់ទេ។

[១១:៤២:១៧]

**ស៖** អរគុណលោកស្រី។ ចុះដែលនៅកន្លែងមូលដ្ឋានដែលលោកស្រីរស់នៅពោធិ៍សាត់ តើអ្នកណាជាអ្នកទទួលខុសត្រូវនៅកន្លែងនោះខ្លះ? លោកស្រីមានចាំឈ្មោះទេ គណៈសហករណ៍ តំបន់ ស្រុក ឬក៏ភូមិភាគ?

**ឆ៖** អ្នកដែលគ្រប់គ្រងនៅវត្តហ្លួងហ្នឹង ដែលនាងខ្ញុំស្គាល់មានឈ្មោះ តាសេម, យាយកប, យាយយ៉ាន, តាមាន ហើយនិង តាភួន។ ចាស ខ្ញុំស្គាល់មានប៉ុន្មាននាក់ហ្នឹងឯង។ ហើយបើ តាភួន យូរៗ ឃើញមុខគាត់តែម្ដង។ ប៉ុន្តែបើ តាសេម, យាយយ៉ាន, យាយកប, តាមាន ហ្នឹង ព្រោះឃើញញឹកញាប់ ចាស។

**ស៖** តើកន្លែងដែលលោកស្រីរស់នៅ តាភួន គ្រប់គ្រងរបៀបណាដែរ? ហើយជាមួយនារីៗយ៉ាងម៉េចដែរលោកស្រី?

[១១:៤៣:២៣]

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីបញ្ជាក់អំពីកាលវេលាផង យើងបានជម្រាបរំឭកហើយ យើងព្យាយាមមិនកាត់ យើងប្រើពាក្យរំឭកអំពីកាលបរិច្ឆេទនៃសំណួរដែលពាក់ព័ន្ធ អង្គហេតុដែលពាក់ព័ន្ធនឹងសំណួរ។ ពីព្រោះកាលវេលាដែលការជម្លៀសទៅដល់ ហើយនិងផលបច្ច័យនៃការទើបទៅដល់ថ្មីៗ វាអាចខុសឆ្ងាយពីហេតុការណ៍ដែលកើតឡើងនៅក្នុងអំឡុង៧៧ ឬ៧៨។ ជៀសវាងសំណួរដែលលោកស្រីប្រើប្រាស់ទៅគឺជាសំណួរក្រៅអង្គហេតុ ដែលអង្គជំនុំជម្រះកំណត់យកធ្វើសវនាការក្នុងសំណុំរឿង០០២/០១។ វាត្រឹមតែអត់ប្រយោជន៍ទេ គឺនឹងមានការជំទាស់ការតវ៉ា ឬក៏ការសង្កេតផ្សេងៗពីភាគីពាក់ព័ន្ធនៃរឿងក្ដីនេះទៀតផង។

**លោកស្រី ជេត វណ្ណលី៖**

សូមអរគុណលោកប្រធានដែលបានរំឭក។ ខ្ញុំអស់សំណួរហើយចាស។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១១:៤៤:៤៣]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** លោកស្រី ពេជ ស្រីផល ខ្ញុំមានសំណួរមួយចំនួនតូចទេ។ ខ្ញុំសូមលើកឡើងនូវការកត់សម្គាល់របស់លោកប្រធានជាចុងក្រោយ ហើយដោយសារតែពេលវេលានោះ គឺថាខ្ញុំចង់សួរថា មានអ្វីកើតឡើង ហើយកើតឡើងនៅក្នុងឆ្នាំណា? នៅក្នុងចម្លើយរបស់លោកស្រី លោកស្រីបានលើកឡើងអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ នៅថ្ងៃ១៧ មេសា ៧៥។ ខ្ញុំចង់សួរលោកស្រីពីពេលវេលាដែលលោកស្រីស្ថិតនៅក្នុងភូមិមួយរៀបរាប់ អំពីពេលវេលានៅភូមិព្រៃត្រប់។ តើខ្ញុំសុំសួរបញ្ជាក់ថា តើភូមិហ្នឹងឈ្មោះភូមិព្រៃត្រប់ ឬក៏ឈ្មោះភូមិគោកត្រប់?

**ផ៖** ចាស ពេលដែលពួកខ្ញុំចូលទៅនៅហ្នឹង អ្នកដែលគេនៅហ្នឹងមុនគេថា "ព្រៃត្រប់" តែនាងខ្ញុំអត់ដឹងថាភូមិអីទេ ខ្ញុំថាតាមគេដែរ។ ពួកមូលដ្ឋាននៅគេប្រាប់ខ្ញុំថា "ព្រៃត្រប់"។

[១១:៤៦:០៤]

**ស៖** តើខ្ញុំយល់ត្រឹមត្រូវទេនៅពេលដែលលោកស្រី នៅភូមិព្រៃត្រប់នៅក្នុងឆ្នាំ១៩៧៥? មានន័យថានៅក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ តើអ៊ីចឹងដែរ ឬយ៉ាងណា?

**ផ៖** ចាស នាងខ្ញុំរស់នៅក្នុងភូមិព្រៃត្រប់ហ្នឹង នៅក្រោយថ្ងៃ១៧ មេសា ឆ្នាំ៩៧៥(ស៊ីក)។

**ស៖** សូមអរគុណ។ ហើយនៅក្នុងចម្លើយរបស់លោកស្រី បន្ទាប់មកទៀត នៅពេលដែលលោកស្រីនៅភូមិ -- បាទ នៅភូមិស្វក់ គឺថាវានៅដើមឆ្នាំ -- ចុងឆ្នាំ៧៥ ឬក៏នៅដើមឆ្នាំ៧៦?

**ផ៖** នៅភូមិស្វក់ នៅចន្លោះចុងឆ្នាំ៧៥ និងដើមឆ្នាំ៧៦។

**ស៖** បើសិនណាលោកស្រីមិនអាចឆ្លើយបានមិនជាបញ្ហាអ្វីទេ ប៉ុន្តែថ្ងៃកំណើតរបស់លោកស្រីគឺខែតុលា តើលោកស្រីអាចចាំថ្ងៃ -- តើលោកស្រីអាចចាំថ្ងៃកំណើតហ្នឹងឲ្យបានច្បាស់លាស់ទាំងថ្ងៃខែឆ្នាំហ្នឹង -- បាទ លោកស្រីធ្វើខួបកំណើតនៅកន្លែងណាដែរ នៅក្នុងខែតុលាហ្នឹងចំថ្ងៃណាដែរ? នៅកន្លែងណាដែរ?

**ផ៖** នាងខ្ញុំមិនដែលបានធ្វើខួបកំណើតទេ ក៏ប៉ុន្តែនាងខ្ញុំសូមបញ្ជាក់ថានាងខ្ញុំកើតនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៥២ ហើយនៅភូមិស្វាយប៉ោ ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង។

**ស៖** បាទ សូមបន្តទៅទៀតលោកស្រី។ នៅក្នុងចម្លើយរបស់លោកស្រី នៅពេលដែលលោកនៅកំពង់ឆ្នាំងហ្នឹង លោកស្រីថាលោកស្រីទៅទីនោះនៅក្នុង -- ប្រហែលជានៅក្នុងឆ្នាំ១៩៧៦ តើអ៊ីចឹងត្រឹមត្រូវដែរឬទេ?

[១១:៤៨:៥២]

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** ហើយពាក់ព័ន្ធទៅនឹងការបន្តដំណើរពីកំពង់ឆ្នាំង ទៅខេត្តពោធិ៍សាត់ លោកស្រីថាការធ្វើដំណើរទៅខេត្តពោធិ៍សាត់នេះ គឺនៅក្នុងឆ្នាំ៧៧ តើត្រឹមត្រូវទេ?

**ឆ៖** នាងខ្ញុំអត់បានចាំទេ អត់ដឹងថាចិតប៉ុន្មានទេ អង្កាល់នុំង។

**ស៖** ហើយពាក់ព័ន្ធទៅនឹងពេលវេលា ដែលលោកស្រីរស់នៅកំពង់ឆ្នាំង លោកស្រីស្នាក់នៅកំពង់ឆ្នាំងប្រហែលជាអស់រយៈពេល១ឆ្នាំ តើត្រឹមត្រូវទេ?

**ឆ៖** ចាស រស់នៅកំពង់ឆ្នាំងហ្នឹង ប្រហែលជា១ឆ្នាំហើយចាស។

**ស៖** ដូច្នេះនៅពេលដែលលោកស្រីនៅក្នុង -- នៅកំពង់ឆ្នាំងឆ្នាំ១៩៧៦ ហើយស្នាក់នៅប្រហែល១ឆ្នាំ។ អ៊ីចឹងបើសិនណាជាលោកស្រីស្នាក់នៅទីនោះ១ឆ្នាំ ក្រោយឆ្នាំ១៩៧៥ គឺក្នុងឆ្នាំ៧៦នោះ តើទៅពោធិ៍សាត់ក្នុងឆ្នាំណាដែរ?

**ឆ៖** ចេញពីកំពង់ឆ្នាំងទៅៗពោធិ៍សាត់។

[១១:៥០:៣៧]

**ស៖** ខ្ញុំនិយាយអំពីឪពុករបស់លោកស្រី និងស្វាមី របស់លោកស្រីវិញម្តង។ លោកស្រីជម្រាបជូនអង្គជំនុំជម្រះសាលាដំបូងរួចហើយថា ប្ដីរបស់លោកស្រីគឺថាជាពេទ្យទាហាន លន់ នល់ ហើយឪពុករបស់លោកស្រីគឺថាជាគិញរបស់ លន់ នល់។ តើត្រឹមត្រូវទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** ខ្ញុំសូមសួរសំណួរមួយចំនួនឱ្យលោកស្រីបញ្ជាក់ អំពីពេលវេលាដែលលោកស្រីនៅកន្លែងប៉ុស្តិ៍ត្រួតពិនិត្យមួយគឺ ៣ថ្ងៃក្រោយពេលចេញពីទីក្រុងភ្នំពេញ។ នៅពេលដែលគេសុំឱ្យមានការចុះឈ្មោះដោយទាហានខ្មែរក្រហម បើសិនណាជាគេជាទាហាន លន់ នល់ ជាគ្រូ ជាវេជ្ជបណ្ឌិត។ លោកស្រីដឹងថា មានប្រជាជនប្រហែលជាប៉ុន្មាននាក់ដែរ ដែលបានប្រាប់កងទ័ពខ្មែរក្រហមថា ខ្លួនស្ថិតនៅក្នុងប្រភេទជាទាហាន លន់ នល់ ជាពេទ្យ លន់ នល់ ជាសាស្ត្រាចារ្យអីដូច្នេះ?

**ឆ៖** នាងខ្ញុំអត់ដឹងថា ប៉ុន្មាននាក់ទេចាស។

**ស៖** នៅពេលដែលគេសុំចុះឈ្មោះរបស់លោកស្រីនោះ តើឪពុករបស់លោកស្រីបាននិយាយនិងបានគិតថាម៉េចដែរ? ដោយសារថាគាត់ជាគិញរបស់ លន់ នល់ តើគាត់គិតយ៉ាងម៉េច ហើយបាននិយាយថាម៉េចដែរ?

[១១:៥២:២៩]

**ឆ៖** ពេលដែលគេសុំចុះឈ្មោះនៅភូមិព្រៃត្រប់ហ្នឹង ឪពុកនាងខ្ញុំអត់បានគិតអ្វីទាំងអស់ ព្រោះពេលនោះគាត់ឈឺ។ ចំណែកនាងខ្ញុំវិញ ខ្ញុំអត់បានទៅចុះឈ្មោះទេ ព្រោះនាងខ្ញុំអត់មានការងារអីជាមន្ត្រីរាជការឡើយ។

**ស៖** ខ្ញុំចង់ឲ្យលោកស្រីជួយខ្ញុំទៅលើចំណុចនេះ។ ខ្ញុំស្តាប់បានគឺថា ២, ៣ ថ្ងៃក្រោយពីការជម្លៀសចេញពីក្រុងភ្នំពេញ នៅពេលលោកស្រីបានធ្វើដំណើរពីរបីគីឡូម៉ែត្រ ទៅដល់ចំការដូងគឺថា គេបានស្នើឲ្យប្រជាជនចុះឈ្មោះ តើត្រឹមត្រូវអ៊ីចឹង ឬក៏អត់?

**ឆ៖** មិនមែនស្នើនៅនឹងចំការដូងហ្នឹងទេ។ ទៅហួសពីចំការដូងប្រហែលជា១គីឡូជាងទៀត បានមានការស្នើឲ្យប្រជាជនចុះឈ្មោះមកធ្វើការនៅភ្នំពេញវិញ។

**ស៖** តើគេបានសួរប្រជាជនតែក្នុងមួយពេលនោះ ឬក៏គេបានសួរប្រជាជននៅពេលក្រោយៗមកទៀតស្នើសុំឲ្យចុះឈ្មោះហ្នឹង?

**ឆ៖** ពេលក្រោយទៀត នាងខ្ញុំអត់ដឹងថា គេស្នើ ឬក៏អត់ទេ ប៉ុន្តែខ្ញុំដឹងនៅពេលដែលខ្ញុំដើរកាត់ទីនោះ។

**ស៖** ខ្ញុំសូមផ្តោត -- ឲ្យលោកស្រីផ្តោតទៅលើពេលវេលាណា ដែលលោកស្រីអាចចាំបាន។ លោកស្រីបាននិយាយថា ឪពុករបស់លោកស្រីមិនបានចូលរួមប្រជុំ ដែលគេហៅប្រជាជន១៧មេសាទាំងអស់ ឲ្យចូលរួមប្រជុំ តែឪពុកលោកស្រីមិនទៅចូលរួមប្រជុំនោះទេ។ តើហេតុអ្វី?

[១១:៥៥:០២]

**ឆ៖** នៅពេលដែលគេហៅអ្នក១៧មេសា ឲ្យចូលរួមប្រជុំ ហើយឪពុកនាងខ្ញុំអត់ចូលរួមប្រជុំនោះ ដោយសារទី១ ឪពុកនាងខ្ញុំគាត់មានវិទ្យុទាក់ទង។ គាត់ដឹងពីស្ថានភាពប្រទេសជាតិ។ គាត់អត់ចូលទេ ទី១។ ទី២ ថ្ងៃហ្នឹងគាត់មានបញ្ហាសុខភាពខ្លួនគាត់។ គាត់អត់បានមកមើលកន្លែងដែលគេហៅចុះឈ្មោះហ្នឹងទេ។

**ស៖** តើស្វាមីរបស់លោកស្រី ក៏ដូចលោកស្រី និងឪពុកលោកស្រី ប្តីលោកស្រីគឺថា មានៗចូលរួមនៅក្នុងប្រជុំហ្នឹង -- អត់ចូលទាំងអស់គ្នា ឬក៏មានចូលរួមខ្លះ?

**ឆ៖** ក្នុងពេលប្រជុំនោះ គ្រួសារខ្ញុំអត់ចូលរួមទេ។ ក៏ប៉ុន្តែខ្ញុំដែលខ្ញុំថា ខ្ញុំជាអ្នកថ្មី ជាប្រជាជនជាអ្នករកស៊ីលក់ដូរធម្មតា ខ្ញុំបានទៅស្ដាប់គេ។ ចំណែកក្រុមគ្រួសារខ្ញុំអត់មានអ្នកណាទៅទេ មានតែខ្ញុំម្នាក់ឯងទេ ដែលចូលទៅស្ដាប់ការប្រជុំ ហើយប្រជុំហ្នឹងបើយើងមិនទៅស្ដាប់ក៏ឮដែរ ព្រោះគេដាក់មីក្រូ។

**ស៖** នៅពេលដែលខ្មែរក្រហម ចង់ដឹកជញ្ជូនប្រជាជនត្រឡប់មកក្រុងភ្នំពេញវិញ តើប្ដីរបស់លោកស្រី និងឪពុករបស់លោកស្រី ពេញចិត្តពេញថ្លើមប្រាប់ខ្មែរក្រហមថា គាត់ជាគ្រូពេទ្យ ជាពេទ្យទាហាន និងជាគិញរបស់ លន់ នល់ ដែរឬទេ?

**ឆ៖** ពេលដែលគេដឹកអ្នកដែលចុះឈ្មោះទាំងអស់ ថាចូលមកភ្នំពេញនោះ ឪពុកនាងខ្ញុំ និងប្ដីនាងខ្ញុំមិនបានប្រាប់ពួកទាហានខ្មែរក្រហមទាំងអស់នោះ ថាគាត់មានតួនាទីជាអ្វីទេ។ ចាស អត់បានប្រាប់គេទាំងអស់ គឺយើងលាក់ប្រវត្តិ អត់ឱ្យនរណាដឹងទេ។

**ស៖** ហេតុអ្វី?

[១១:៥៧:៣៩]

**ឆ៖** ព្រោះថា ទី១ យើងមិនចង់រស់នៅបែកគ្នា។ យើងឃើញគេដឹកតាមផ្លូវ គេយកតែប្ដីៗដែលទៅចុះឈ្មោះ ថាអ្នកធ្វើការហ្នឹង គេយកតែអ្នកដែលធ្វើការទៅ ចំណែកប្រពន្ធកូនគេអត់ឱ្យទៅ។ ហ្នឹងយើងឃើញទី១។ បន្ទាប់មកទៀតនៅដល់កន្លែងនោះ ដូចខ្ញុំជម្រាបអ៊ីចឹងថា លោកពុកខ្ញុំគាត់មានខ្សែរយៈទាក់ទងតាមវិទ្យុ អ៊ីចឹងគាត់ដឹងសភាពការណ៍ស្រុកទេសមួយចំនួនដែរ។ ដូច្នេះ គាត់មិនបានប្រាប់គេឱ្យដឹងពីស្ថាប័នដែលគាត់រស់នៅទេ។ ចាស ចំណុចហ្នឹង គឺអ៊ីចឹង។

**ស៖** តើគ្រោះថ្នាក់អ្វី?

**ឆ៖** ដែលយើងសង្ស៊ឹមថា នឹងមានគ្រោះថ្នាក់នោះ ព្រោះសកម្មភាពតាំងពីចេញពីភ្នំពេញមក គឺឃើញសកម្មភាពរបស់ពួកទាហាន ដែលស្លៀកឈុតខ្មៅហ្នឹង មានសកម្មភាពអហិង្សា អ៎! មានសកម្មភាពហិង្សាតាំងពីក្នុងមក។ ចាស ត្រូវវ៉ៃៗ ត្រូវបាញ់ៗ ចាស មកតាមផ្លូវអត់មានអនុគ្រោះដល់ប្រជាពលរដ្ឋដែលជម្លៀសមកតាមផ្លូវទេ គឺអ្នកណាឈឺទុកចោលកន្លែងហ្នឹង អ្នកណាស្លាប់ទុកចោលកន្លែងហ្នឹង ហើយឱ្យដើរទៅតាមផ្លូវរហូត ហើយនៅតាមផ្លូវទៀត គេយើងដឹងថា គេកុហកយើងដោយសារគេប្រាប់ថា ៣ថ្ងៃឱ្យយើងចូលវិញ តែយើងចាំ៣ថ្ងៃក៏មិនឃើញ ១អាទិត្យក៏មិនឃើញ ១០ថ្ងៃក៏មិនឃើញ ឃើញតែដេញឱ្យដើរទៅៗ អត់មានទិសតំបន់អីទាំងអស់។ ដូច្នេះ អាការទុកចិត្តនោះ សេចក្ដីទុកចិត្តថា

ទាហានខ្មែរក្រហម នឹងផ្ដល់ភាពកក់ក្ដៅឲ្យពួកយើងត្រឡប់មកភ្នំពេញវិញ រស់នៅសុខដុមតាមក្រុមគ្រួសារ ពួកយើងអត់ជឿ។

**ស៖** ចាតើប្ដីលោកស្រី ហើយនិងឪពុកលោកស្រីហ្នឹង គាត់ខ្លាចយ៉ាងម៉េចដែរ ខ្លាចពីរឿងអីដែរ?

**ឆ៖** ចាស គាត់ៗ សរុបសេចក្ដីទៅគាត់ជាអ្នកនយោបាយ។ គាត់ដឹងថាលោក លន់ នល់ រត់ចោលប្រទេសទៅបាត់ហើយ។ ដូច្នេះ ពួកគាត់កំប៉ិកកំប៉ុកអ៊ីចឹង បើគាត់ចូលមកវិញ ក៏វាអត់បានសុខដែរចាស។ ហើយចំណុចមួយទៀត ប្ដីនាងខ្ញុំ មូលហេតុដែលគាត់អត់មកវិញ ដោយសារគាត់ជាពេទ្យទាហាន។ គាត់ជាពេទ្យទាហានហ្នឹង គាត់ក៏មិនមែនជាមេពេទ្យដែរ គាត់ជាអ្នកយាមឃ្លាំងថ្នាំចាស។ អ៊ីចឹងតួនាទីនោះ ក៏មិនមែនជាធំដុំប៉ុន្មានដែរ។ ហើយចំណុចមួយទៀតគំនិតពួកយើងចង់ស្រូតទៅឲ្យដល់ស្រុកទេសឪពុកម្ដាយក្មេកនោះ ក្រែងលោវាបានសុខ យើងអត់ដឹងថាទៅដល់ហ្នឹងវាមានរឿងអ៊ីចឹងទៀតទេ។ ចាស ចំណុចទាំងអស់ហ្នឹង ពួកយើងគិតថា អ៊ីចឹងបានជាយើងមិនព្រមបែកគ្នា។

[១២:០១:០២]

**ស៖** ពូ និងជីដូនមួយរបស់លោកស្រី ដែលបានប្រាប់ខ្មែរក្រហម ថាពួកគាត់ហ្នឹងគឺជាទាហាន ហើយពួកគាត់ក៏ត្រូវបានគេយកទៅបាត់ទៅ។ តើលោកស្រីបានជួបពួកគាត់ក្រោយមកទៀតទេ?

**ឆ៖** ពួកខ្ញុំបានជួបអ៊ំខ្ញុំហ្នឹង នៅតាមផ្លូវដែលគេដឹកឡាន ព្រោះ ដូចខ្ញុំបានជម្រាបអ៊ីចឹង អាឡាំប្រឹតាអស់សាំងនៅឈប់។ ហើយអ៊ំខ្ញុំ ពូខ្ញុំហ្នឹង គាត់ជិះនៅឡើអាឡានៗធំៗគេហ្នឹង គាត់មកដល់គាត់ឃើញពួកខ្ញុំនៅនឹងផ្លូវហ្នឹង គាត់បានស្រែកថា អាវ៉ាអើយ អញទៅមុនហើយ អ្នែងចាំទៅតាមក្រោយ ទៅអញចូលទៅភ្នំពេញមុនអ្នែងហើយ។ អាហ្នឹង ខ្ញុំឃើញគាត់កន្លែងត្រង់ហ្នឹងឯង។

**ស៖** តើអ៊ំ និងជីដូនមួយរបស់លោកស្រីហ្នឹង គឺនៅរស់រានមានជីវិតទេក្រោយឆ្នាំ១៩៧៩?

**ឆ៖** ក្រោយឆ្នាំ១៩៧៩ អ៊ំខ្ញុំ ពូខ្ញុំ ប្អូនជីដូនមួយខ្ញុំអីហ្នឹង អត់មាននៅរស់រានមានជីវិតទេ។ ខ្ញុំនៅសល់តែបងជីដូនស្រីមួយ ដែលជាកូនរបស់អ៊ំខ្ញុំហ្នឹង ដោយសារពេលនោះ គាត់ជម្លៀសដែរ តែគាត់អត់បានទៅជាមួយខ្ញុំទេ មិនដឹងគាត់ទៅជម្លៀសទៅខាងណាទេ យើងទើបនឹងបានជួបគ្នានៅភ្នំពេញហ្នឹង ហើយគាត់ក៏បានប្រាប់ថា អស់ហើយអត់មានសល់អ្នកណាទេចាស។

**ស៖** បុរសម្នាក់ ដែលជិះរទេះគោ ដែលបររទេះគោ ហើយប្រាប់ថា អ្នកដែលគេដឹកជញ្ជូននោះ គឺថា អ្នកដែលបានចុះឈ្មោះនោះ គឺ -- ហើយថាដឹកទៅភ្នំពេញគឺ មិនបានដឹកទៅភ្នំពេញទេ តែត្រូវបាន

គេយកទៅសម្លាប់ចោល។ តើគាត់បានប្រាប់ថា គេសម្លាប់នៅទីណា ហើយគេសម្លាប់ដោយរបៀបណាដែរទេ?

[១២:០៣:៣៣]

**ឆ៖** ពូម្ចាស់រទេះគោនោះ មិនបានប្រាប់ថាសម្លាប់ដោយរបៀបណា នៅទីណាទេ។ គាត់គ្រាន់តែចង្អុលប្រាប់ថា កុំទៅទៀតៗ។ អ្នកដឹកទៅអំមិញហ្នឹង ងាប់អស់ហើយ គាត់ប្រាប់អ៊ីចឹង ហើយគាត់ថា គាត់ក៏អ្នក១៧ដែរ គាត់ក៏មូលដ្ឋានដែរ។ ក៏ប៉ុន្តែគាត់ហ្នឹង ក៏ចេះអ្នកធម៌អ្នកអាចារ្យដែរ ដូច្នេះអ៊ំឯងហ្នឹងក្រុមគ្រួសារហ្នឹងរត់ទៅកុំទៅមុខទៀត។ ចាស គាត់បានប្រាប់ថាអ៊ីចឹង។

**សៈ** នៅពេលដែលលោកស្រីទៅពោធិ៍សាត់ លោកស្រីនិយាយថា ឪពុកម្តាយរបស់លោកស្រីត្រូវបានគេបញ្ជូនទៅទីកន្លែងមួយផ្សេង។ តើឪពុក និងម្តាយរបស់លោកស្រី នៅរស់រានមានជីវិតទេក្រោយឆ្នាំ១៩៧៩?

**ឆ៖** ក្រោយឆ្នាំ១៩៧៩ នៅរស់តែម្តាយទេ ឪពុកនាងខ្ញុំស្លាប់ក្នុងរបប៣ឆ្នាំ ៨ខែហ្នឹងបាត់ទៅហើយ។

[១២:០៤:៥៨]

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន ខ្ញុំឃើញថា ពេលវេលាគឺម៉ោងដប់ពីរ ប្រាំនាទីហើយ ខ្ញុំមានសំណួរមួយចំនួនតូចទៀត ថាតើអង្គជំនុំជម្រះអនុញ្ញាតឲ្យខ្ញុំបន្តសួរបន្តទៅទៀត ឬក៏អនុញ្ញាតឲ្យខ្ញុំសួរក្រោយពេលពិសាបាយថ្ងៃត្រង់ហើយ ដោយសារខ្ញុំយល់ឃើញថា ខ្ញុំបាត់បង់ពេលវេលាអស់១៤នាទី។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

តើលោកទំនងជាត្រូវការពេលវេលាប៉ុន្មានទៀត លោកតំណាងសហព្រះរាជអាជ្ញា?

**លោក ឃីត រេយ៍ន័រ៖**

ខ្ញុំត្រូវការតែ៥នាទីទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបន្ត!

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** លោកស្រី ពេជ ស្រីផល នៅពេលដែលលោកស្រីនៅឯភ្នំស្វក់ ហើយនៅក្នុងចម្លើយរបស់លោកស្រី ពាក់ព័ន្ធទៅនឹងអំឡុងពេលនេះឯង។ ខ្ញុំសូមដកស្រង់ "នៅពេលដែលប្រជាជនទៅរកចំណីអាហារ ទាហានខ្មែរក្រហមនៅជើងភ្នំនោះគឺថាបានបាញ់សម្លាប់ប្រជាជនទាំងនោះ" តើអ៊ីចឹងមែនទេ?

**លោកស្រី ពេជ ស្រីផល៖**

**ឆ៖** ចាស ទាហានខ្មែរក្រហម ដែលបាញ់សម្លាប់នោះ គឺបាញ់សម្លាប់អ្នកដែលលួចចុះពីភ្នំមករកអាហារនៅតាមភូមិចាស។ អ៊ីចឹង មិនមែនបាញ់ប្រជាជនឲ្យទៅនៅជើងភ្នំ ឲ្យតែឃើញបាញ់ទាំងអស់ទេ។ គេចាំបាញ់តែអ្នក ដែលលួចចុះពីភ្នំចំនួន៥០នាក់ ដែលបានដឹកឡើងទៅដាក់ចោលនៅលើភ្នំនោះតែប៉ុណ្ណោះឯង។

**ស៖** តើប្រជាជននោះចុះពីលើភ្នំមករកចំណីអាហារនៅខាងក្រោមហ្នឹង ញឹកញាប់ប៉ុនណាដែរ?

[១២:០៧:១៤]

**ឆ៖** ពេលដែលឡើងទៅហ្នឹង ពួកយើងអត់ទាន់ចុះទេចាស។ រស់នៅទីនោះបានប្រហែលជា៤-១០ថ្ងៃ ហើយដល់ពេលអស់ស្បៀង ដែលសាច់ញាតិបងប្អូនបានឲ្យទៅនៅ ដល់អស់អ៊ីចឹងទៅនាំគ្នារក ហើយក៏អត់ដឹងថា ចុះមកហ្នឹងគេបាញ់ដែរ។ នៅពេលដែលចុះមកអ៊ីចឹង ដល់ឃើញមានគេបានបាញ់ស្លាប់មួយ។ ដូច្នេះអ្នកដទៃទៀតអត់ហ៊ានចុះទេ ចាស លែងហ៊ានចុះហើយ នាំគ្នារកស៊ីទៅតាមអ្វីដែលអាចរកបាននៅលើភ្នំហ្នឹង រកទៅ។ ប៉ុន្តែមានអ្នកខ្លះមកថ្ងៃក្រោយទៀត មានអ្នកខ្លះដែលទ្រាំមិនបានដោយសារភាពស្រេកឃ្លាន បើបានហូបតែមួយម៉ាត់ក៏អស់ចិត្តដែរនោះ ប្រថុយចុះមកទៀត។ ជួនកាលឈ្លបឆកល្វែងដែរ អត់ឃើញ គាត់រួចខ្លួន មានថ្ងៃខ្លះគាត់ចុះមកចំមុខគេហ្នឹង ក៏គេបាញ់សម្លាប់ទៀតទៅ។ ចាស រឿងហ្នឹងអ៊ីចឹង។

**ស៖** លោកស្រី ខ្ញុំសូមឲ្យលោកស្រីផ្តង់អារម្មណ៍ទៅសំណួររបស់ខ្ញុំបន្តបន្ទាប់នេះគឺ ជាពិសេសពេលវេលាដែលលោកស្រីបានទៅដល់ខេត្តពោធិ៍សាត់ ដែលលោកស្រីធ្វើដំណើរពីកំពង់ឆ្នាំងឆ្ពោះទៅកាន់ខេត្តពោធិ៍សាត់។ លោកស្រីបានបញ្ជាក់អំពីពេលវេលាថា នៅពេលដែលលោកស្រីត្រូវបានគេយកទៅសម្លាប់ចោល តើរយៈពេលប៉ុន្មានដែរ ក្រោយពីលោកស្រីទៅដល់ពោធិ៍សាត់ ដែលគេយកលោកស្រីទៅសម្លាប់ចោលនោះ?

**ឆ៖** ដែលខាងទាហានខ្មែរក្រហម មានបំណងយកនាងខ្ញុំទៅសម្លាប់ចោលនោះ គឺនៅរដូវច្រូតកាត់ចាស នៅរដូវច្រូតកាត់ ហើយនៅក្នុងឆ្នាំ -- ក្នុងចុងឆ្នាំ១៩៧៧។

**ស៖** ហើយសំណួរនេះ ប្រហែលជាអាចពិបាកឲ្យលោកស្រីឆ្លើយបន្តិច។ លោកស្រីអាចនឹកមើលថាតើរយៈពេលប៉ុន្មានខែដែរ ក្រោយពេលលោកស្រីបានទៅដល់ពោធិ៍សាត់? ហើយដែលគេយកហើយដែលគេយកលោកស្រីទៅសម្លាប់ចោលនោះ?

[១២:១០:១៣]

**ឆ៖** ពេលដែលនាងខ្ញុំទៅដល់ពោធិ៍សាត់ មិនមែនរយៈពេលប៉ុន្មានខែទេ គឺនៅទីនោះ យើងបានទៅធ្វើការដកស្ទូង លើកភ្លឺស្រែ រហូតដល់ចុងឆ្នាំ៧៧ ឬក៏ចូលដល់ដើមឆ្នាំ៧៨ ហើយ ដល់ពេលនោះហើយទើបមានសកម្មភាពដែលថា ដោយសារនាងខ្ញុំនេះមិនស្តាប់គោលការណ៍របស់គេ លួចរត់ចេញពីការប្រជុំមួយនៅក្នុងចម្ការដើម្បីយកថ្នាំមកឲ្យប្តីលេខនៅឯវត្តហ្លួងចាស។

**ស៖** សុំអធ្យាស្រ័យលោកស្រី ខ្ញុំមិនចង់កាត់លោកស្រីទេ មិនមែនមានន័យថាខ្ញុំមិនមានការគួរសមនោះទេ។ លោកស្រី ពេជ ស្រីផល ខ្ញុំចង់សួរបញ្ហាដែលកើតទៅលោកស្រី ក្រោយពីលោកស្រីទៅដល់ពោធិ៍សាត់ភ្លាមៗនោះ។ តើហេតុការណ៍នេះ ដែលលោកស្រីគិតថា គេយកលោកស្រីទៅសម្លាប់ចោល។ តើវាកើតភ្លាមៗក្រោយពេលដែលលោកស្រីទៅដល់ពោធិ៍សាត់ ឬក៏យ៉ាងណា?

[១២:១១:៣២]

**ឆ៖** វាមិនបានកើតភ្លាមនៅពេលដែលនាងខ្ញុំទៅដល់ពោធិ៍សាត់ទេ វាកើតនៅពេលដែលយើងធ្វើការនៅពោធិ៍សាត់បានចូល ១ឆ្នាំកន្លះអីហើយបានកើត។ ព្រោះពេលដែលនាងខ្ញុំទៅដល់ពោធិ៍សាត់ភ្លាមៗ គឺនាងខ្ញុំចូលទៅនៅក្នុងកងជីកប្រឡាយវត្តហ្លួង ក្នុងពេលនោះអត់មានអ្នកណាសម្លាប់ទេ គ្រាន់តែបង្អត់អាហារ និងប្រើឲ្យធ្វើការធ្ងន់ធ្ងរតែប៉ុណ្ណោះឯង។

**ស៖** ដោយសារតែចម្លើយរបស់លោកស្រីនេះ គឺថាខ្ញុំឈប់សួរលោកស្រីពាក់ព័ន្ធទៅនឹងពេលវេលានេះហើយ។ លោកស្រីបានបង្ហាញភស្តុតាងជូនអង្គជំនុំជម្រះថា ពាក់ព័ន្ធទៅនឹងការកសាងលត់ដំខ្លួន អ្នកខ្លះក៏ត្រូវបានគេសម្លាប់ចោលនៅពេលដែលគេបញ្ជូនទៅកាន់មន្ទីរលត់ដំកែប្រែ តើការណ៍នេះកើតមានឡើងភ្លាមៗ ក្រោយពេលដែលលោកស្រីទៅដល់ខេត្តពោធិ៍សាត់ ឬក៏យ៉ាងណា?

**ឆ៖** មិនបានកើតភ្លាមៗនៅពេលដែលនាងខ្ញុំទៅដល់ទេ។

**ស៖** សូមអរគុណលោកស្រី ពេជ ស្រីផល ខ្ញុំសុំសួរខ្លីទេ។ បាទ លោកស្រីខ្ញុំអស់សំណួរអ្វីដែលត្រូវសួរលោកស្រីហើយ។ សូមអរគុណលោកប្រធាន។

[១២:១៣:២៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ចាប់ពីពេលនេះតទៅរហូតដល់ដល់ម៉ោងមួយសាមសិបនាទីរសៀល អញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដើមបណ្តឹងរដ្ឋប្បវេណី ដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាកពិសាអាហារ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញនៅពេលរសៀល នៅវេលាម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

**លោក អេនគ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជម្រាបលោកប្រធានថា កូនក្តីខ្ញុំ គឺថាមិនស្រួលខ្លួនទេ គាត់ឈឺក្បាល ឈឺខ្នង និងបាត់បង់ការផ្តង់អារម្មណ៍។ ដូច្នេះ សុំការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីឲ្យកូនក្តីយើងខ្ញុំបានចូលទៅបន្ទប់ខាងក្រោមដើម្បីតាមដានដំណើរការនីតិវិធីនៅពេលរសៀលនេះ។ សូមអរគុណ។

[១២:១៤:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ ស្នើសុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលធ្វើសវនាការនៅរសៀលថ្ងៃនេះ ដោយមូលហេតុមានបញ្ហាសុខភាពមិនអាចអង្គុយតាមដានកិច្ចដំណើរការសវនាការផ្ទាល់ក្នុងបន្ទប់សវនាការបាន។ ហើយសំណើសុំនេះមាន -- ធ្វើឡើងមានហេតុផលសមស្រប អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ។ ដោយលោក នួន ជា លះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះ។ អង្គជំនុំជម្រះតម្រូវឲ្យមេធាវីការពារក្តីលោក នួន ជា ប្រគល់ជូនមកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយ

ផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃយ៉ាងជាក់ច្បាស់របស់លោក នួន ជា។

បង្គាប់ឲ្យបគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការនៅរសៀលថ្ងៃនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និងលោក ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដោយនៅរសៀលនេះ ទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍ សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់ឡើងត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ ឲ្យបានមុនម៉ោងមួយសាមសិបនាទីរសៀលនេះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:១៦ នាទី ដល់ម៉ោង ១៣:៣៥ នាទី)*

[១៣:៣៥:០៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងសូមប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ! សូមគោរពលោកប្រធាន!

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សុន អរុណ៖**

**ស៖** សូមជម្រាបសួរអ្នកស្រី ពេជ ស្រីផល។ ខ្ញុំជា -- ខ្ញុំឈ្មោះ សុន អរុណ មេធាវីរបស់លោក នួន ជា។ ខ្ញុំមានសំណួរមួយចំនួន មិនច្រើន ប្រហែលបីបួន សួរទៅលោកស្រីនៅថ្ងៃនេះ។ ជាដំបូង ខ្ញុំចង់

ដឹងលោកស្រីកាលពីនៅក្នុងឯកសារ ដែលលោកស្រីបានធ្វើសម្ភាសជាមួយនឹងចៅក្រមស៊ើបអង្កេត។ ហើយលោកស្រីបានជម្រាបថា បាន -- លោកស្រីបានចេះអាន ចេះសរសេរ។ ប៉ុន្តែលោកស្រីបានរៀនដល់ថ្នាក់ណាដែរ? ថ្នាក់ចុងក្រោយបំផុត?

**លោកស្រី ពេជ ស្រីផល៖**

**ផ៖** ចាស អរគុណលោកមេធាវីការពារក្តី។ នាងខ្ញុំរៀនចប់នៅថ្នាក់ទី១ បើសិនជាយើងនិយាយឲ្យចំទៅថា បាក់ឌុប ក្នុងឆ្នាំ១៩៧៤។

**ស៖** អរគុណ។ លោកស្រីបានជម្រាបទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណីព្រឹកមិញថា ឪពុកលោកស្រីជាគិញរបស់ លន់ នល់ ឬក៏ ស៊ី.អាយ.អេ។ ពាក្យទាំងពីរហ្នឹងយ៉ាងម៉េច? សូមឲ្យបំភ្លឺជាគិញ ឬ ស៊ី.អាយ.អាយ បន្តិចមើល៍?

**ផ៖** ចាស អរគុណ។ ឪពុកនាងខ្ញុំគឺជាគិញនៅក្នុងរបប លន់ នល់ នោះ។ មិនមែនជា ស៊ី.អាយ.អេ អីទេ។ គាត់ជាគិញ ហើយមានតួនាទីតូចតាចនៅក្នុងអង្គភាពរបស់គិញហ្នឹងចាស។

**ស៖** សូមអរគុណ។ នៅពេលដើមឆ្នាំ១៩៧៥ មកដល់ដើមឆ្នាំ១៩៧៥ ពេលនុ៎ងអ្នកស្រីមានចាំ ឬក៏ដឹងទេថា ប្រជាពលរដ្ឋខ្មែរដែលភៀសខ្លួនចូលក្រុងភ្នំពេញមានប្រហែលប៉ុន្មានទេ?

[១៣:៣៨:៣៨]

**ផ៖** ចាស អរគុណ។ ក្នុងឆ្នាំ១៩៧៥ មុនថ្ងៃរំដោះរបស់កងទ័ពខ្មែរក្រហម ប្រជាជនពលរដ្ឋនាងខ្ញុំឃើញមានចំនួនកើននៅក្នុងទីក្រុងភ្នំពេញមែន។ ក៏ប៉ុន្តែបើមានចំនួនប៉ុន្មាននោះ នាងខ្ញុំមិនអាចក្តាប់ស្ថិតិប្រជាជនដែលកើននៅទីក្រុងភ្នំពេញបានទេ ចាស។

**ស៖** អ្នកស្រីអាចថាបានថា ចំនួនពីរដងលើសកាលពីសម័យមុនឆ្នាំ៧០ទេ ឬក៏មួយដងកន្លះ អាចថាអ៊ីចឹងបានទេ?

**ផ៖** អត់ច្បាស់លាស់អ៊ីចឹង។ នាងខ្ញុំអត់អាចថាបានទេ ចាស។

**ស៖** អរគុណ។ លោកស្រី ឪពុកលោកជាគិញរបស់របប លន់ នល់ ប្រហែល -- ខ្ញុំមិននិយាយពាក្យប្រហែលទេ។ ជាញឹកញាប់ពីព្រឹកមិញ លោកស្រីបានជម្រាបអង្គសវនាការថា ព័ត៌មានពីឪពុកលោកមានច្រើនណាស់បានប្រាប់មកគ្រួសារ ពីព័ត៌មានផ្សេងៗ។ លោកស្រីមានដែលឮឪពុកលោកនិយាយអំពីប្រជាជនទាំងស៊ីវិល ទាំងទាហាន ទាហានទាំងសងខាង ទាំង លន់ នល់ ទាំងខ្មែរក្រហមច្បាំងគ្នារយៈ៥ឆ្នាំនុ៎ង មានស្លាប់ប៉ុន្មានទេ?

**ឆ៖** ចាស ចំពោះសំណួរនេះ នាងខ្ញុំអត់ក្តាប់បានថា ស្លាប់ប៉ុន្មាននាក់ទេ ហើយឪពុកនាងខ្ញុំក៏អត់បានប្រាប់ដែរចាស។

**ស៖** អ្នកស្រីអត់ដែលបានមើលកាសែត ឬក៏ទស្សនាវដ្តីអ្វីដែលនិយាយអំពីប្រជាជនស្លាប់ ឬរបួសនៅពេលនុំងទេ?

**ឆ៖** ចាស ពេលនោះ ជីវភាពនៅក្នុងក្រុមគ្រួសារមានការខ្វះខាត។ ដូច្នេះអត់មានឱកាសក្នុងការទិញកាសែតយកមកអានទេ ហើយក៏ខ្ញុំសូមជម្រាបឲ្យត្រង់ចុះ បើកាសែតមាន ខ្ញុំអានតែរឿងទេ អត់ដែលអានព័ត៍មានអីទាក់ទងនឹងប្រទេសជាតិទេចាស។

[១៣:៤១:៤៣]

**ស៖** អរគុណសាក្សី។ នៅក្នុងឯកសារ D226/10 នៅសំណួរនិងចម្លើយជាមួយចៅក្រមស៊ើបអង្កេត លេខចម្លើយរបស់អ្នកស្រីលេខ៤ អ្នកស្រីបានឆ្លើយថា "នៅថ្ងៃខ្មែរក្រហមជម្លៀសប្រជាជនចេញពីភ្នំពេញ នៅឆ្នាំ១៩៧៥ ក្រោយពេលដែលគេបានបាញ់កាំភ្លើងឡើងទៅលើ ហើយនៅមិនចេញៗពីភ្នំពេញទៀត។ ហ្នឹងចង់និយាយថាប្រជាជនហ្នឹងមិនព្រមចេញពីភ្នំពេញទៀត នោះទាហានខ្មែរក្រហមនឹងវាយនឹងស្វាយកាំភ្លើង"។ ខ្ញុំ -- អ្នកស្រីបាននិយាយថា "ខ្ញុំបានឃើញព្រឹត្តិការណ៍ផ្ទាល់នៅម្តុំផ្សាររឃ្លាំងរំសេវ"។ ត្រង់ចំណុចនេះ លោកស្រីបានឃើញមួយកន្លែងហ្នឹងហើយ បន្តទៅទៀត លោកស្រីបានឃើញព្រឹត្តិការណ៍របៀបនេះទៀតទេ?

**ឆ៖** ចាស កាលៗដែលទាហានខ្មែរក្រហមវាយធ្វើបាបប្រជាជនដែលប្រឆាំងមិនព្រមចេញពីទីក្រុងភ្នំពេញនោះ គឺនាងខ្ញុំបានឃើញចំពោះតែគ្រួសារមួយដែលនៅជិតផ្ទះនាងខ្ញុំទេ។ ចំណែកសកម្មភាពដទៃទៀត ដែលចេញទៅតាមផ្លូវ គឺឃើញទៅតាមលក្ខណៈដែលពួកជម្លៀសត្រឡប់ថយក្រោយវិញចង់មកក្នុងទីក្រុងភ្នំពេញ ដើម្បីប្រមូលនូវសម្ភារៈ ឬក៏គេមកយកអ្វីមួយដែលជាវត្ថុចាំបាច់របស់គេនោះក៏ឃើញទាហានខ្មែរក្រហមហ្នឹងកាក់មិនឲ្យមកដែរ។ ហើយមានអ្នកខ្លះនៅតាមផ្លូវនៅពេលដែលមានសាច់ញាតិរបស់គាត់ឈឺមិនទៅមិនរួច គាត់ទាមទារសុំនៅកំដរ ក៏ឃើញទាហានខ្មែរក្រហមបង្ខំឲ្យចេញដោយកំហែង ដោយបាញ់ទៅលើ ដោយសម្លុត គឺថាមិនឲ្យនៅទេ។ សកម្មភាពវ៉ៃនឹងស្វាយកាំភ្លើងគឺខ្ញុំឃើញនៅក្នុងម្តុំផ្សាររំសេវវេលាចន្លោះពីម៉ោងដប់ពីរថ្ងៃត្រង់ទៅម៉ោងបី ចន្លោះដែលពេលយើងចេញ។ ចាស ឃើញតែប៉ុណ្ណឹងទេចាស។

[១៣:៤៤:១៤]

**ស៖** ចំណុចខ្ញុំសួរអំមិញថា អ្នកស្រីបានឃើញតែមួយកន្លែងហ្នឹងទេ តែមួយហ្នឹងទេ ករណីព្រឹត្តិការណ៍បែបនេះ។ រួចពីហ្នឹងទៅឃើញមានព្រឹត្តិការណ៍ណាផ្សេងរបៀបៗអ៊ីចឹងទៀតទេ មានវ៉ៃនឹងកាំភ្លើង បាញ់អ៊ីចឹង គឺផ្ទាល់ភ្នែកទេ?

**ឆ៖** ចាស ឃើញផ្ទាល់ភ្នែកនៅកន្លែងដែលលោកមេធាវីការពារក្ដីលោកសួរអំមិញហ្នឹង ឃើញចាស។ ចំណែកតាមផ្លូវដែលចេញទៅ ដូចខ្ញុំជម្រាបអ៊ីចឹង ថាខ្ញុំបានឃើញ ប៉ុន្តែវាមិនមែនមានលក្ខណៈវ៉ៃដូចគ្នាអ៊ីចឹងទេ វាមានលក្ខណៈខុសៗគ្នា។ ចាស នៅភ្នំពេញវ៉ៃនឹងស្នាយកាំភ្លើង ចេញទៅតាមផ្លូវមានការបាញ់សម្លុតទៅលើចាស មានការប្រើជារំពាត់ខ្សែតីអី ឬក៏ជាការសម្លុតគំរាម តែបើថាឲ្យឃើញតែវ៉ៃអ៊ីចឹងទៅមុខទៀត ឃើញវ៉ៃនឹងស្នាយកាំភ្លើងអ៊ីចឹងទៀត អត់ឃើញទេចាស។

[១៣:៤៥:១៣]

**ស៖** អរគុណ។ នៅក្នុងឯកសារសួរចម្លើយដដែល នៅក្នុងសំណួរលេខ២២ សំណួរចម្លើយលេខ២២។ នៅឃ្លាចុងក្រោយបានសរសេរថា "នៅមានរឿងមួយ ដែលខ្ញុំដឹងពីបងស្រីរបស់ខ្ញុំ ឈ្មោះពេជ ផាន ដែលរស់នៅទីនោះដែរ បានប្រាប់ខ្ញុំថា រាល់យប់ គេបានយករទេះគោទៅដឹកមនុស្សចេញពីភូមិយកទៅសម្លាប់ និងបានឃើញកន្លែងគេសម្លាប់ទៀតផង"។ នេះជាសម្ដីលោកស្រីជម្រាបទៅចៅក្រម គឺបងស្រីអ្នកស្រីឃើញ ឬក៏អ្នកស្រីអ្នកឃើញ?

**ឆ៖** ចាស អរគុណ។ អម្បាញ់មិញនេះ គឺបងស្រីនាងខ្ញុំជាអ្នកឃើញ ចំណែកនាងខ្ញុំ បានឮគាត់ប្រាប់។

**ស៖** អរគុណណាស់។ សំណួរមួយទៀត ត្រង់ឯកសារដដែល សួរនិងឆ្លើយលេខ២៣ ត្រង់ឃ្លាមួយបាននិយាយថា "នៅឆ្នាំ១៩៧៨ ឬយ៉ាងណានោះទេ (សូមទោស មើលរំលង) នៅឆ្នាំ១៩៧៨ មានមិត្តនារីម្នាក់ឈ្មោះ នី ជាអ្នក១៧ មេសា និង សំ បានខុសសីលធម៌នឹងគ្នា។ ខ្ញុំមិនដឹងថា គេខុសសីលធម៌ឬយ៉ាងណានោះទេ ប៉ុន្តែនៅថ្ងៃមួយ ខ្ញុំត្រូវបាន បងឈិន ឲ្យទៅបេះស្លឹកថ្នឹងខាងក្រោយមន្ទីរពេទ្យទួលថ្មី ហើយខ្ញុំបានឃើញ មិត្តសំគេចងស្លាបសេកទៅខាងក្រោយ ហើយគេថា អ្នកឯងខុសសីលធម៌នឹងគ្នា។ គេក៏រះពោះយកប្រមាត់ទាំងរស់ ដោយមានចងដៃចងជើងផ្ដោបនឹងសសរព័ទ្ធទៅខាងក្រោយ។ ចំណែកមិត្តនារី នី គេឲ្យដោះខោអាវចេញ ហើយចង បន្ទាប់ឈ្លបបានកាំបិតហាន់ថ្នាំជក់យកៗ យកទៅសង្កត់កនារីនោះ ដោយសង្កត់ម្ដងបន្តិចៗ នារីនេះ -- នារីនោះ ក៏ស្រែកថា អូយ! ហើយឈ្លបបានសួរថា តើស្រួលដែរទេ? ឈ្លបបានធ្វើដូច្នេះរហូតដល់នារីនោះស្លាប់។ ខ្ញុំមិនដឹងថា ឈ្លបបានរំលោភនារីនោះ ឬក៏

អត់នោះទេ"។ ឃ្លាទាំងនេះ ខ្ញុំសូមសួរអ្នកស្រីបានឃើញនឹងភ្នែកនូវព្រឹត្តិការណ៍ទាំងនេះទេ ឬក៏អ្នកស្រីបានឮគេនិយាយប្រាប់ដែរ?

[១៣:៤៩:១៦]

**ឆ៖** ចាស អរគុណ។ ចំណុចត្រង់កន្លែងនេះ គឺនាងខ្ញុំបានឃើញផ្ទាល់នឹងភ្នែក ក៏ប៉ុន្តែដូចខ្ញុំបានជម្រាបនៅក្នុងឯកសារហ្នឹងអ៊ីចឹង ខ្ញុំមិនដឹងថា ឈ្លបនោះរំលោភនារីនោះហើយ ទើបយកទៅចងសម្លាប់ ឬក៏មិនរំលោភ ខ្ញុំអត់ដឹងទេ។ សាច់រឿងដែលខ្ញុំដឹង គឺខ្ញុំឃើញពេលដែលសកម្មភាព គេវះពោះ មិត្តសំហ្នឹង ហើយនិងគេជាន់កាំបិតហាន់ថ្នាំហ្នឹង ជាន់ទៅលើ-កនាងនីហ្នឹងចាស។ សាច់រឿងនេះ សកម្មភាពនេះ គឺខ្ញុំឃើញដោយផ្ទាល់ភ្នែក អត់មានអ្នកណាប្រាប់ទេចាស។

**ស៖** ពេលនោះ អ្នកស្រីបានឃើញព្រឹត្តិការណ៍នោះ នៅពេលយប់ ឬពេលថ្ងៃ?

[១៣:៥០:០៦]

**ឆ៖** ចាស ព្រឹត្តិការណ៍នោះកើតឡើងនៅពេលរសៀលមិនមែនយប់ ហើយក៏មិនមែនថ្ងៃដែរ។ ចន្លោះពេលដែលយើងហូបបាយរួមគ្នាព្រឹកហើយ បងឈិន ហ្នឹងគាត់ត្រូវស្លម្ហូរទៀត។ គាត់ប្រើខ្ញុំថា "អូនឯងទៅបេះស្លឹកថ្នឹងមកនៅមួយជួរចុងក្រោយនោះ ជិតពេទ្យទួលថ្មហ្នឹង"។ ហើយពេលនុ៎ង ខ្ញុំក៏កន្ត្រៀតកញ្ជ្រែងហ្នឹងដើរទៅបេះស្លឹកថ្នឹង។ ប៉ុន្តែនៅពេលដែលខ្ញុំដើរហ្នឹង ខ្ញុំអត់ចាប់អារម្មណ៍ថា មានឃើញសកម្មភាពអីទេ។ នៅពេលដែលខ្ញុំបួតហ្នឹងខ្ញុំឮសូរស្រែក អ៊ីចឹងខ្ញុំក៏ឈប់បួតហើយ ខ្ញុំលបៗមក ខ្ញុំវែកស្លឹកថ្នឹងលួចមើល។ នៅពេលដែលឃើញនោះ ខ្ញុំចង់ឈានជើងចេញទៅវិញដែរ ដោយខ្លាចស្លាប់ដល់ខ្លួនឯងទៀត ប៉ុន្តែជើងខ្ញុំហ្នឹងហាក់ដូចជាស្ពុត ហាក់ដូចជាមានអីចងជាប់នឹងដីហ្នឹង ខ្ញុំទៅអត់រួចទេ។ អ៊ីចឹងសកម្មភាពខ្ញុំនៅពេលនោះគឺគាំងៗនៅហ្នឹង។ ដូចថាយើងស្កុបអ៊ីចឹង អត់ទៅណារួចទេ។ រហូតដល់តែនារីនោះស្លាប់ ហើយដល់ឮៗគេនាំគ្នាសើច គេសើចនឹងគេបានធ្វើសកម្មភាពហ្នឹងហើយបានខ្ញុំភ្ញាក់អារម្មណ៍វិញ។ ពេលដែលភ្ញាក់ហើយក៏ខ្ញុំអត់ហ៊ានចេញទៅដែរ ខ្ញុំសំងំរហូតដល់តែឈ្លបហ្នឹងគេចេញទៅអស់ បានខ្ញុំលបចេញទៅការដ្ឋានវិញដោយអត់មានបានស្លឹកថ្នឹងអីមួយបន្តិចទេ ទៅដល់វិញចុងភៅហ្នឹងគាត់សួរ និយាយអីៗក៏អត់ចេញដែរចាស។

[១៣:៥០:៤៨]

**ស៖** កាលដែលអ្នកស្រីបានឃើញការរំលោភ ការសម្លាប់ ហ្នឹងផ្ទាល់ភ្នែក ពេលហ្នឹងអ្នកស្រីភ័យទេ? ខ្លាចទេ? ហើយអ្នក -- បើសិនជា អ៎ ខ្ញុំសួរប៉ុណ្ណឹងសិន។

**ផ៖** ចាស នាងខ្ញុំមានការភ័យខ្លាចយ៉ាងខ្លាំង។

**លោក សុន អរុណ៖**

ខ្ញុំសូមអរគុណ។ ខ្ញុំមានសំណួរតែប៉ុណ្ណោះ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសក្នុងការសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន ហើយសូមអរគុណ។ សូមគោរពតុលាការជាថ្មី សូមគោរពអង្គសវនាការ។

[១៣:៥២:៣៣]

**សួរដោយលោក អាង ឧត្តម៖**

**ស៖** សួស្តីលោកស្រី ពេជ ស្រីផល។ ខ្ញុំអាង ឧត្តម ហើយខាងស្តាំដៃខ្ញុំនេះគឺលោក ម៉ៃខល កាណាវាស។ យើងខ្ញុំជាសហមេធាវីការពារក្តីលោក អៀង សារី។ នៅពេលនេះខ្ញុំមានសំណួរតែមួយទេនឹងសួរលោកស្រី។ ឆ្លើយតបទៅនឹងសំណួរទៅនឹងសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីព្រឹកមិញ លោកស្រីឆ្លើយថា "អ្នកភៀសខ្លួននៅលើរទេះភ្លើង ដែលក្នុងទូរទេះភ្លើងណាដែលបន្ទោបង់គ្មានការអនុញ្ញាតត្រូវបានសម្លាប់ភ្លាម"។ លោកស្រីមានប្រសាសន៍ថា "ប្រសិនបើអ្នកណាបន្ទោបង់នៅលើទូរទេះភ្លើងដោយគ្មានការអនុញ្ញាតពីកង -- ពីឈ្លប ឬទាហានខ្មែរក្រហមយាមកាមនៅលើទូរទេះភ្លើងនោះទេនឹងត្រូវសម្លាប់ភ្លាម"។ ក្នុងករណីដែលលោកស្រីប្រើពាក្យថា "បើសិនបើមានរឿងហ្នឹងកើតឡើងអ៊ីចឹងមានគេបន្ទោបង់អត់មានការអនុញ្ញាតអ៊ីចឹងត្រូវបានគេសម្លាប់ភ្លាម។ តើនេះជាការស្មាន ឬការសន្និដ្ឋានរបស់លោកស្រីទេ ក្នុងការប្រើពាក្យ "ប្រសិនបើ" បែបនេះ?

**លោកស្រី ពេជ ស្រីផល៖**

**ផ៖** ចាស អរគុណ។ ក្នុងលក្ខណៈដែលនាងខ្ញុំបានបកស្រាយជូនទៅលោកស្រីមេធាវីដើមបណ្តឹងរដ្ឋប្បវេណីព្រឹកមិញនេះ ខ្ញុំបាននិយាយថា "បើមាននរណាម្នាក់បន្ទោបង់នៅក្នុងរថភ្លើងនឹងត្រូវទាហានខ្មែរក្រហមបាញ់សម្លាប់នៅទីនោះ"។ ក្នុងការដែលនាងខ្ញុំប្រើពាក្យថា "បើសិនបើ" នេះគឺក្នុងនោះគឺមានបន្ទោបង់ទៅហើយ ប៉ុន្តែដែលខ្ញុំនិយាយ ខ្ញុំបាននិយាយអ៊ីចឹង ខ្ញុំដឹងថាជាចំណុចមួយដែលខ្ញុំ

និយាយទៅវាមានអត់ ឬក៏មាន។ ប៉ុន្តែខ្ញុំសូមជម្រាបថា គឺមានបន្ទោបង់ក្នុងរថភ្លើងហ្នឹងហើយ ហើយទាហាននោះក៏បាញ់សម្លាប់ ដូច្នេះបើសិនជាក្រោយពីករណីសម្លាប់ហ្នឹងហើយ មានអ្នកណាទៀតឃើ ហើយមិនសុំច្បាប់គេបន្ទោបង់ទៀតនឹងមានសម្លាប់តទៅទៀតចាស។

[១៣:៥៥:០២]

**ស៖** អរគុណ។ បាទ អ៊ីចឹង ខ្ញុំសូមសួរបន្តមួយសំណួរទៀត។ ប្រតិកម្មបែបនេះ តើអ្នកស្រីបានឃើញផ្ទាល់នឹងភ្នែក ឬមួយយ៉ាងម៉េច?

**ឆ៖** ចាស អរគុណ។ ឧក្រិដ្ឋកម្មនេះ គឺកើតនៅក្នុងទូរថភ្លើងដែលនាងខ្ញុំជិះ ចំណែកទូរថភ្លើងដទៃទៀត នាងខ្ញុំអត់ដឹងទេចាស។

**ស៖** ការបាញ់សម្លាប់នោះមានប៉ុន្មាននាក់ដែរ ដែលអ្នកស្រីឃើញនៅក្នុងទូហ្នឹង?

**ឆ៖** ចាស នៅក្នុងទូនោះមានតែម្នាក់ទេ បន្ទាប់ពីហ្នឹងទៅបាក់ស្បាតហើយ អត់មានអ្នកណាហ៊ានលេចទៀតទេចាស។

[១៣:៥៥:៥៥]

**លោក អាង ឧត្តម៖**

សូមអរគុណអ្នកស្រី ពេជ ស្រីផល ខ្ញុំអស់សំណួរហើយ។ តាងនាមលោក អៀង សារី យើងខ្ញុំទាំងពីរនាក់សូមអរគុណថ្លែងអំណរគុណលោកស្រី ដែលឡើងមកផ្តល់សក្ខីកម្មជួយតុលាការ ដើម្បីស្វែងរកការពិត។ សូមអ្នកស្រីបានជោគជ័យ សិរីសួស្តីពេលត្រឡប់ទៅវិញ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកា ជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការសួរដេញដោល ចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការ! សូមជម្រាបសួរលោកស្រី ពេជ ស្រីផល ផង។ ក្នុងនាមមេធាវីរបស់លោក ខៀវ សំផន យើងខ្ញុំអត់មានសំណួរអ្វីសម្រាប់អ្នកស្រីទេ។ សូមថ្លែងអំណរគុណ។ សូមអរគុណលោកប្រធាន។

[១៣:៥៦:៥០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

បាទ អរគុណលោកស្រី ពេជ ស្រីផល។ ដូចបាន អង្គជំនុំជម្រះបានជម្រាបជូនលោកស្រីរួចហើយថា ក្នុងនាទីចុងក្រោយនៃការផ្តល់សក្ខីកម្មរបស់លោកស្រីចំពោះមុខអង្គជំនុំជម្រះ អង្គជំនុំជម្រះផ្តល់ឱកាសឲ្យលោកស្រីធ្វើសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងព្យសនកម្ម ដែលលោកស្រីទទួលរងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។

**លោកស្រី ពេជ ស្រីផល៖**

ចាស នាងខ្ញុំសូមគោរពលោកប្រធានតុលាការជាទីគោរព! សូមគោរពលោក លោកស្រីចៅក្រមនៃអង្គជំនុំជម្រះជាទីគោរព! សូមគោរពអង្គសវនាការទាំងមូលជាទីគោរពចាស! នាងខ្ញុំសូមអនុញ្ញាតបង្ហាញអំពីការឈឺចាប់ ព្យសនកម្ម ដែលនាងខ្ញុំបានទទួលក្នុងរបប៣ឆ្នាំ៨ខែ ២០ថ្ងៃ កន្លងមកនេះចាស។ ហើយនាងខ្ញុំថ្ងៃនេះ ក៏មានសំណាងដែរ ដែលបានយកទុក្ខសោកទាំងអស់នោះ យកមកបង្ហាញនៅមុខ អ.វ.ត.ក ចាស។ នាងខ្ញុំសូមជម្រាបអស់លោក លោកស្រីឲ្យបានជ្រាបថា ក្នុងរបប៣ឆ្នាំ ៨ខែនេះ នៅពេលដែលនាងខ្ញុំត្រឡប់មកវិញ គឺគ្មានសេសសល់អ្វីទេ ក្រៅពីការឈឺចាប់ ចាស ភាពភ័យខ្លាច ភាពបាក់ស្បាត ការបាត់បង់នូវស្មារតីសតិបញ្ញា ដែលជះឥទ្ធិពលមកលើនាងខ្ញុំរហូតមកដល់ឥឡូវនេះ នៅតែចងចាំមិនភ្លេចទេ នូវឧក្រិដ្ឋកម្មនានា ដែលបានបង្កវិនាសកម្ម ដល់គ្រួសារនាងខ្ញុំ ដល់រូបនាងខ្ញុំ ដល់បងប្អូនរួមជាតិខ្មែរទាំងអស់ដែលជាជនរងគ្រោះចាស។

[១៣:៥៨:២៩]

នាងខ្ញុំសូមជម្រាបថា នៅក្នុងសម័យនោះប្អូនប្រុសរបស់នាងខ្ញុំ ដែលទើបតែអាយុ១៤ឆ្នាំ ដោយសារភាពអត់ឃ្លានពេក បានទៅលួចល្ពៅគេហូបមួយ ត្រូវបានទិសគេដាក់មកថា កម្ទេចគឺយកទៅសម្លាប់ចោលតែម្តងចាស។ តើឈឺចាប់កម្រិតណា? ចំណុចមួយទៀត ឪពុក ប្អូនស្រី ប្អូនប្រុស មិនបានសម្លាប់មែន ក៏ប៉ុន្តែស្លាប់ដោយសារធ្វើការងារធ្ងន់ អត់ចំណីអាហារ អត់ថ្នាំចាស។ ហើយចំណុចដែលគួរឲ្យនាងខ្ញុំចងចាំមិនអាចបំភ្លេចបាននោះ គឺនារី១៩នាក់ ដែលរស់នៅក្នុងសហករណ៍ព្រហស្បតិ៍ក្បាលត្រូវបានមេគណៈតំបន់ឈ្មោះ ភួន គាត់រំលោភមួយយប់មួយៗ ដាក់វេនគ្នា ព្រោះនារីទាំងអស់នោះជាកងពិសេស ហើយរំលោភគ្រប់១៩ ដល់ចូលវេននារីទី២០ ជាមិត្តសម្លាញ់របស់ខ្ញុំ អត់ធ្វើអីនាងកើតចាស ម៉ោង១២យប់នាងត្រឡប់មកវិញ នាងរ៉ាយរ៉ាប់សាច់រឿងទាំងអស់នោះប្រាប់ខ្ញុំ។ តើក្នុងនាមជាស្ត្រីជា

ជនរងគ្រោះដែលត្រូវគណៈសហករណ៍ គណៈតំបន់រំលោភ តើឈឺចាប់ប៉ុនណា? បើគិតមកដល់ឥឡូវនេះ បើគិតមកច្បាប់យើងឥឡូវនេះវិញ តើគេកាត់ទោសយ៉ាងម៉េច? រំលោភតែមួយក៏គ្រប់ដែរ មិនបាច់ដល់២០ទេចាស។ អាហ្នឹងគឺជាការឈឺចាប់ គឺជាផ្ទុះបញ្ចាំងឲ្យខ្ញុំឃើញឥទ្ធិពលទាំងអស់នោះ ដែលធ្វើឲ្យខ្ញុំឈឺចាប់មិនអាចបំភ្លេចបាន។

[១៤:០០:០៣]

ហើយក្នុងនេះដែរ ក៏នាងខ្ញុំសូមជម្រាបអស់លោក លោកស្រីថា ការឈឺទាំងអស់នោះ វាមិនអាចសុខទៅបាន ធ្វើយ៉ាងម៉េចក៏មិនភ្លេចដែរ ក៏ប៉ុន្តែមានសំណូមពរ ចាស មានសំណូពរថាសុំឲ្យ អ.វ.ត.ក ហ្នឹង មេត្តា ផ្តល់ជាសំណង។ សំណងសមូហភាពខាងខ្ញុំទទួលហើយ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី តែសូមឲ្យមានចេញជារូបរាង តើជាស្តូប ឬក៏ជាមន្ទីរសុខភាពផ្លូវចិត្ត មន្ទីរពេទ្យសុខភាពផ្លូវចិត្ត ដើម្បីឲ្យពួកយើងខ្ញុំទាំងអស់គ្នា ដែលជាជនរងគ្រោះ ទាំងប្រជាជនខ្មែរ ទាំងដើមបណ្តឹងរដ្ឋប្បវេណីហ្នឹង បានទៅធ្វើពិធីគោរពបូជា ទៅតាមបុណ្យប្រពៃណីជាតិដូចជា ភ្ជុំបិណ្ឌ ឬក៏ចូលឆ្នាំ ចាស ហើយដើម្បីឲ្យយើងទាំងអស់គ្នានេះ បានស្ងប់អារម្មណ៍ធូរស្រាលនៅក្នុងចិត្ត។

[១៤:០១:០៥]

ហើយចំណុចសំខាន់មួយទៀតនោះ នាងខ្ញុំដឹងថា អ្នកណាដែលប្រព្រឹត្តត្រូវតែទទួលទោស។ ដូច្នេះសូមឲ្យលោកប្រធាន លោកជួយរកយុត្តិធម៌ឲ្យជនរងគ្រោះទាំងអស់ មិនចាំបាច់នាងខ្ញុំទេ បើរកឲ្យជនរងគ្រោះទាំងអស់ នាងខ្ញុំក៏ស្ថិតនៅក្នុងចំណោម នៃជនរងគ្រោះទាំងអស់នោះដែរ។ សូមឲ្យលោកប្រធានធ្វើយ៉ាងម៉េចឲ្យអ្នកទទួលខុសត្រូវខ្ពស់ និងអ្នកដឹកនាំខ្ពស់ទទួលស្គាល់នូវទង្វើ ដែលអស់លោកទាំងបានប្រព្រឹត្តនៅក្នុងរបបគេហៅថា របបមនុស្សឃាតនោះ, របប៣ឆ្នាំ៨ខែ, របបកម្ពុជាប្រជាធិបតេយ្យនោះចាស ដែលពួកគាត់មានផែនការចាស មានផែនការបង្កវិនាសកម្មឲ្យប្រជាពលរដ្ឋស្លាប់យ៉ាងរង្គាល ហើយក៏សូមឲ្យលោកប្រធានតុលាការ លោកផ្តន្ទាទោសឲ្យបានតឹងរ៉ឹងជាទីបំផុត ដើម្បីជាគំរូទៅដល់បងប្អូនជាន់ក្រោយ និងដើម្បីឲ្យប្រជាជនខ្មែរទាំងអស់ស្ងប់អារម្មណ៍ ហើយដឹងថាអ្នកធ្វើខុសគឺត្រូវតែមានទោស។ ចាស នាងខ្ញុំសូមអរគុណ។

[១៤:០២:១៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី ពេជ ស្រីផល។ ឥឡូវនេះការស្ដាប់សក្ខីកម្មរបស់លោកស្រីរហូតដល់ពេលនេះបានចប់ហើយ វត្តមានរបស់លោកស្រីនៅ អ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ សក្ខីកម្មរបស់លោកស្រីនឹងអាចរួមចំណែក រួមវិភាគទានក្នុងការស្វែងរកការពិតនៃរឿងក្ដីនេះ។ លោកស្រី ពេជ សុផល -- អ៎! ពេជ ស្រីផល អាចវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោកស្រី ឬក៏គោលដៅណា ដែលលោកស្រីមានបំណងចង់ទៅបានហើយ។ សូមលោកស្រីជួបតែសំណាងល្អ បានសេចក្ដីសុខសេចក្ដីចម្រើន និងធ្វើដំណើរវិលទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ វិលទៅកាន់លំនៅដ្ឋានរបស់គាត់វិញចុះ!

លោកស្រី ពេជ ស្រីផល អាចចាកចេញពីបន្ទប់សវនាការ វិលត្រឡប់ទៅវិញបានហើយ!

*(ដើមបណ្ដឹងរដ្ឋប្បវេណីចាកចេញពីបន្ទប់សវនាការ)*

[១៤:០៣:២៧]

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅភាគីពាក់ព័ន្ធនៃរឿងក្ដី ដើម្បីមានលទ្ធភាពក្នុងការធ្វើការកត់សម្គាល់ទៅលើសក្ខីកម្មនានា ដែលលោកស្រី ពេជ ស្រីផល បានផ្ដល់សក្ខីកម្មក្នុងថ្ងៃនេះ តាំងពីព្រឹករហូតមកនេះ ប្រសិនបើមានបំណងធ្វើដូច្នេះ។

បាទ ទំនងជាមិនមានទេ អង្គជំនុំជម្រះសូមជម្រាបភាគីនៃរឿងក្ដីថា អង្គជំនុំជម្រះសាលាដំបូងបានទទួលនូវសេចក្ដីតប របស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះអង្គជំនុំជម្រះថា ខ្លួនសុំអង្គជំនុំជម្រះមិនចាំបាច់ស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCW-213 នោះឡើយ។ ហើយបញ្ហានេះអង្គជំនុំជម្រះបានដាក់ លើកសំណួរពាក់ព័ន្ធដោយលោកចៅក្រម ហ្សង់ម៉ាក ចំពោះដើមបណ្ដឹងរដ្ឋប្បវេណីកាលពីម្សិលមិញ។ ហើយម្យ៉ាងទៀតគឺ អង្គជំនុំជម្រះកត់សម្គាល់ឃើញសក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-213 មិនមានភាពពាក់ព័ន្ធទៅនឹងអង្គហេតុទាំងឡាយ ដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការនៅក្នុងសំណុំរឿង០០២/០១ ទេ។ ដូច្នេះអង្គជំនុំជម្រះសម្រេចមិនស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងកិច្ចដំណើរការសវនាការសំណុំរឿង០០២/០១ នេះទេ។

ហើយជាបន្តអង្គជំនុំជម្រះបន្តស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-59។

មន្ត្រីរដ្ឋបាលតុលាការកោះ អញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណី TCCP-59 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលបន្ទប់សវនាការ)*

[១៤:០៦:៣៥]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកដើមបណ្ដឹងរដ្ឋប្បវេណី។ តើលោកឈ្មោះអី?

**លោក គឹម វ៉ាន់ឌី៖**

**ឆ៖** បាទ ខ្ញុំឈ្មោះ គឹម វ៉ាន់ឌី។

**ស៖** អរគុណលោក គឹម វ៉ាន់ឌី តើលោកមានថ្ងៃខែឆ្នាំកំណើត កើតថ្ងៃខែឆ្នាំណាដែរ?

**ឆ៖** បាទ ខ្ញុំកើតថ្ងៃទី៦ ខែ៦ ឆ្នាំ១៩៦២។

**ស៖** តើលោកមានទីកន្លែងកំណើតនៅទីកន្លែងណា?

**ឆ៖** ខ្ញុំមានទីកន្លែងកំណើតនៅភូមិអង្គរជ័យ ឃុំអង្គរជ័យ ស្រុកអង្គរជ័យ ខេត្តកំពត។

**ស៖** បាទ អរគុណ។ ចុះទីលំនៅដ្ឋានរបស់លោកបច្ចុប្បន្ន តើលោករស់នៅទីកន្លែងណា?

**ឆ៖** នៅភូមិទី៤ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

[១៤:០៧:៤៥]

**ស៖** តើលោកប្រកបមុខរបររកស៊ីធ្វើអ្វីសព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំប្រកបមុខរបររកស៊ីលក់កម្លាំងពលកម្មឲ្យក្រុមហ៊ុន។

**ស៖** ចុះឪពុកបង្កើតរបស់លោកគាត់ឈ្មោះអី?

**ឆ៖** ឪពុកបង្កើតរបស់ខ្ញុំ ឈ្មោះ កែម អ៊ែល។

**ស៖** ចុះម្ដាយបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** បង្កើត -- អ៎! ម្ដាយបង្កើតរបស់ខ្ញុំឈ្មោះ អ៊ុំ យឿន។

**ស៖** លោកមានបងប្អូនប៉ុន្មាននាក់ បងប្អូនបង្កើតប៉ុន្មាននាក់?

**ឆ៖** ខ្ញុំមានបងប្អូនបង្កើតប្រាំនាក់។

**ស៖** លោកមានប្រពន្ធទេ? ហើយប្រពន្ធរបស់លោកឈ្មោះអី?

**ឆ៖** ខ្ញុំមានប្រពន្ធ។ ប្រពន្ធខ្ញុំឈ្មោះ ឈួន ស្រីម៉ុម។

[១៤:០៩:០៧]

**ស៖** លោកមានកូនប៉ុន្មាននាក់?

**ឆ៖** ខ្ញុំមានកូនប្រាំមួយនាក់។

**ប្រធានអង្គជំនុំ៖**

លោក គឹម វ៉ាន់ឌី ក្នុងនាមលោកជាដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងដំណើរការនៃរឿងក្ដីនេះ លោកអាចមានសិទ្ធិថ្លែងរៀបរាប់ប្រាប់ជូនអង្គសវនាការអំពីស្ថានភាពទុក្ខវេទនានិងស្ថានភាពព្យសនកម្ម គឺមហន្តរាយដែលកើតមានឡើងចំពោះលោក ដែលមានជាអាទិ៍ ការខូចខាតខាងផ្លូវចិត្ត ផ្លូវកាយ ឬសម្ភារៈ។ ហើយព្យសនកម្មផ្ទាល់ខ្លួនដែលជាបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋដែលកើតមានពិតប្រាកដរហូតមកដល់ពេលបច្ចុប្បន្ន ដែលនាំឲ្យលោកប្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទ ដែលបានប៉ះពាល់ចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

នេះយើងជម្រាបអំពីសិទ្ធិនេះ ដោយអង្គជំនុំជម្រះនឹងទុកឱកាសជូនលោកសម្រាប់ធ្វើសេចក្ដីថ្លែងរៀបរាប់បញ្ហានេះនាទីចុងក្រោយនៃការផ្ដល់សក្ខីកម្មរបស់លោក បន្ទាប់ពីមុននឹងបញ្ចប់អង្គជំនុំជម្រះនឹងផ្ដល់វេទិកាជូនទៅលោក ដើម្បីធ្វើការថ្លែងរៀបរាប់អំពីស្ថានភាពព្យសនកម្ម គឺអន្តរាយហើយនិងស្ថាន-ភាពទុក្ខសោកវេទនាដែលលោកជួបប្រទះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

[១៤:១០:៤១]

អង្គជំនុំជម្រះសូមជម្រាបតំណាងសហព្រះរាជអាជ្ញា -- តំណាងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីថា អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ អង្គជំនុំជម្រះសាលាដំបូងផ្ដល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះមុនភាគីដទៃទៀត។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ លោកស្រីមេធាវី ទី ស្រ៊ីនណា គឺជាមេធាវីដែលនឹងលើកសំណួរសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីនេះ សូមលោកប្រធានអនុញ្ញាត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! សូមអញ្ជើញ!

**លោកស្រី ទី ស្រ៊ីនណា៖**

ជាដំបូងនាងខ្ញុំសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** ជម្រាបសួរលោក គឹម វ៉ាន់ឌី។ ដំបូង នាងខ្ញុំមានសំណួរពាក់ព័ន្ធជាមួយនឹងលំនៅដ្ឋានរបស់លោកនៅក្នុងសម័យលន់ នល់។ អ៊ីចឹងខ្ញុំចង់សួរថា តើលោក និងក្រុមគ្រួសាររបស់លោករស់នៅឯណាដែរកាលពីសម័យ លន់ នល់?

[១៤:១២:១០]

**លោក គឹម វ៉ាន់ឌី៖**

**ឆ៖** បាទ កាលពីសម័យ លន់ នល់ ខ្ញុំមានទីលំនៅនៅភូមិជ្រោយចង្វា ក៏ប៉ុន្តែមិនស្គាល់ថាឃុំចាំអីទេ ក៏ប៉ុន្តែដឹងថានៅជ្រោយចង្វា ដូចជាស្រុកមុខកំពូល ខេត្តកណ្ដាល រាជធានីភ្នំពេញ។

**ស៖** សូមអរគុណ។ តើពេលនោះសមាជិកក្នុងក្រុមគ្រួសាររបស់លោកមានចំនួនប៉ុន្មាននាក់ដែរ?

**ឆ៖** ដូចជាមានប្រាំ -- អាហ្នឹងដូចខ្ញុំ អាហ្នឹងខ្ញុំដូចចាំអត់ច្បាស់ ព្រោះខ្ញុំបានបែកបងខ្ញុំពីរនាក់ទៅ ពោធិ៍សាត់។ ខ្ញុំចាំនៅតែក្នុងហ្នឹងមាន ឪពុកម្ដាយខ្ញុំ ពីរនាក់, រូបខ្ញុំម្នាក់, បងជីដូនមួយខ្ញុំម្នាក់ ហើយនិងប្អូនស្រីខ្ញុំម្នាក់ទៀត។ ហើយប្អូនស្រីខ្ញុំពីរនាក់ ស្រីដន មួយ, ហើយនិងស្រីសុគន្ធា ហ្នឹងមួយ។ ចាំបានតែប៉ុណ្ណឹង។

**ស៖** ចុះកាលពីសម័យ លន់ នល់ហ្នឹង តើឪពុកម្ដាយរបស់លោកហ្នឹងប្រកបមុខរបរអ្វីដែរ?

**ឆ៖** កាលពីសម័យ លន់ នល់ ហ្នឹងម្ដាយខ្ញុំមេផ្ទះ ឪពុកខ្ញុំហ្នឹងធ្វើជាទាហានជើងទឹក។

[១៤:១៣:៥៧]

**ស៖** ចុះរូបលោកវិញ លោកធ្វើអ្វីដែរនាពេលនោះ?

**ឆ៖** ពេលហ្នឹងខ្ញុំនៅរៀន។

**ស៖** តើលោកអាចចាំបានឬទេ មុនថ្ងៃដែលកងទ័ពខ្មែរក្រហមវាយរំដោះយកទីក្រុងភ្នំពេញហ្នឹង នៅម្តុំផ្ទះរបស់លោកហ្នឹងមានហេតុការណ៍អ្វីកើតឡើងដែរឬទេ កាលពេលនុ៎ង?

**ឆ៖** ពេលហ្នឹង ខ្ញុំចាំមិនសូវបានច្បាស់។ ពេលហ្នឹងឃើញកងទ័ពរបស់ លន់ នល់ ហ្នឹងប្រយុទ្ធគ្នាជាមួយកងទ័ពខ្មែរក្រហម។ ពេលហ្នឹងមានគឺមានឧទ្ធម្ភាគចក្រហ្នឹងឈរបាញ់ជួយទៀត។ ឧទ្ធម្ភាគចក្ររបស់ខាង លន់ នល់ ហ្នឹងជួយ -- បាញ់ជួយទៀត។ បាទ ខ្ញុំឃើញពេលហ្នឹងប្រយុទ្ធគ្នាណាស់។ ប្រយុទ្ធគ្នាដូចទាំងយប់ ទាំងថ្ងៃ បាទ ទាំងយប់ ទាំងថ្ងៃហ្នឹងនៅតាមមាត់ទន្លេហ្នឹង ត្រើយខាងវិហារសួគ៌ហ្នឹង គឺទ័ពខ្មែរក្រហម គេឈរ គេដាក់ទីតាំង។ តែទ័ពនៅត្រើយម្ខាងទន្លេជាប់ដីផ្ទះខ្ញុំនេះ គឺទាហាន លន់ នល់។ ខ្ញុំចាំបានប៉ុណ្ណឹង។

**ស៖** ចុះនៅពេលដែលមានការប្រយុទ្ធគ្នារវាងទាហាន លន់ នល់ និងខាងកងទ័ពខ្មែររំដោះហ្នឹង តើពេលនោះមាន -- លោកមានបានកត់សម្គាល់ឬទេ ថាតើមានសមាជិកក្រុមគ្រួសាររបស់លោក ក៏ដូចជាអ្នកនៅតំបន់ដែលរស់នៅតំបន់ -- អ្នកដែលរស់នៅក្នុងតំបន់ ឬក៏ភូមិស្រុកជាមួយលោកហ្នឹង មានត្រូវរបួសដោយសារការប្រយុទ្ធគ្នាហ្នឹងដែរឬទេ?

[១៤:១៦:០១]

**ឆ៖** ពេលហ្នឹងខាងក្រុមគ្រួសាររបស់ខ្ញុំហ្នឹងអត់មានត្រូវរបួសទេ តែខាងគ្រួសារដែលនៅជិតជាប់ម្តុំផ្ទះខ្ញុំហ្នឹងមានត្រូវ។ ក៏ប៉ុន្តែខ្ញុំមិនបានហ៊ានទៅមើលទេ ព្រោះខ្ញុំខ្លាចត្រូវ ក៏ខ្ញុំនៅជ្រកនៅក្នុងគេហៅថា រណ្តៅត្រង់សេនោះ។

**ស៖** តើពេលហ្នឹងតំបន់ដែលលោករស់នៅហ្នឹងមានការកាន់កាប់ដោយពួកខ្មែរក្រហមរំដោះ ឬដោយទាហាន លន់ នល់?

**ឆ៖** ពេល១ហ្នឹងគឺគ្មានទ័ពខ្មែរក្រហមកាន់កាប់ទេ មានតែកងទ័ព លន់ នល់ ទេដែលនៅឈរនៅទីនោះ។

**ស៖** លោកថា លោករស់នៅម្តុំជ្រោយចង្វា អ៊ីចឹងលោកមាន នៅពេលដែលមានហេតុការណ៍ច្បាំងគ្នាអ៊ីចឹង តើលោកមានធ្វើការផ្លាស់ប្តូរទីលំនៅដែរឬទេ នៅពេលនុ៎ង?

**ឆ៖** បាទ មាន១ការផ្លាស់ប្តូរទីលំនៅហ្នឹងដោយសារខ្ញុំមានឪពុកមាមួយ គាត់បានមកនិយាយប្រាប់ម្តាយខ្ញុំថា "ប្អូនឯងនៅហ្នឹងមិនបានទេ ព្រោះគ្រាប់ផ្លោងហ្នឹងធ្លាក់ជិត១ផ្ទះណាស់។ អ៊ីចឹងអូនឯង

ត្រូវភៀសខ្លួនទៅស្នាក់នៅផ្ទះម្ដុំបងទៅ ម្ដុំហ្នឹងដូចឃើញគ្រាប់ផ្លោងវាទៅមិនសូវដែលដល់ដែរ"។ ដល់ពេលហ្នឹង ម្ដាយខ្ញុំហ្នឹងក៏បានគិតគូរគ្នាចប់សព្វគ្រប់ក៏នាំគ្នាទៅនៅផ្ទះឪពុកមារបស់ខ្ញុំហ្នឹងទៅ។

[១៤:១៧:៥៥]

**ស៖** តើផ្ទះឪពុកមារបស់លោកហ្នឹងនៅកន្លែងណាដែរ?

**ឆ៖** បាទ ផ្ទះឪពុកមារបស់ខ្ញុំហ្នឹងនៅ គឺនៅសន្ធរម៉ុក។

**ស៖** តើនៅពេលដែលលោកទៅរស់នៅផ្ទះឪពុកមារបស់លោកបានរយៈពេលប៉ុន្មានដែរ ទើបបានកងទ័ពរំដោះវាយសម្រុកទៅដល់ទីក្រុងភ្នំពេញនោះ? លោកអាចចាំបានឬទេ?

**ឆ៖** ខ្ញុំនៅចាំបានថា ពេលហ្នឹងខ្ញុំទៅរស់នៅផ្ទះឪពុកមារបស់ខ្ញុំហ្នឹងជា ដូចជាពីរលើក បីលើកដែលខ្ញុំបានចាំ។

**ស៖** សូមលោកបញ្ជាក់ឡើងវិញ លោកថាលោកទៅរស់នៅផ្ទះឪពុកមារបស់លោកជាពីរលើក បីលើក។ តើលោកចង់មានន័យយ៉ាងម៉េចដែរ? សូមលោកជួយបញ្ជាក់បន្តិច។

**ឆ៖** លើកទី១ហ្នឹង គេបានបាញ់ដាក់គ្នាអ៊ីចឹងទៅ ធ្វើឲ្យខ្ញុំភិតភ័យ ខ្ញុំក៏បានចាកចេញពីផ្ទះសម្បែងហ្នឹងរត់ទៅនៅផ្ទះឪពុកមារបស់ខ្ញុំ។ ពេលណាស្ងាត់គ្រាប់ផ្លោងទើបខ្ញុំហ្នឹងបានត្រឡប់មកពីផ្ទះឪពុកមាខ្ញុំមកកាន់ផ្ទះលំនៅ -- មក១នៅលំនៅដ្ឋានរបស់ខ្ញុំវិញ។

**ស៖** អ៊ីចឹងខ្ញុំសូមសួរលោកថា លោក លើកចុងក្រោយដែលលោកទៅរស់នៅផ្ទះឪពុកមារបស់លោកហ្នឹង បានរយៈពេលប៉ុន្មានថ្ងៃ ទើបកងទ័ពខ្មែររំដោះហ្នឹងវាយចូលទៅដល់ទីក្រុងភ្នំពេញ?

[១៤:២០:១៣]

**ឆ៖** អាហ្នឹង ខ្ញុំអត់បាននៅចាំពេលវេលាថា ទៅនៅបានប៉ុន្មានថ្ងៃៗទេ ក៏ប៉ុន្តែដឹងថា ខ្ញុំបានដឹងពេលវេលាថា ពេលដែលគេកំពុងប្រយុទ្ធគ្នា ថ្ងៃចុងក្រោយបំផុត១ គឺស្ងាត់គ្រាប់ផ្លោង ប្រហែលជាពាក់កណ្ដាលយប់ គឺខ្ញុំត្រូវធ្វើដំណើរទៅផ្ទះឪពុកមាខ្ញុំ។

**ស៖** ខ្ញុំសូមបញ្ជាក់សំណួរខ្ញុំឡើងវិញ ខ្ញុំចង់សួរលោកថា ពេលដែលលោក -- លោកថា លោកបានទៅ ពេលដែលគ្រាប់ផ្លោងស្ងាត់ពេលយប់ លោកបានធ្វើដំណើរទៅផ្ទះឪពុកមារបស់លោក។ តើពេលដែលលោកទៅដល់ផ្ទះឪពុកមារបស់លោកហ្នឹង លោកចាំបានឬទេ ថាពេលហ្នឹង លោកទៅនៅផ្ទះឪពុកមារបស់លោកបានរយៈពេលប៉ុន្មានថ្ងៃ ទើបបានកងទ័ពខ្មែរក្រហមហ្នឹង ឬក៏កងទ័ពរំដោះហ្នឹងវាយចូលទីក្រុងភ្នំពេញ វាយដណ្ដើមបានទីក្រុងភ្នំពេញ? តើលោកយល់សំណួរខ្ញុំដែរឬទេ?

[១៤:២១:៣០]

**ឆ៖** ពេលនោះ ខ្ញុំស្ងាត់គ្រាប់ផ្លោង ខ្ញុំទៅនៅបានតែ១យប់ទេ។ ក៏ព្រលឹមឡើងប្រហែលជាខ្ទង់ម៉ោងប្រាំមួយ ឬម៉ោងប្រាំពីរទេ តែខ្ញុំវាមិនចាំពេលវេលាច្បាស់ ខ្ញុំឃើញទ័ពខ្មែរក្រហមនោះ ចូលដល់ពេញទីក្រុងភ្នំពេញ។ ពេលនុ៎ង ឃើញឪពុកមារបស់ខ្ញុំហ្នឹង បើកឡានអាហ្ស៊ីបអាដឺ ជាឡានរបស់ទាហានអាមេរិកាំង មកដល់ឈប់មុខផ្ទះនោះ ពេលដែលកងទ័ពខ្មែរក្រហមធ្វើដំណើរជាជួរៗ ខ្លះមានកាន់កាំភ្លើងតូច កាំភ្លើងធំនោះ។ បានស្ទុះមកបាញ់ឪពុកមាខ្ញុំហ្នឹង ដួលនៅមុខផ្ទះ។ ដួលពេលហើយហ្នឹងទាហានខ្មែរក្រហមហ្នឹងក៏ដើរចាកចេញពីកន្លែងហ្នឹង ដើរចូលជួរវិញហើយ ហើយដំណើរទៅបាត់ទៅ។

**ស៖** តើពេលនោះ -- តើឪពុកមារបស់លោកហ្នឹង ពេលនុ៎ងហ្នឹង មានភិនភាគយ៉ាងម៉េចដែរបានជាត្រូវទាហានខ្មែរក្រហមដើរមកបាញ់គាត់ភ្លាមៗ ដូច្នេះ? តើគាត់មានសួររកមូលហេតុ ឬក៏មានការជជែកគ្នារវាងគាត់ ជាមួយនឹងទាហានខ្មែរក្រហមរូបនោះដែរឬទេ បានជាមានការផ្ទុះកាំភ្លើងដល់ថ្នាក់បាញ់គាត់សម្លាប់បែបដូច្នេះ? លោកអាចចាំនូវព្រឹត្តិការណ៍ហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំ អាព្រឹត្តិការណ៍ហ្នឹង ដូចជាខ្ញុំចាំបានខ្លះ ព្រោះខ្ញុំស្ថិតនៅក្នុងផ្ទះបិទទ្វារ។ ពេលហ្នឹង ខ្ញុំឮសំឡេងឡានៗរបស់ឪពុកមារបស់ខ្ញុំបើកមកហ្នឹង ឃើញថា មិនដឹងជា ខ្ញុំអត់មានបានចាប់អារម្មណ៍ថាហ្នឹងបានស្តាប់សំឡេងនិយាយឆ្លើយឆ្លងគ្នាយ៉ាងម៉េចយ៉ាងណាអី ក៏ប៉ុន្តែឮស្នូរកាំភ្លើង១បាទ ស្នូរកាំភ្លើងពេលនោះ បង្ហើបទ្វារមើលឃើញទៅ ឃើញថាឪពុកមាខ្ញុំហ្នឹងដួលបាត់ទៅហើយ។ ដួលស្លាប់នឹងថ្កុកឈាមហ្នឹងបាត់ហើយ តែសម្លៀកបំពាក់គាត់នោះ ស្ថិតនៅជាឯកសណ្ឋានប៉ារ៉ា ហើយមានពាក់ស័ក្តិនៅលើស្មាទៀត។

[១៤:២៣:៥៤]

**ស៖** អ៊ីចឹង អំឡុងពេលហ្នឹង តើឪពុកមារបស់លោកហ្នឹង មានតួនាទីអីដែរ បើគាត់ស្លៀកសម្លៀកបំពាក់ប៉ារ៉ាដូច្នេះ?

**ឆ៖** ខ្ញុំអត់ចាំបានថា គាត់មានតួនាទីអីទេ ក៏ប៉ុន្តែគ្រាន់តែឃើញថា ឪពុករបស់ខ្ញុំបង្ហើតប្រាប់ថា "អាំៗកូនឯងហ្នឹង ទាហានពាក់ស័ក្តិ៥" គ្រាន់តែប្រាប់ខ្ញុំថាប៉ុណ្ណឹងឯង ទេដែលខ្ញុំចាំបានតែប៉ុណ្ណឹង។

**ស៖** តើនៅពេលដែលគាត់ស្លាប់ហ្នឹង លោកជាអ្នកឃើញហេតុការណ៍ហ្នឹងដែរ ឬក៏យ៉ាងណាដែរ?

**ឆ៖** បាទ ពេលដែលគាត់ស្លាប់ហ្នឹង គឺខ្ញុំអត់បានឃើញផ្ទាល់នឹងភ្នែកទេ តែស្នូរគ្រាប់កាំភ្លើងៗបាញ់ហ្នឹង ខ្ញុំបើកទ្វារឃើញមក គាត់ស្លាប់នៅនឹងមុខផ្ទះ អែបនឹងឡានរបស់គាត់ហើយ។

**ស៖** តើលោកដឹងថា នរណាជាអ្នកបាញ់គាត់ដែរឬទេពេលនោះ?

**ឆ៖** ខ្ញុំដឹងថា ជាទាហានខ្មែរក្រហម ក៏ប៉ុន្តែមិនស្គាល់មុខ មិនស្គាល់ឈ្មោះទេ។

[១៤:២៥:១៨]

**ស៖** ហេតុអ្វីបានជាលោកធ្វើការសន្និដ្ឋានថា ជាទាហានខ្មែរក្រហមជាអ្នកបាញ់ឪពុកមារបស់លោក?

**ឆ៖** ព្រោះពេលហ្នឹង ខ្ញុំឃើញទាហានហ្នឹង ម្នាក់ហ្នឹងដើរបែកចេញពីជួរ ហើយកាំភ្លើងមិនទាន់បានលើទៅវិញទេ នៅបំរៀប គេហៅថា ប្រុងលក្ខណៈត្រៀមប្រយុទ្ធណ៎ា ប្រុងលក្ខណៈត្រៀមប្រយុទ្ធ ហើយបាននិយាយថា "ហ្នឹងហើយពួកក្បត់ណ៎ា ពួកកម្ពែលចាស់។ អ៊ីចឹង យើងកុំទុកវា កម្ទេចវាឲ្យអស់"។ បាទ ខ្ញុំចាំបានប៉ុណ្ណឹង។ ពេលហ្នឹង ខ្ញុំចេញមកខាងក្រៅផ្ទះខាងសំយ៉ាបផ្ទះ ដូចជាជញ្ជាំងដែក អ៊ីចឹង មាត់ទ្វារដែកណ៎ា។

**ស៖** អ៊ីចឹងនៅពេលដែលក្រុមគ្រួសាររបស់លោក ចេញមកមើលឪពុកមារបស់លោកស្លាប់ ពេលហ្នឹងប្រពន្ធរបស់គាត់ចេញមកដែរ ឬក៏យ៉ាងណា? ហើយបើសិនជាគាត់ចេញមកដែរ តើពេលដែលគាត់ឃើញស្ថានភាពប្ដីរបស់គាត់ដូច្នោះ តើគាត់មានអារម្មណ៍យ៉ាងម៉េចដែរ? លោកអាចចាំនូវព្រឹត្តិការណ៍នោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានអស់ ក៏ប៉ុន្តែគ្រាន់តែថា អ៎ ខ្ញុំមិនចាំបានអស់ទេ ក៏ប៉ុន្តែវាគ្រាន់តែថា ខ្ញុំចាំបានខ្លះៗ។ ពេលនុ៎ងមុនដំបូងហ្នឹងគឺឮសំឡេងឆោឡោបន្តិចបន្តួច ដល់បន្ទាប់មកបានឃើញថា ក្រុមគ្រួសារខ្ញុំហ្នឹងចេញមកផ្អើលឆោឡោ ឮសំឡេងកូនស្រែកឡូឡាពេញហ្នឹងទៅ ប្រពន្ធរបស់ឪពុកមាខ្ញុំហ្នឹង ក៏ស្រែកយំណ៎ា បោកខ្លួនទ្រោបទ្រាលលើសពនោះៗ។ បាទ ទ្រោបទ្រាលលើសពនោះ ដូចថា សេចក្ដីអស់មិនអស់អាល័យៗ ព្រោះមនុស្សគាត់ហ្នឹងជា គ្មានចរិតកាចឆេវឆាវទេ មនុស្សគាត់នោះស្លូតណាស់។ ខ្ញុំដូចថា ចាំបានតែប៉ុណ្ណឹងឯង។

[១៤:២៧:៣២]

**ស៖** សូមអរគុណ។ ក្រោយពីឪពុកមារបស់លោកត្រូវគេសម្លាប់ តើពេលនុ៎ងលោកមានបានដឹង ឬទេថាតើមានការប្រកាសឲ្យប្រជាជន ចេញពីទីក្រុងភ្នំពេញដែរឬទេនៅពេលនុ៎ង? តើរយៈពេល

ប៉ុន្មានថ្ងៃបន្ទាប់ពីឪពុកមាររបស់លោកស្លាប់ ទើបមានការប្រកាសឲ្យប្រជាជនចេញ ឬក៏ភ្លាមៗនោះត្រូវគេប្រកាសឲ្យប្រជាជនចេញពីទីក្រុងភ្នំពេញ?

**ឆ៖** បាទ ពេលហ្នឹងខ្ញុំអត់ទាន់បានឮស្អូរអីទាំងអស់ គឺគិតតែក្នុងក្រុមគ្រួសារថា នឹងទៅរកនិមន្តលោក និមន្តអីមកដើម្បីប្រោះព្រំព្រលឹងវិញ្ញាណក្ខន្ធគាត់ហ្នឹង ឲ្យគាត់បានស្ងប់សុខស្រួល ក៏ប៉ុន្តែមិនដឹងគិតថា ទៅរកវត្តទៅរកវ៉ាទៅរកលោកឯណាយកមកធ្វើបុណ្យហ្នឹង ក៏សម្រេចចិត្តថា បូជាគាត់ដោយគ្មានព្រះសង្ឃទៅចុះ។ បាទ បូជាគាត់នៅកន្លែងក្រោមដើមក្លោកមុខផ្ទះគាត់ហ្នឹង ហើយប្រហែលជាខ្ទង់ម៉ោងប្រាំបួន បើខ្ញុំអាចប៉ាន់ស្មានមើល ប្រហែលជាខ្ទង់ម៉ោងប្រាំបួន ឮស្អូរមានម៉ូតូម៉ូអីស្រែកអាឡូអាឡាពេញតែផ្លូវ ពេញផ្លូវសន្ធរម៉ុក គេហៅផ្លូវកម្ពុជាក្រោមហ្នឹង ហើយនៅតាមផ្លូវលំហ្នឹងគឺថាបង្ខំឲ្យប្រជាពលរដ្ឋ ប្រជាជនហ្នឹងចាកចេញពីទីក្រុងភ្នំពេញ ព្រោះខ្លាចទាហានអាមេរិកាំងទម្លាក់គ្រាប់បែក ពេលហ្នឹងឮអ៊ីចឹង ខ្ញុំឮតែអ៊ីចឹង។

**ស៖** នៅពេលដែលមានខាង -- ខ្ញុំសូមសួរម្តងទៀត។ នៅពេលនោះ លោកចាំបានឬទេ អ្នកដែលមកប្រកូកប្រកាសថា ឲ្យប្រជាជនចេញហ្នឹង គាត់មានឯកសណ្ឋានយ៉ាងម៉េចដែរ បើតាមការសង្កេតរបស់លោក ឬក៏តាមបទពិសោធន៍របស់លោកនៅពេលនុំង តើលោកមានចាំឬទេថាតើគាត់មានបុគ្គលនោះមានឯកសណ្ឋានយ៉ាងម៉េចដែរ ជាទាហានខាង លន់ នល់ ដដែល ឬក៏ជាទាហានមកពីខាងណាផ្សេង?

[១៤:២៩:៥៨]

**ឆ៖** ពេលនោះ ខ្ញុំឃើញទាហានហ្នឹងមានឯកសណ្ឋានពណ៌ខ្មៅ ពាក់មួកប៉ារ៉េកាតិប បង់-កក្រមា ដាក់កាំភ្លើងឈាងហើយជិះម៉ូតូសេអិលគ្នាពីរនាក់។ ម៉ូតូនុំងម៉ាកសេអិលជិះគ្នាពីរនាក់ ម្នាក់បើកម្នាក់កាន់មីក្រូនិយាយៗ ស្រែករំពងឲ្យប្រជាជនយើងហ្នឹង បានចាកចេញពីទីក្រុងភ្នំពេញឲ្យឆាប់ជាបន្ទាន់ រយៈពេលតែ ៣ថ្ងៃទេឲ្យចេញហ្នឹង ប្រកាសឮអ៊ីចឹង ឮថា ៣ថ្ងៃទេ ដើម្បីកុំឲ្យទាហានអាមេរិកាំងទម្លាក់គ្រាប់បែកណ៎ះ។ ដល់ពេលអ៊ីចឹងហើយ ទាំងគេទាំងឯងឮដូចជាមានព្រឹត្តិការណ៍ឃើញថា បាញ់សម្លាប់ផង អីផងអ៊ីចឹងក៏មើលទៅដូចជាមានចិត្តរន្ធត់ក៏ឆាប់រៀបចំ រៀបចំចាកចេញពីផ្ទះសម្បែងហ្នឹងរយៈពេល ៣ថ្ងៃទេ គេប្រកាសបានច្បាស់អ៊ីចឹងទៀត។

[១៤:៣១:០៩]

**សៈ** តើក្រុមគ្រួសាររបស់លោកហ្នឹងចាកចេញតាមការប្រកាស ឬក៏មានគេបង្ខំឲ្យចេញដែរ? ឬក៏ --?

**ឆៈ** ពេលហ្នឹងខ្ញុំនៅបង្អែបង្អង់មិនទាន់ថាចេញទេ ព្រោះចាំមើលគេមើលឯង។ ដល់ពេលហើយហ្នឹង គឺមានទ័ពមួយខ្សែមកខាងក្រោយទៀតនោះ ប៉ុន្តែខ្ញុំមិនបានចាំចំនួនថាមកប៉ុន្មានៗនាក់ទេ ក៏ស្រែកថា "ចុះចាំអីទៀត នៅយឺតយ៉ាវ នៅរួញរា ត្រេតត្រតអីដល់អង្កាល់ទៀត? នែ៎ បន្តិចទៀតយន្តហោះមកដល់ហើយ ប្រញាប់ស្រូតឡើងណ៎ា ក្រែងលោបាត់បង់អាយុជីវិតកាន់តែច្រើនទៅៗ"។ ពេលហ្នឹង ខ្ញុំក៏ព្យួរបៀបគេឃោសនាអ៊ីចឹងក៏ប្រញាប់ប្រញាល់ណាស់ ឆាប់នាំគ្នាចាកចេញរៀបអីវ៉ាន់បានបន្តិចបន្តួចអីជាប់នឹងខ្លួនហ្នឹងទៅសិនចុះ។ បាទ ខ្ញុំចាំបានប៉ុណ្ណឹង។

[១៤:៣២:១០]

**សៈ** ក្រោយពីការស្រែកគំរាម សួរថាតើមានការប្រើប្រាស់អាវុធ ដើម្បីបង្ខំឲ្យចេញពីផ្ទះដែរឬទេនៅពេលនោះ?

**ឆៈ** ពេលនុ៎ងម្ដុំកន្លែងខ្ញុំហ្នឹងដូចជាមិនឃើញមានគំរាមកំហែងជាកាំភ្លើង តែខ្ញុំចោលភ្នែកមើលទៅប្រហែលជាខ្ទង់បួនដប់ម៉្ភៃម៉ែត្រហ្នឹង ឃើញមានមនុស្ស ឃើញមានប្រជាជនហ្នឹងឈរកកកុំគ្នាជាច្រើនហើយក៏មានស្នូរថាបាញ់ ថាបំបែកជួរគ្នាទៅ ម៉េចក៏ចំ រៀបចំអីវ៉ាន់ អីវ៉ែអីវ៉ាន់ចាកចេញពីផ្ទះនៅឈរកកកុញទៅដល់ណាទៀតណ៎ា។ ខ្ញុំស្ដាប់ឮសំឡេងហ្នឹងល្វើយៗដែរ ប្រហែលជា បែបជា បើតាមខ្ញុំស្មានមើលមិនលើសពីខ្ទង់១០ម៉ែត្រទេ ដែលនិយាយហ្នឹង ហើយមនុស្សឈរពីខាងមុខហ្នឹង។ ខ្ញុំនៅចាំបានប៉ុណ្ណឹង។

[១៤:៣៣:១៧]

**សៈ** តើពេលនុ៎ងក្រុមគ្រួសាររបស់លោកហ្នឹង ធ្វើដំណើរចេញពីទីក្រុងភ្នំពេញភ្លាមៗ ឬក៏យ៉ាងណាដែរ? ហើយពេលធ្វើដំណើរតើក្រុមគ្រួសាររបស់លោកហ្នឹង ធ្វើដំណើរចេញទៅតាមច្រកណាដែរ? លោកចាំបានដែរឬទេ?

**ឆៈ** បាទ ពេលហ្នឹង ខ្ញុំនិងប្រពន្ធឪពុកមាហ្នឹង ខ្ញុំក្រុមគ្រួសារខ្ញុំ ហើយនិងប្រពន្ធរបស់ឪពុកមាខ្ញុំហ្នឹង គឺថាធ្វើដំណើរបែកគ្នាៗ ខ្ញុំហ្នឹងធ្វើដំណើរមកតាមស្ពាន គល់ស្ពានជ្រោយចង្វា ឆ្ពោះទៅផ្លូវជាតិលេខ៦ ៗបាទ។ បាទ ខ្ញុំបានចាំបានប៉ុណ្ណឹង ក៏ប៉ុន្តែវាគ្រាន់តែថាធ្វើដំណើរពីណាទៅណា ពីច្រកណាមក

ច្រកណាខ្ញុំអត់បានចាំទេ ព្រោះភ្នំពេញខ្ញុំមិនអាចស្គាល់ផ្លូវអស់។ បាទ មិនដឹងជាផ្លូវណាហៅផ្លូវកម្ពុជាក្រោម មិនដឹងផ្លូវណាផ្លូវរុស្ស៊ីរុសអី ខ្ញុំអត់បានចាំទេ បាទ។

**ស៖** សូមអរគុណ។ ហើយខ្ញុំសូមបន្តសំណួររបស់ខ្ញុំទៀត លោកថា លោកធ្វើដំណើរទៅតាមផ្លូវជាតិលេខ៦ អ៊ីចឹងខ្ញុំចង់សួរថាពេលដែលលោកធ្វើដំណើរចាកចេញពីផ្ទះឪពុកមា ពីសន្ធរម៉ុកទៅដល់ផ្លូវ ទៅដល់ម្តុំគល់ស្ពានជ្រោយចង្វា តើតាមផ្លូវនៃការធ្វើដំណើររបស់លោកហ្នឹង លោកមានជួបប្រទះនឹងហេតុការណ៍អ្វី ដែលគួរឲ្យកត់សម្គាល់ទេនៅពេលនោះ?

[១៤:៣៥:០១]

**ឆ៖** បាទ ពេលដែលខ្ញុំធ្វើដំណើរទៅតាមផ្លូវជាតិលេខ៦ហ្នឹង ឃើញថាមនុស្សម្នាហ្នឹងច្រើនណាស់ ច្រើនមែនទែន។ ហើយផ្លូវនោះតូច មនុស្សដើរច្រើនហ្នឹងក៏ជាចង្អៀត ហើយការដែលជួបប្រទះហ្នឹងគឺឃើញមានជាមនុស្សត្រូវរបួស ក៏ប៉ុន្តែមិនដឹងជា ជាទាហាន ឬក៏មិនដឹងជាប្រជាពលរដ្ឋទេ ឃើញមានរុំជាបង់ ហើយដៃហ្នឹងដាក់សេរ៉ូម គ្រា ហើយឃើញទិដ្ឋភាពហ្នឹង ឃើញច្រើន ខ្ញុំឃើញច្រើន ក៏ប៉ុន្តែខ្ញុំមិនសូវជាប់អារម្មណ៍ទេ ព្រោះខ្ញុំខ្វាចវង្វេងបងប្អូន ខ្វាចវង្វេងក្រុមគ្រួសារខ្ញុំហ្នឹង គឺមិនសូវប៉ានមើលអីច្រើនបានយូរ អីអ៊ីចឹងទេ គិតថាខំធ្វើម៉េច ធ្វើដំណើរទៅឲ្យស្រួតៗ។

[១៤:៣៥:៥៨]

**ស៖** តើនៅចន្លោះពីផ្ទះរបស់ឪពុកមារបស់លោកនៅសន្ធរម៉ុក ទៅគល់ស្ពានជ្រោយចង្វា។ នៅចន្លោះតាមផ្លូវហ្នឹងលោកមានបានសង្កេតដែរឬទេ នៅពេលនោះមានឃើញទាហាន ឈរយាមកាមនៅតាមផ្លូវដែរឬទេ? ហើយស្ថានភាពនៅពេលនោះយ៉ាងម៉េចដែរ សូមលោកជួយរៀបរាប់បន្តិចឲ្យបានលម្អិតទៅលើស្ថានភាពនៅពេលនោះ បើសិនជាលោកអាចចាំបានច្រើន? សូមអរគុណ។

**ឆ៖** បាទ ពេលហ្នឹង ពេលដែលខ្ញុំធ្វើដំណើរចាកចេញពីផ្ទះរបស់ឪពុកមាខ្ញុំហ្នឹង ឃើញគេដាក់មុខព្រួញ ប៉ុន្តែខ្ញុំវាមិនចាំថាផ្លូវណាផ្លូវណើ ក៏ប៉ុន្តែខ្ញុំឃើញទាហានខ្មែរក្រហមហ្នឹងជាឯកសណ្ឋានពណ៌ខ្មៅ ពាក់មួកប៉ារ៉េ បង់កក្រមា មានកាន់ ខ្លះកាន់ជាកាំភ្លើងអាកា ខ្លះកាន់ជាកាំភ្លើងអឹមសី ហៅ អឹមសី។ ឈរដាក់ចុងកាណុងទៅក្រោមហ្នឹង។ ដាក់ចន្លោះគ្នាពី១០ម៉ែត្រ ទៅ២០ម៉ែត្រ មួយអ៊ីចឹងទៅ ហើយចុងកាណុងហ្នឹងដាក់ភ្ជង់មកក្រោមអ៊ីចឹង។ ខ្ញុំបានឃើញ ឃើញទិដ្ឋភាពបែបហ្នឹង។ ហើយខ្ញុំមិនសូវប៉ានមើលទេ ខំធ្វើម៉េចចេះតែប្រជៀតរុញគ្នាបន្តិចៗណា ដើម្បីធ្វើដំណើរឲ្យបានដល់កន្លែងទូលាយអីអ៊ីចឹងទៅ។ បាទ យើងខ្ញុំនៅចាំបានប៉ុណ្ណឹង។

[១៤:៣៧:២៦]

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះ លោកបានលើកអំពីថា លោកបានឃើញទិដ្ឋភាពនៃការដែលអ្នកប្រជាជនមួយចំនួនមានរបួស មានរុំរបួស រុំអីដើរតាមផ្លូវ។ តើពេលហ្នឹង លោកមានបានសង្កេតទេថា នៅពេលដែលគាត់មានស្ថានភាពបែបនុំង អ្នកយាមដែលលោកបានលើកឡើងអម្បាញ់មិញថា មានឈរប្រហែលជា១០ម៉ែត្រមួយៗ ហ្នឹងគាត់មានបានជួយយកចិត្តទុកដាក់ដល់ប្រជាជនដែលគ្នាមានស្ថានភាពលំបាកបែបនោះដែរឬទេ?

**ឆ៖** ទេ ខ្ញុំដូចអត់មានឃើញជាកងទ័ពហ្នឹងយកចិត្តទុកដាក់នេះ រឿងអ្នកត្រូវរបួស ត្រូវអីហ្នឹងអីអត់ទេ។ ឃើញតែនៅឈរដូចទីងមោងអ៊ីចឹង។ ក៏ប៉ុន្តែព្រោះគ្រាន់តែថា កន្លែងណារាងទ្រង់ស្ទះចរាចរណ៍អ៊ីចឹងទៅ គ្រាន់តែបានហារមាត់ស្រែកថា "អ្នកមុខដើរឲ្យស្រួត ដើរឲ្យលឿនៗបន្តិច អ្នកក្រោយហ្នឹងនៅកកកុញហើយ"។ គ្រាន់ឮបានថាប៉ុណ្ណឹង។ តែបើសិនជា ខ្ញុំសង្កេតមើលទៅ ឃើញដូចជាគ្មានយកចិត្តទុកដាក់ពីរឿងអ្នកជំងឺ អ្នកអីប៉ុន្មានទេ អត់ទេ។ ខ្ញុំនឹកឃើញបានចាំប៉ុណ្ណឹង។

[១៤:៣៨:៤៩]

**ស៖** តើពេលនោះលោកមានបានសង្កេតទេ តើការដែលប្រជាជនដែលណែនតាន់តាប់ដើរចេញពីទីក្រុងភ្នំពេញហ្នឹង តើលោកមានបានសង្កេតទេ តើមានតែប្រជាជនដែលដើរចេញទេ ឬក៏មានប្រជាជនដើរចូលមកក្នុងទីក្រុងវិញដែរ?

**ឆ៖** បាទ មាន មានខ្លះ មានភាគតិច តែភាគច្រើនដែលត្រូវទៅហ្នឹង គឺទៅច្រើន។ តែភាគតិចដែលត្រឡប់មកវិញ ដូចជាខ្លះវង្វេង វង្វេងបង វង្វេងប្អូន វង្វេងកូន អ្នកខ្លះភ្លេច ជាលុយ ជាកាក់អីអ៊ីចឹងទៅណា។ ឮស្រែកតៗគ្នាអ៊ីចឹងទៅ ភ្លេចយកលុយទៅ ខ្លះភ្លេចនេះ ភ្លេចនោះ។ ក៏ប៉ុន្តែខ្ញុំបានចាំព្រឹត្តិការណ៍ហ្នឹង ហើយខ្ញុំមិនបានជាសួរគេទេ ព្រោះខ្ញុំកាលហ្នឹងមិនទាន់ជាមនុស្ស ដូចជាថាមិនទាន់ពេញវ័យប៉ុន្មានដែរទេ។

**ស៖** អ៊ីចឹងខ្ញុំសូមសួរលោកបន្តទៀត។ នៅពេលដែលលោកធ្វើដំណើរចេញហ្នឹង អំឡុងពេលដែលមានប្រជាជនណែនណាន់តាន់តាប់ហ្នឹងនៅក្នុងចន្លោះរវាងពីផ្ទះឪពុកមា ទៅខាងគល់ស្ពានជ្រោយចង្វាហ្នឹង លោកមានបានប្រទះឃើញប្រជាជនណាដែលគាត់ ដូចថាគាត់នៅស្តាយរបស់របរ ស្តាយផ្ទះសម្បែង គាត់មិនៗព្រមចាកចេញពីផ្ទះដែរទេ? ហើយបើសិនជាមាន តើមានរឿងរ៉ាវអ្វីកើតឡើងចំពោះរូបគាត់ដែរឬទេ នៅពេលនោះ?

**ឆះ** ពេលហ្នឹង ខ្ញុំដូចជាមិនបានចាប់អារម្មណ៍រឿងអ្នកស្លាយរបស់ទ្រព្យ ស្លាយអីទេ គ្រាន់តែថាបានឃើញៗ បានឮ ធ្វើដំណើរជាជួរៗអ៊ីចឹង ហើយគាត់និយាយពិភាក្សាគ្នាថា "អត់មានបានយកអីមកជាប់នឹងខ្លួនទេណ៎ា មិនទាន់បានរៀបចំអីស្រួលបួលផង ស្រាប់តែគេប្រកាសឲ្យចេញរយៈពេលប៉ុណ្ណេះៗថ្ងៃអ៊ីចឹង មិនដែលបានឃើញថាគេនៅក្នុងផ្ទះក្នុងអីគេ ខ្ញុំអត់បានចាប់អារម្មណ៍ទេ។ បាទ ខ្ញុំចាំបានតែប៉ុណ្ណឹងទេ។

[១៤:៤០:៥៦]

**សះ** តើនៅអំឡុងនុំងមានហេតុការណ៍នៃការបាញ់សម្លាប់មនុស្ស នៅក្នុងពេលនោះដែរឬទេ? មានការបាញ់សម្លាប់ ឬក៏ការវ៉ៃធ្វើទារុណកម្មភ្លាមៗនៅនឹងកន្លែងអីដែរឬទេ? លោកមានបានសង្កេត ឬក៏បានជួបប្រទះដែរឬទេនៅពេលនោះ?

**ឆះ** ខ្ញុំៗបានឃើញបុរសម្នាក់។ បុរសម្នាក់ហ្នឹងខ្ញុំអត់ចាំមុខ អត់ចាំភិនភាគ អត់ចាំឈ្មោះទេ។ ឃើញដើរបញ្ច្រាសទិសគ្នា ហើយស្រែថាខ្ញុំបាត់កូនៗ។ ដល់ពេលទៅដក់កន្លែងហ្នឹង ទៅដល់កន្លែងទាហានខ្មែរក្រហមឈរយាមហ្នឹងថា "សូមទោស បងខ្ញុំឲ្យខ្ញុំសុំទៅរកកូនខ្ញុំបន្តិច។ ដល់ពេលនុំង "កូនឯណា អាណាទៅមុនឲ្យទៅមុន អាណានៅក្រោយឲ្យវានៅក្រោយទៅ តែប៊ានត្រេត្រាហ្នឹងតិចប្រយ័ត្នចួសឹង"។ ហើយខ្ញុំវាអត់យល់អាពាក្យ "ចួសឹង"។ បាទមិនដឹងគេចង់និយាយរបៀបម៉េច គេប្រើពាក្យហ្នឹង ខ្ញុំនៅចាំរហូតដល់ប៉ុណ្ណឹងមកនេះ។ ហើយដល់ពេលហើយអ៊ីចឹង ក៏អង្វរ លុតជង្គង់អង្វរគេ ដល់អង្វរគេខ្ញុំឃើញ លើក -- ទាហានខ្មែរក្រហមហ្នឹងលើកកាំភ្លើង ៗទាំងមូលវ៉ៃចំឆ្អឹងខ្នង។ ពេលហ្នឹងប៉ុងទៅឃើញផ្កាប់មុខ។ ផ្កាប់មុខហ្នឹងក្រោកឡើងមកវិញ សុំអង្វរទៀត ក៏ឃើញថាដើរដូចរបៀបមនុស្សអស់សង្ឃឹមៗ ហើយដើរចាកចេញទៅ។ អាហ្នឹងខ្ញុំឃើញព្រឹត្តិការណ៍ហ្នឹង។ ហើយខ្ញុំហ្នឹងដឹកដៃក្រុមគ្រួសារ ក្រុមគ្រួសារឪពុកម្ដាយខ្ញុំ បងស្រីខ្ញុំហ្នឹងដឹកដៃហ្នឹងភ្នែកខ្ញុំងាកមើល ៗទិដ្ឋភាពបែបហ្នឹង។ ដល់ពេលហ្នឹងអ៊ីចឹង ចេះតែ -- ដល់ពេលងាកមើលទិដ្ឋភាពបែបហ្នឹង គឺដំណើរខ្ញុំកាន់តែយឺតមែនទែន។ ដល់ពេលហើយអ៊ីចឹង ឪពុកម្ដាយបងប្អូនខ្ញុំថា "អាល័យមើលអី? សម្លុតខ្ញុំ អាល័យមើលអី? ដើរឲ្យលឿនៗមក"។ ដល់ពេលហ្នឹង ក៏ខ្ញុំក៏បោះបង់ចោលពីការមើល ការចាប់អាម្មណ៍នោះ ធ្វើឲ្យខ្ញុំហ្នឹងបែរមុខទៅរក -- សំដៅទៅទិសដៅខាងមុខវិញ។ បាទខ្ញុំនាំចាំបានប៉ុណ្ណឹង។

[១៤:៤៣:១៦]

**ប្រធានអង្គជំនុំះ**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាក នៅបន្ទប់រង់ចាំសម្រាប់សាក្សី អ្នកជំនាញ ដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលសម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៣ នាទី ដល់ម៉ោង ១៥:១២ នាទី)*

[១៥:១២:០៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទទួលសិទ្ធិ ដើម្បីបន្តការតាំងសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** ខ្ញុំសូមធ្វើការតាំងសំណួរទៅលោកបន្តទៀត។ ដោយសារតែមុននេះបន្តិចហ្នឹង លោកបានឆ្លើយពាក់ព័ន្ធជាមួយនឹងស្ថានភាព ដែលលោកត្រូវបានផ្លាស់ទីលំនៅពីខាងផ្ទះរបស់លោក នៅខាងជ្រោយចង្វា អ៊ីចឹង ខ្ញុំសូម -- នៅខាងស្រុកមុខកំពូល អ៊ីចឹង ខ្ញុំសូមធ្វើការបញ្ជាក់បន្តិច ដោយសារខ្ញុំបានអានទូវឯកសាររបស់លោក ពាក់ព័ន្ធនឹងពាក្យបណ្តឹងរបស់លោក ហើយអ៊ីចឹង ខ្ញុំសូមធ្វើការបញ្ជាក់បន្តិច។ --

**លោកស្រី ទី ស្រ៊ីនណា៖**

--ដូច្នេះ ខ្ញុំស្នើសុំលោកប្រធានអនុញ្ញាតឲ្យនាងខ្ញុំប្រើប្រាស់ នូវឯកសារដែលមានទម្រង់ជាពាក្យបណ្តឹងរបស់គាត់ ដែលមានលេខ D22/1352។ សូមការអនុញ្ញាតលោកប្រធាន ដើម្បីប្រើប្រាស់ឯកសារនេះ។

[១៥:១៣:៣៩]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន។ ឯកសារ -- ខ្ញុំនឹងប្រើនៅទំព័រ ERN ជាភាសាខ្មែរ 00526165 ហើយជាភាសាអង់គ្លេស ដែលមាន 00866007។ ហើយឯកសារនេះមាន ខ្ញុំបានស្រាវជ្រាវរកទៅឃើញតែមានភាសាខ្មែរ និងភាសាអង់គ្លេសប៉ុណ្ណោះ។ ហើយខ្ញុំនឹងសូមធ្វើការបញ្ជាក់នឹងកូនក្តីរបស់ខ្ញុំនាពេលនេះ។

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** ខ្ញុំនឹងសូមអាននូវចំណុចមួយ ចុងក្រោយ ត្រង់កថាខណ្ឌចុងក្រោយ។ ខ្ញុំស្នើសុំឱ្យលោក គឹម វ៉ាន់ឌី ធ្វើការស្តាប់នូវចំណុចហ្នឹង ហើយនិងសូមឱ្យលោកធ្វើការឆ្លើយបំភ្លឺ។ “នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលដែលទាហានឈុតខ្មៅខ្មែរក្រហមចូលដល់ភូមិខ្ញុំ ក៏ដូចជាទីក្រុងភ្នំពេញ ពួកគេបានបាញ់កាំភ្លើងគំរាមបង្ខំឱ្យក្រុមគ្រួសារខ្ញុំ ក៏ជាដូចជាគ្រួសារប្រជាពលរដ្ឋដទៃទៀត ឱ្យចាកចេញពីផ្ទះទៅរស់នៅតំបន់ជនបទវិញ។ នៅក្នុងពេលនោះឪពុករបស់ខ្ញុំ បានទទួលព័ត៌មានថា ឪពុកមារបស់ខ្ញុំឈ្មោះ អ៊ំយ៉ន –បងរបស់ម្តាយខ្ញុំបង្កើតដែលធ្វើទាហានពាក់ស័ក្តិ៥ មានផ្ទះនៅសន្ធរមុខក្រុងភ្នំពេញ– ត្រូវទាហានខ្មែរក្រហមចូលបាញ់សម្លាប់ចោលនៅក្នុងផ្ទះរបស់គាត់តែម្តង”។ អ៊ីចឹង ខ្ញុំសូមធ្វើការបញ្ជាក់ជាមួយលោកបន្តិច ទាក់ទងជាមួយនឹងព័ត៌មានដែលលោកបានរៀបរាប់ពីខាងដើមថា លោកបានឃើញហេតុការណ៍ឪពុកមារបស់លោកហ្នឹងត្រូវគេ ត្រូវពួកខ្មែរក្រហមសម្លាប់។ អ៊ីចឹងលោកបានឃើញដោយផ្ទាល់ ឬក៏ឪពុកលោកជាអ្នកឃើញ?

[១៥:១៦:១០]

**លោក គឹម វ៉ាន់ឌី៖**

**ឆ៖** ពេលហ្នឹង មិនមែនជាឪពុកខ្ញុំជាអ្នកឃើញទេ ព្រោះឪពុកខ្ញុំហ្នឹង គាត់នៅបន្ទាយគាត់ ក៏ប៉ុន្តែមិនដឹងជា គាត់នៅមន្ទីរឯណាឯណី ខ្ញុំអត់បានដឹងទេ តែពេលហ្នឹងទេ ឮស្នូរកាំភ្លើងហ្នឹងគឺខ្ញុំហ្នឹងបើកបង្អើបទ្វារហ្នឹងចូលមកមើល ចេញមកមើល បើកបង្អើបទ្វារមកមើលទេ។ តែតាមការពិតហ្នឹងមិន

មែនទេ ឪពុករបស់ខ្ញុំហ្នឹងបានទទួលព័ត៌មានពីខាងម្ដាយខ្ញុំអ៊ីចឹង ដែលពេលគាត់រត់ពីកន្លែងបន្ទាយគាត់មកដល់ផ្ទះខាងឪពុកមាខ្ញុំទេ។ បាទ ដែលខ្ញុំនៅចាំបានប៉ុណ្ណឹង។

**ស៖** ចាស សូមអរគុណ។ ហើយខ្ញុំសូមបំភ្លឺកន្លែងមួយទៀត ទាក់ទងទៅនឹងការធ្វើដំណើរពី -- នៅក្នុងនេះដែរ លោកក៏បានលើកអំពីការចាកចេញពី -- ក្រុមគ្រួសាររបស់លោកហ្នឹង ត្រូវបានទាហានខ្មែរក្រហមហ្នឹងបង្ខំឲ្យចេញពីផ្ទះ គំរាមបង្ខំឲ្យចេញពីផ្ទះដែលនៅស្រុក -- គំរាមឲ្យចេញពីផ្ទះនៅភូមិ។ តើលោកអាចនៅចាំបានទេ នៅថ្ងៃ១៧ មេសា នោះគឺជាថ្ងៃដែលលោក ពួកខ្មែរក្រហមចូលមកគំរាមឲ្យចេញពីផ្ទះនៅនឹងភូមិ ឬក៏ចេញពីផ្ទះនៅខាងសន្ធរម៉ុក? តើកន្លែងហ្នឹងមានភាពខុសគ្នាយ៉ាងម៉េចដែរ? លោកសូមលោកជួយបំភ្លឺអំពីបញ្ហាហ្នឹងបន្តិចជូនអង្គសវនាការ។

**ឆ៖** ខ្ញុំដូចស្ដាប់សំណួរអត់បានច្បាស់អ៊ីចឹង។

**ស៖** សូមអរគុណ។ ខ្ញុំនឹងធ្វើការកែសំណួររបស់ខ្ញុំឲ្យស្រួលស្ដាប់បន្តិច។ កន្លែងនេះ ខ្ញុំអត់សូវយល់នូវឃ្លាហ្នឹង ថាតើវាមានភាពខុសគ្នារវាងការឆ្លើយពីមុនហ្នឹងបន្តិច ថាតើនៅកន្លែងនេះលោកបានសរសេរថា "នៅថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ ពេលដែលទាហានឈុតខ្មៅខ្មែរក្រហម ចូលដល់ភូមិខ្ញុំ ក៏ដូចជាទីក្រុងភ្នំពេញ ពួកគេបានបាញ់កាំភ្លើង គំរាមបង្ខំឲ្យក្រុមគ្រួសារខ្ញុំ ក៏ដូចជាគ្រួសារប្រជាពលរដ្ឋដទៃទៀត ឲ្យចាកចេញពីផ្ទះទៅរស់នៅតំបន់ជនបទវិញ"។ អ៊ីចឹង កន្លែងហ្នឹង ខ្ញុំសូមបញ្ជាក់បន្តិចថាតើថ្ងៃដែលគេចូលមកហ្នឹង ថ្ងៃ១៧ មេសា ហ្នឹង ឬក៏យ៉ាងម៉េច? នៅនឹងភូមិណា មានន័យថា ខ្មែរក្រហមគំរាមនៅនឹងភូមិហើយ ហើយអ៊ីចឹងវាមានការខុសគ្នារវាងការគំរាមនៅនឹងភូមិហើយបានលោកមកផ្ទះឪពុកមាលោក ឬក៏យ៉ាងម៉េច? សូមលោកជួយបញ្ជាក់បន្តិចមក តើថ្ងៃ១៧ មេសា ហ្នឹងដដែល ឬក៏យ៉ាងម៉េច?

[១៥:១៩:១០]

**ឆ៖** បាទ តាមការពិត ថ្ងៃហ្នឹងជាថ្ងៃ១៦ មេសា ទេ ដែលខ្ញុំនៅចាំបាន ថាថ្ងៃហ្នឹងជាថ្ងៃ១៦ មេសា តែក៏ប៉ុន្តែកងទ័ពហ្នឹង គឺខ្ញុំមិនបានផ្ដោតសំខាន់ទៅលើកងទ័ពខាងណាខាងណីទេ តែក៏ប៉ុន្តែឃើញកងទ័ពហ្នឹងមានឈុតខ្មៅៗ ហើយបានស្រែកមកថា "ចុះមិនចាកចេញទៅ? នៅចាំដល់អង្កាល់ទៀត?" ពេលហ្នឹងក៏ខ្ញុំមិនចាប់អារម្មណ៍ចាប់អីទេ ហើយក្រុមគ្រួសារខ្ញុំហ្នឹងបានឆ្លើយតបថា "ចាំឲ្យស្ងាត់គ្រាប់ផ្លោងបន្តិច ចាំបានទៅបាន"។ ពេលហ្នឹងដល់ពេលរង់ចាំទៅឃើញថាវាជិតនឹងពាក់កណ្ដាលអធ្រាត្រហើយ ហ្នឹងបើសិនជាយើងប៉ាន់ស្មានមើលនាឡិកាក៏វាលោតនៅពេលហ្នឹងដែរ។ វាប្ដូរវេនប្ដូរនៅពេល

ហ្នឹងដែរ។ ក៏នាំគ្នាទៅ ស្រាប់ដល់ពេលព្រលឹមឡើងនោះៗ ហ្នឹងថ្ងៃទី១៧ មេសា ហ្នឹងស្រាប់តែឃើញថា មនុស្សប៉ោកព្រៀវកុះករណ៌ះ ឮសំឡេងរំពងណាស់ នេះខ្ញុំឆ្ងល់ ឆ្ងល់ដោយសារអីហ្នឹង? ចេះតែដើររត់មើលគេមើលឯងហើយ អង្កាល់ហ្នឹងវាដូចថា វាមិនទាន់ជាវ័យចំណាស់អីអីចឹង នៅក្មេងនៅរៀនអីចឹង នៅសប្បាយណាស់ រត់ទៅមើលទៅគេថា អ្អូក! ស្អីដូចជាឮថានៅចាំថា កងទ័ពខ្មែររំដោះរំដោះទីក្រុងភ្នំពេញបានទាំងមូលហើយអីអីចឹងអ្អឹ! បាទ លើកទៅ ខ្លះលើកទង់ជ័យស រកទង់ជ័យសដោតតាមផ្ទះ ខ្លះអត់ហ្នឹង ខ្ញុំដោះអាវសិស្សគ្រវី គ្រវីសប្បាយនឹងគេទៅ កាលហ្នឹងស្លៀកអាគេហៅថា ស្លៀកខោបារាំង ខោគេហៅថា បារាំងពណ៌ខៀវ ហោប៉ៅជ្រែង។ ដោះអាវហ្នឹងលើកគ្រវីនឹងគេនឹងឯងអីចឹងទៅ។ បាទ ខ្ញុំនៅចាំបានប៉ុណ្ណឹង។ តែបន្ទាប់មកទៀត គឺខ្ញុំក្រោយពីហ្នឹងមក ពេលដែលឪពុកខ្ញុំនោះរត់ពីបន្ទាយគាត់មកដល់សន្លរម៉ុកនោះ ខ្ញុំបានសួរៗទៅគាត់ថា “ឪពុកទាហានស្អីស្លៀកពាក់ខ្មៅដែរ”។ គាត់ថា “អាហ្នឹងទាហានពិសេស ៗរបស់រដ្ឋាភិបាល”។ ប៉ុន្តែខ្ញុំហ្នឹងមិនស៊ីជម្រៅដល់រដ្ឋាភិបាលទេព្រោះអត់ស្គាល់។ អត់ស្គាល់ទេរដ្ឋាភិបាល អាហ្នឹងគេហៅទាហានពិសេសហ្នឹង ស្លៀកពាក់ឈុតខ្មៅគេថាស្អី គាត់និយាយបញ្ជាក់ថាអាហ្នឹង ស្អែកស្អាប់ ស្អែករស់អាម៉េចគេទេ។ បាទ ហើយខ្ញុំក៏មិនចាប់អារម្មណ៍អីដែរ។ ខ្ញុំក៏ឈប់ដេញដោលពេលហ្នឹងទៅ។ អាហ្នឹងខ្ញុំនៅចាំសួរដេញដោលជាមួយពុកខ្ញុំប៉ុណ្ណឹង។

[១៥:២២:១៣]

**ស៖** សូមអរគុណ។ អម្បាញ់មិញលោកបានលើកឡើងថា ចេញពីផ្ទះទាំងកណ្ដាល -- ទាំងយប់តើលោកថា លោកទៅ ចេញទៅណាដែរពេលនុ៎ង?

**ឆ៖** ពេលហ្នឹង ខ្ញុំធ្វើដំណើរពីផ្ទះខ្ញុំនៅជ្រោយចង្វា មុខកំពូល ខេត្តកណ្ដាលហ្នឹង ទៅសន្លរម៉ុកផ្ទះរបស់ឪពុកមារបស់ខ្ញុំ។

**ស៖** សូមអរគុណ។ អីចឹងឥឡូវខ្ញុំសូមបង្វែរសំណួរខ្ញុំពាក់ព័ន្ធជាមួយនឹងការធ្វើដំណើររបស់លោកវិញ។ ពីមុនខ្ញុំបានសួរលោកពាក់ព័ន្ធជាមួយនឹងការធ្វើដំណើរហ្នឹង តើលោកធ្វើដំណើររយៈពេលប៉ុន្មានដែរ ទើបចេញផុតពីទីក្រុងភ្នំពេញនៅក្នុងអំឡុងពេលនុ៎ង?

[១៥:២៣:០៧]

**ឆ៖** ខ្ញុំធ្វើដំណើរហ្នឹងប្រហែលជាខ្ទង់ម៉ោង បើគិតមើលជាថ្ងៃ ៗ ប្រហែលជាថ្ងៃត្រង់ ខ្ញុំចេញពីសន្លរម៉ុក ធ្វើដំណើរមកគល់ស្ពានជ្រោយចង្វាហ្នឹងតាមផ្លូវជាតិលេខ៦ហ្នឹង ខំប្រឹងដើរ ខំប្រឹងកន្លែងណា

ដែលមិនចង្អៀតទៅដើរលឿន កន្លែងណាគេចង្អៀតទៅដើរបានយឺតអ៊ីចឹង។ ខំស្រូតៗ គេចឆ្ងាយពីទីក្រុងភ្នំពេញ ក៏ប៉ុន្តែមិនដឹងជាធ្វើដំណើរហ្នឹងដល់កន្លែងណាអីកន្លែងណា ខ្ញុំមិនបានដឹងទេ។ ខ្ញុំបានសួរតែឪពុកម្ដាយខ្ញុំថា ដល់កំពង់ចម្លងៗ តែប៉ុណ្ណឹងឯង។ ខ្ញុំចាំបានតែប៉ុណ្ណឹង។ ត្រើយខាងលិច បញ្ជាក់ថាត្រើយខាងលិចទៀត។

**ស៖** លោកថា ពេលនុ៎ងមានមនុស្សច្រើន តើមនុស្សច្រើនកកកុញហ្នឹង តើលោកមានដឹងថាពួកគាត់មកពីខាងណាដែរឬទេពេលនុ៎ង ដូចថា ជាមនុស្សដែលអ្នកទីក្រុងភ្នំពេញសុទ្ធសាធ ឬមួយក៏មានអ្នកមកពីបណ្ដាខេត្តដែរ?

[១៥:២៤:៣៥]

**ឆ៖** បាទ ពេលហ្នឹងខ្ញុំមិនបានចាប់អារម្មណ៍គយគន់មនុស្សមកពីណាទេ។ ខ្ញុំប្រហែលជាថាមនុស្សហ្នឹងនៅក្នុងទីក្រុងតែម្ដង ដែលធ្វើដំណើរចេញទៅហ្នឹង ព្រោះខ្ញុំវាអត់បានដឹងសភាពការណ៍អី។ ព្រោះខ្ញុំអង្គាល់នុ៎ងនៅជាក្មេងសិស្សសាលា គេហៅថា ក្មេងសិស្សសាលា មិនទាន់ស៊ីជម្រៅពាក្យអ្វីៗបានច្រើន បាទ។

**ស៖** ចាស សូមអរគុណ។ ហើយតើពេលហ្នឹងក្រុមគ្រួសាររបស់លោកហ្នឹងមានគោលដៅត្រូវទៅដែរឬទេ ឬមួយក៏មានការចង្អុលបង្ហាញអំពីអ្នកដែលតម្រូវឲ្យខាងក្រុមគ្រួសាររបស់លោក ក៏ដូចជាប្រជាជនដទៃទៀត ចាកចេញពីទីក្រុងភ្នំពេញ?

**ឆ៖** បាទ ក្រុមគ្រួសារខ្ញុំគ្មានគោលដៅនឹងត្រូវចាកចេញពីទីក្រុងភ្នំពេញទេ។ តាមពិតចង់រស់នៅក្នុងហ្នឹង ព្រោះគិតថាប្រសិនជាចាកចេញទៅ វាដូចជាថានឹកនៅស្ដាយអីអ៊ីចឹង។ ដល់ពេលគេឃើញគេចេញ ចេញតាមគេតាមឯងអ៊ីចឹងទៅ។ ព្រោះពេលហ្នឹងពួគេដើរឃោសនា ដើរនិយាយអ៊ីចឹងទៅថាចេញតែ៣ថ្ងៃទេ ៣ថ្ងៃហ្នឹងគេ កងទ័ពគេហ្នឹង គេរៀបចំៗបោសសម្អាតខ្លាំង។ ហើយខ្ញុំហ្នឹងនៅជាសិស្សសាលា មិនដឹងខ្លាំងអីរបៀបម៉េច អីរបៀបម៉េចទេ អត់បានដឹងទេ។ មិនដឹងអ្នកណាខ្លាំង មិនដឹងអ្នកណាសត្រូវអី ដូចថា សូម្បីតែខ្ញុំរៀនអក្សរហ្នឹង រៀនដល់ ក៏ប៉ុន្តែវាអត់ទាន់ដឹងថាឃើញថាជាក់ស្ដែងពិតប្រាកដ ថាយ៉ាងម៉េចយ៉ាងណា បាទ តាមខ្ញុំដឹង។

[១៥:២៦:២៣]

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំសូមសួរបន្តទៀត ថាតើនៅពេលដែលក្រុមគ្រួសាររបស់លោកដើរចេញទៅតាមផ្លូវហ្នឹងមានគេប្រាប់អំពីទិសដៅ ដែលខាងក្រុមគ្រួសារលោកទាំងអស់ គេមានចង្អុលទិសដៅឱ្យក្រុមគ្រួសារលោកទៅដែរឬទេ?

**ឆ៖** បាទ ពេលហ្នឹងខ្ញុំឃើញអាហ្នឹងមិនដឹងជាគេហៅផ្លូវស្អីទេ ដូចជាខ្ញុំចាំមើលថា ខាងស្តាំនិងខាងឆ្វេងមិនដឹងទេ នៅជាប់នឹងគល់ស្ពានជ្រោយចង្វា អាកន្លែងសព្វថ្ងៃហ្នឹង គេដាក់បិទរបងហ្នឹង។ ឃើញមានទាហាននៅក្នុងហ្នឹងបួននាក់នៅខាងណេះក៏មាន ខាងណោះក៏មាន ហើយចន្លោះកណ្តាលៗចិញ្ចើមថ្នល់ហ្នឹងទុកឱ្យប្រជាជនធ្វើដំណើរហ្នឹង គឺឃើញគេដាក់ គេថាដេញឱ្យទៅអ៊ីចេះ ៗទៅតាមផ្លូវជាតិលេខ៦អ៊ីចេះ។ ហើយដល់ពេលអ្នកខ្លះហ្នឹង ខ្ញុំឃើញថា វាអត់យល់អីអ៊ីចឹង វាបានសម្តុតសួរថា "អត់ឃើញមុខកាំភ្លើងគេដាក់ទៅហ្នឹងទេ អត់ចេះមើលមែន!"។ ខ្ញុំថា អីយ៉ាស់ អានេះកាចតើវ៊ី! បាទខ្ញុំថាអ៊ីចឹង ខ្ញុំបាននិយាយពោលពាក្យ "អីយ៉ាស់អានេះកាច" ខ្ញុំថាអ៊ីចឹង។ ហើយដល់ពេលម្តាយខ្ញុំថា "អីកុំមាត់ កូនឯងថាអីអ៊ីចឹង ប្រយ័ត្នគេឮ"។ ហើយខ្ញុំក៏លែងថា ខ្ញុំចេះតែដើរទៅទៀតទៅ។

[១៥:២៨:០៨]

**ស៖** ពេលនោះ ក្រុមគ្រួសាររបស់លោកហ្នឹង ចេះតែដើរទៅៗ។ អ៊ីចឹងខ្ញុំចង់សួរថា តើពេលហ្នឹងក្រុមគ្រួសាររបស់លោកហ្នឹង ដើរទៅកន្លែងណាដែរ? ទៅស្នាក់ទៅឯណា? ហើយមានគោលបំណងថាចង់ទៅស្នាក់នៅឯណាដែរ ហើយចង់រស់នៅឯណា? ឬក៏យ៉ាងម៉េចដែរពេលហ្នឹង? លោក សូមលោកជួយរៀបរាប់ឱ្យលម្អិតបន្តិចមក អំពីដំណើរខ្សែជីវិតរបស់ក្រុមគ្រួសារលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង ថាតើវាប្រព្រឹត្តទៅយ៉ាងម៉េចដែរនៅអំឡុងពេលដែលគេតម្រូវឱ្យក្រុមគ្រួសាររបស់លោកហ្នឹងចាកចេញពីផ្ទះ ហើយជាពិសេសចាកចេញពីទីក្រុងភ្នំពេញនោះ?

**ឆ៖** បាទ ដែលក្រុមគ្រួសារខ្ញុំដែលមានបំណង គោលដៅដែលត្រូវធ្វើដំណើរចាកចេញពីភ្នំពេញទៅកាន់កន្លែងដែលស្នាក់នៅហ្នឹង គឺម្តាយឪពុកខ្ញុំហ្នឹងបានមានប្រសាសន៍ថា "យើងទៅឱ្យឆ្ងាយពីទីក្រុងភ្នំពេញបន្តិចកូន" ហើយបើសិនជាថា យើងឆ្ងាយ -- នៅកៀកទីក្រុងភ្នំពេញអ៊ីចឹង ភាពចលាចលហ្នឹងកើតឡើងហ្នឹង គឺទំនិញទិញដូរ លក់ដូរអីហ្នឹង គឺវាឡើងថ្លៃណាស់។ អ៊ីចឹងទៅឱ្យឆ្ងាយបន្តិច។ ហើយបើសិនជាយើងមិនបានជាប់ជាលុយជាកាក់ហ្នឹងមកច្រើនលើសលប់មែន ក៏ប៉ុន្តែយើងអាចថាមានលុយប្រាក់មួយចំនួនគ្រាន់តែសម្រាប់ទិញតែអង្ករ តែម្ហូបយើងអាចដើររកតាមវាលស្រែបាន។ អ៊ីចឹងឃើញថាខ្ញុំហ្នឹងទៅដល់កំពង់ចម្លង ប៉ុន្តែខ្ញុំហ្នឹងអត់ស្គាល់អីទេ ព្រោះនៅពីតូចៗ ខ្ញុំមិនបានចេះនាំ ឪពុកម្តាយខ្ញុំ

នាំដើរលេងឆ្ងាយៗអ៊ីចឹងទេ។ ប៉ុន្តែគ្រាន់តែថា ពេលហ្នឹងខ្ញុំសួរពុករបស់ខ្ញុំថា "ពុកដល់ណា?" ពុកខ្ញុំក៏ឆ្លើយថា "ដល់កំពង់ចម្លង"។ ដល់ហើយ ក៏ខ្ញុំមិនចាប់អារម្មណ៍ ខ្ញុំថា "អ៊ូ កំពង់ចម្លងមានទឹកទន្លេដែរ"។ ខ្ញុំថា "អ៊ីចឹង", ប្អូនថា " អើ គេចម្លងឡានចម្លងអី បើមិនប្រើទឹកទន្លេ"។ អ៊ីចឹងខ្ញុំក៏មិនចាប់អារម្មណ៍ចាប់អីទៀតដែរ។ ក៏នៅសម្រាកត្រើយខាងលិច តែធ្វើដំណើរទៅហ្នឹងគ្មានទេ គ្មានកន្ទេល គ្មានមុង គ្មានអីទេបាទ ព្រោះនឹកឃើញថាវា ៣ថ្ងៃទេ ធ្មេចបើកៗវាដល់ហើយ វាដល់ពេលហ្នឹងវិញហើយ។

[១៥:៣០:២៤]

ដល់ពេលហ្នឹងហើយ ឃើញមានដើមឈើ ដើមរាំងៗ ចាំច្បាស់ថាដើមរាំង ឃើញមានដើមរាំងហ្នឹងស្អាតល្មមអាចទៅៗស្នាក់នៅហ្នឹង។ ក៏កាច់ស្លឹកឈើស្លឹកអីនៅតាមចិញ្ចើមៗផ្លូវហ្នឹងដាក់ក្រាលចុះអាយើង គេហៅថាជើងទេររបស់ផ្លូវហ្នឹង ចុះទៅបន្តិចទៅ យើងដល់កន្លែងដើមរាំងហ្នឹងហើយ។ ចុះទៅដេកស្នាក់នៅហ្នឹង១យប់។ ពេលហ្នឹង ខ្ញុំដេកមិនដែលលក់ទេ ព្រោះធ្លាប់នៅផ្ទះមានមុង មានស្អីគ្រប់បែបសព្វយ៉ាង ពេលខ្ញុំធ្វើដំណើរទៅហ្នឹង ឃើញថាវាមានមូសខាំ មូសអីគ្រប់គ្រាន់ ថាពិបាកណាស់ធ្វើឲ្យខ្ញុំពិបាកវេទនាមែនទែន។ ហើយម្ដាយខ្ញុំ ចេះតែស្ដីបន្ទោសខ្ញុំថា "ទ្រាំទៅកូនហើយវាអត់យូរទេ តែ ៣ថ្ងៃទេកូន យើងនឹងបានទៅដល់ផ្ទះដល់សម្បែងយើងវិញហ្នឹង យើងរស់នៅបានសប្បាយដូចពីមុនៗមកអ៊ីចឹង"។ ខ្ញុំចាំពាក្យភាសាគាត់ ដែលគាត់និយាយដាក់ខ្ញុំអ៊ីចឹង ហើយនិងដាក់បងជីដូនមួយខ្ញុំ។ ពន្យល់ៗ ពន្យល់ឲ្យខ្ញុំអ៊ីចឹង។ ខ្ញុំចាំៗបានប៉ុណ្ណឹង។

**សៈ** សូមអរគុណ។ ហើយតើពេលនុ៎ងរបបនៃការហូបចុកយ៉ាងម៉េចដែរ នៅពេលដែលនៅក្រោមដើមឈើហ្នឹង ហើយពេលហ្នឹងលោកនៅស្នាក់នៅទីនោះរយៈពេលប៉ុន្មានដែរ? ហើយនិងរបបហូបចុកយ៉ាងម៉េចដែរ? ការហូបចុកអីៗគេមានការឧបត្ថម្ភពីខាងទាហានខ្មែរក្រហម ដែលនៅតំបន់នោះអីដល់ក្រុមគ្រួសាររបស់លោកដែរឬទេ?

**ឆៈ** បាទដូចជាអត់ឃើញមានខាងទាហានខ្មែរក្រហមណាឧបត្ថម្ភទេ បាទអត់មានទេ។ ពេលហ្នឹងឃើញតែម្ដាយខ្ញុំហ្នឹងដើរទៅខ្ចីកូនឆ្នាំងគេមួយល្មម យកមកដាំទឹកស្រុះមីទទួលទាន។ តែមីហ្នឹងខ្ញុំនៅចាំបានថា មីហ្នឹងមីរូប ប្រអប់វានៅក្រដាស ប្រអប់វាធ្វើពីក្រដាស ហើយដាក់រូបបង្កងៗ។ ខ្ញុំនៅចាំបានពីសង្គម លន់ នល់ ក៏ប៉ុន្តែគ្រាន់តែថាឲ្យខ្ញុំទៅចាំរោងចក្រផលិតនៅត្រង់ណាៗ ខ្ញុំអត់បានចាំទេ។ ក៏ប៉ុន្តែឃើញឲ្យផុងមីឲ្យហូបៗ។ ហ្នឹង គឺម្ដាយឪពុករបស់ខ្ញុំហ្នឹង។

[១៥:៣៣:០១]

**សៈ** តើក្រុមគ្រួសាររបស់លោក រស់នៅកំពង់ចម្លងហ្នឹងរហូត ឬក៏យ៉ាងម៉េចដែរ?

**ឆៈ** បាទ ក្រុមគ្រួសារខ្ញុំមិនបានរស់នៅក្នុងកំពង់ចម្លងនោះរហូតទេ។ ពេលព្រលឹមឡើងភ្លឺស្រាងៗហ្នឹង ក្រុមគ្រួសារខ្ញុំហ្នឹងក៏បានឆ្លងទៅត្រើយខាងកើតវិញ ឆ្លងទៅត្រើយខាងកើតហ្នឹងថា ក្រែងលោទៅរកអាកន្លែងដែលគួរសមជាងគេងនៅពីយប់។ ដល់ពេលទៅហ្នឹងគឺថា ឃើញថាទៅរកបានអាសំយាបផ្ទះគេមួយៗហ្នឹង ក៏ស្នាក់នៅសុំស្នាក់នៅ សុំគេហ្នឹង គេថា "មិនបាច់សុំស្នាក់នៅអីទេ សុទ្ធតែអ្នកដំណើរដូចគ្នាទេ"។ អ៊ីចឹងក៏ស្នាក់នៅជុំគ្នាហ្នឹងទៅ។ ហើយក៏ចេះតែយប់ឡើងប្រាជ្ញលេងគ្នាទៅថា "សួរនៅណា? អីណាទៅ?" កាលហ្នឹងចាស់ៗសួរ ហើយឃើញថាខ្ញុំហ្នឹងមិនបានចាប់អារម្មណ៍សួរអីដល់ នៅអង្គុយស្ដាប់អង្គុយអីគាត់ទេ។ គ្រាន់គិតថាប្រមូលអារម្មណ៍ដែរថា ដឹងថានៅក្នុងគោលដៅវិញថាប្រហែលជា៣ថ្ងៃហ្នឹង ខ្ញុំបានទៅរៀនវិញហើយណោះម៉ែ? ខ្ញុំសួរម្ដាយខ្ញុំថា "អើ កូនបើគេឲ្យយើងចេញតែ៣ថ្ងៃ ក្រោយពី៣ថ្ងៃទៅ កូនឯងអ៊ីចឹងបានទៅសាលា ទៅអីវិញធម្មតាហើយ"។ ខ្ញុំទៅសួរគាត់ដល់កម្រិតហ្នឹង។ ដល់តែពេលហើយ ដេក១យប់ ដេកនៅត្រើយខាងកើតហ្នឹង១យប់ ស្អែកឡើងរង់ចាំ១យប់ទៀតៗ ដល់យប់ទី៣នោះ ឃើញគេដូចជា គ្មានឃើញប្រជាជនណាធ្វើដំណើរចូលទៅទីក្រុងភ្នំពេញវិញសោះ។ ដល់ពេលហ្នឹងឆ្ងល់ ចាប់ផ្ដើមឆ្ងល់ៗហ្នឹង គឺថា ចាប់ផ្ដើមឆ្ងល់អ៊ីចឹងក៏ឃើញថាម្ដាយខ្ញុំហ្នឹងទៅសួរៗហ្នឹង មិនដឹងជាកងឈ្លប មិនដឹងទាហានទេ ក៏ប៉ុន្តែមានឃើញកាន់កាំភ្លើង ប៉ុន្តែអត់មាន ដូចជាអត់មានមួកពាក់ទេ ប៉ុន្តែពាក់ស្បែកជើង ព្រោះវាអត់មានសញ្ញាអីជាសម្គាល់ថាអាហ្នឹងជាទាហាន ឬក៏ជាឈ្លបអី។ អត់បានដឹងទេ។ ដល់ពេលសួរថា សួរទៅ គេក៏បានឆ្លើយប្រាប់ថា "ស្រុកមីងឯងនៅឯណា? ថាស្រុកខ្ញុំនៅកំពត។ ស្រុកមីងឯងនៅណា? ទៅហ្នឹងវិញទៅ"។ បាទ ដល់ពេលហើយអ៊ីចឹង "អុញ! ចុះថាចេញតែ៣ថ្ងៃ ហើយឥឡូវស្រាប់ថា ស្រុកឯណា ទៅហ្នឹងវិញអ៊ីចឹង។ ទៅរៀបចំទៅ"។ ដល់ពេលហើយអ៊ីចឹង អូ កាន់តែម្ដាយខ្ញុំហ្នឹង ហើយឪពុកខ្ញុំ កាន់តែយល់ជ្រួតជ្រាបអ៊ីចឹង។ ហើយដល់ពេលហើយអ៊ីចឹង អ៊ីចឹង ខ្ញុំសូមឆ្លងទៅកាន់ត្រើយខាងលិចវិញ ដើម្បីទៅកំពត។ ថា "អត់ទេ មុខឆ្លងមកហើយ ទៅតែម្ដងទៅ"។ ពេលហ្នឹងក៏ខ្ញុំ ក្រុមគ្រួសារខ្ញុំក៏បានធ្វើដំណើរតាមហ្នឹងរហូត ដូចជាទៅតាមហ្នឹងទៅ ខ្ញុំនៅចាំថា ភូមិហ្នឹង គេហៅភូមិទួលៗ ក៏ប៉ុន្តែអត់ដឹងឃុំអីទេ។ ប្រហែលជាខ្ទង់បាធាយហ្នឹងឯង បាទ។ ភូមិទួល តែដឹងថា ខេត្តកំពង់ចាម។

[១៥:៣៦:៤១]

ទៅស្នាក់នៅហ្នឹង ប្រហែលជាបើមិន១អាទិត្យ ២អាទិត្យដែរ។ បាទ ទៅហ្នឹង ឃើញខាងគេហៅថា "មូលដ្ឋាន១"។ ប្រជាជនមូលដ្ឋាន គេនិយាយអ៊ីចេះ គេថា គេជួយ ឃើញថា គេឲ្យស្រូវឲ្យអីអ៊ីចឹងទៅ ដោយសារយើងមានជាសម្លៀកបំពាក់ល្អ១បន្តិច១ទៅ យើងឲ្យគេមួយកំប្លេ ឬក៏ពីកំប្លេអីអ៊ីចឹងទៅ គេឲ្យជាស្រូវ ឲ្យជាអង្ករយើង ឲ្យជាឆ្នាំង ឲ្យជាអីដាំបាយអីអ៊ីចឹងទៅបាទ។ ឃើញពេលហ្នឹង ឃើញឪពុកម្ដាយខ្ញុំហ្នឹងទៅបានទៅនិយាយជាមួយក្រុមគ្រួសារមូលដ្ឋានហ្នឹងថា "ចង់សុំស្នាក់នៅនៅភូមិទួលហ្នឹង" ឃើញគេនាំម្ដាយខ្ញុំហ្នឹង ហើយមូលដ្ឋានហ្នឹង ឡើងទៅ ប៉ុន្តែមិនដឹងឡើងទៅកន្លែងណា ខ្ញុំអត់បានដឹងទេ ព្រោះខ្ញុំអត់បានទៅជាមួយគាត់។ យើងឃើញឡើងទៅបាត់អ៊ីចឹងទៅ ប្រហែលជាមួយសន្ទុះធំ គាត់មកវិញ គេថា "មិនអនុញ្ញាតឲ្យទៅទេ១ ព្រោះអ្នកឯងជាជន១៧មេសា។ ឯចំណែកភូមិហ្នឹង គេរំដោះបានមុន គេចាត់ថា ជន១៨មេសា"។ ហើយខ្ញុំអត់យល់១ ថា១៧មេសា ១៨មេសារបៀបម៉េចទេ។ ប៉ុន្តែដឹងថា តែលេខ១៧ ១៧ហើយ តែ១៨ ១៨ហើយ។ ដល់សារអីគេ ខ្ញុំអត់យល់ភាសាស៊ីជម្រៅរបស់គេហ្នឹង ក៏បានលា -- បានចាកចេញពីកន្លែងគាត់ហ្នឹងមកវិញ ឃើញនឹងគាត់ហ្នឹងជួយអាណិតអាសូរដែរ។ គាត់យករទេះក្របីហ្នឹង សណ្ដោងកន្ទុយរ៉ឺម៉ករបស់ខ្ញុំនោះ កន្ទុយរ៉ឺម៉កដែលខ្ញុំអូសអីវ៉ាន់ ដឹកអីវ៉ាន់ទៅ ចេញមកដល់ផ្លូវជាតិ១ ក៏បែកគ្នាត្រឹមហ្នឹង១។ ខ្ញុំក៏បានបន្តដំណើរ១ ថ្ងៃហ្នឹងពេលហ្នឹងបន្តដំណើរមកវិញហើយ។ បាទ បន្តដំណើរថយក្រោយវិញ។ ថយក្រោយហ្នឹងឃើញថាថយមកអ៊ីចឹងមក មកឆ្លងសាឡាងហ្នឹងដដែលហ្នឹង ឆ្ពោះទៅកាន់ អាឆ្លងហ្នឹងគឺមិនអាចធ្វើដំណើរបានលឿនទេ ក៏ប៉ុន្តែអានេះដោយសារខ្ញុំនិយាយកាត់១ទៅ ចោះ១ទៅ ឃើញថា ទៅដល់ ទៅតាមផ្លូវស្រុកខដុង្គ វាងរាជធានីភ្នំពេញ ព្រោះទៅដល់ហ្នឹងគេមិនអនុញ្ញាតឲ្យចូលទីក្រុងទេ។ គេបិទនៅកន្លែងផ្លូវព្រែកក្ដាមហ្នឹង ត្រើយខាងលិច។

[១៥:៣៩:២៦]

អ៊ីចឹង ក៏ខ្ញុំបែកទៅ វាងទៅផ្សារខដុង្គ បាទ ខ្ញុំទៅដល់ ខ្ញុំក៏ទៅដេកនៅហ្នឹង ១ថ្ងៃ ២ថ្ងៃ ដើម្បីសម្រាកយកជើង១ ក្រោយពីធ្វើដំណើរទៅ វា៣, ៤ថ្ងៃហ្នឹង វាឆ្ងាយណាស់ វាអស់ជើង។ បើនិយាយទៅ ថាវាអស់ជើង អស់មែនទែន អស់លែងចង់ដើរ បាទ។ ខ្ញុំនៅចាំបានប៉ុណ្ណឹង។

**សៈ** តើនៅពេលនោះ តាមផ្លូវដែលលោកថា ធ្វើដំណើរចេញពីកំពង់ចម្លងទៅតាមបាធាយរហូតទៅដល់ខាងព្រែកក្ដាម តើពេលហ្នឹងលោកមាន ក្រុមគ្រួសាររបស់លោកហ្នឹងមានជួបស្ថានការណ៍លំបាកអី ឬក៏បញ្ហាអីដែរឬទេនៅពេលនុំង? ឧទាហរណ៍ដូចជាការស្នាក់នៅ ការហូបចុក ឬក៏មានការ

ឈឺស្កាត់អីតាមផ្លូវដែរឬទេ ហើយបើមានៗការជួយ មានការយកចិត្តទុកដាក់ពីខាងអ្នកនៅក្នុងតំបន់ដែលគេរស់នៅទីនោះ ឬក៏ខាងអ្នកគ្រប់គ្រងអីដែរឬទេ?

[១៥:៤០:៣៧]

**ផ៖** ដែលខ្ញុំបាននៅត្រើយខាងកើតហ្នឹងណ៎ា គឺការហូបចុករបស់ខ្ញុំវេទនាមិនគួរអាចខ្ញុំទទួលយកបានទេ ព្រោះអត់តាំងពីឆ្នាំងដាំបាយដាំអីអ៊ីចឹង ពេលដាំបាយម្តងៗរត់រកខ្ចីគេ ដោយសារនឹកឃើញថា ឪពុកម្តាយខ្ញុំថា អ្ហ៎! ៣ថ្ងៃវាគ្រប់គ្រាន់ហើយកូន សម្រាប់មីមួយបាវហ្នឹងវាគ្រប់ហើយ ដើម្បីចូលទៅទីក្រុងភ្នំពេញវិញ អ៊ីចឹងមិនបានកាន់ឆ្នាំងចានអីមកជាមួយអីទេ។ ដល់ពេលហើយអ៊ីចឹងក៏ៗ សម្រេចចិត្តថា ខ្ចីគេប្រើបណ្តោះអាសន្នហូបមួយគ្រាៗសិនទៅ នឹកឃើញថាពេលវេលាហ្នឹងវាអត់យូរ វាមិនយូរទេ។ ដល់ពេលចេះតែនៅអ៊ីចឹងទៅ ដល់ខ្ញុំចាប់ផ្តើមឃើញថា "អ្ហ៎! ពេលហូបម្តងៗ ខ្ញុំថាម៉ែ ដូចកាលពីយើងនៅផ្ទះយើងអត់អ៊ីចឹងឯណា សាច់ម្ហូបអាហារអីយើងហូបគ្រប់គ្រាន់បរិបូរ ដល់ពេលយើងមកនៅអ៊ីចឹង ហើយហូបដូចជាគ្មានឃើញដែលសាច់អី ឥឡូវមើលឃើញបងជីដូនមួយក្តៅខ្លួនហើយ ទៅរកឯណា ទៅរកថ្នាំរកអីឯណា?"។ "អ្ហ៎! កូនអើយ កូនឯងមកកន្លែងកណ្តាលវាល កូនឯងទៅរកស្អីឃើញ"។ ក៏គ្មានយកចិត្តទុកដាក់ពីប្រជាជនមូលដ្ឋាននៅម្តុំហ្នឹងអត់ទេ ដូចអត់មានសោះ ហើយក៏សុខចិត្តថា យកអាក្រមាពោះគោជ្រលក់ទឹក ពូតស្អំបណ្តោះៗសិន។ បាទ ខ្ញុំនៅចាំបានប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ អ៊ីចឹង ខ្ញុំសូមសួរលោកបន្តទៀតថា តើនៅពេលដែលធ្វើដំណើរពីមួយកន្លែងទៅមួយកន្លែងហ្នឹង តើលោកមានដែលប្រទះឃើញមានប៉ុស្តិ៍យាម ឬក៏ប៉ុស្តិ៍ឆែកឆេរចំពោះប្រជាជនដែរឬទេ កាលពីអំឡុងពេលនោះ?

**ផ៖** បាទ អត់ទេ។ ខ្ញុំអត់ដែលបានឃើញប៉ុស្តិ៍យាមទេ គ្រាន់តែថា គេចល័តគ្នា ឃើញគេចល័តគ្នា ដូចជា ដើរ ឬក៏ជិះកង់អ៊ីចឹង ប៉ុន្តែមិនមែនខាងក្រុមគ្រួសារខ្ញុំទេ អ្នកជិះកង់នោះគឺ ខាងខ្ញុំដូចជាចាំមិនច្បាស់ស្រពេចស្រពិលថា មិនដឹងជាកងឈ្លប ហើយក៏មិនដឹងជាទាហាន។ ពេលហ្នឹងគេជិះកង់ៗ ធ្វើដំណើរឆ្លាស់គ្នាទៅមកៗអ៊ីចឹងណ៎ា។ បាទ ខ្ញុំចាំបានតែប៉ុណ្ណឹង។

**ស៖** ចុះអំឡុងពេលដែលលោកធ្វើដំណើរនោះ លោកមានបានប្រទះឃើញទាហាន លន់ នល់ដែរឬទេ?

[១៥:៤៣:៤០]

**ឆ៖** ពេលដែលខ្ញុំធ្វើដំណើរហ្នឹង ដូចជាមិនឃើញប្រទះឃើញមានជាទាហាន លន់ នល់ ទេ តែបើសិនជាឃើញទាហាន លន់ នល់ ស្លាប់នៅនឹងផ្លូវខ្ញុំឃើញបាទ ខ្ញុំឃើញ ក៏ប៉ុន្តែស្លាប់ហ្នឹង ខ្ញុំគិតថាប្រហែលជាបាញ់គ្នាហើយ ដោយសារបាញ់គ្នាហើយបានស្លាប់ ដែលខ្ញុំគិតឃើញអ៊ីចឹង។ តែរាងទ្រង់ឃើញខ្មោចហ្នឹងហើមហើយៗ ហើមឡើងរុយរោមអ៊ូ។ បាទខ្ញុំឃើញប៉ុណ្ណឹង។

**ស៖** នៅពេលដែលលោកបានឃើញថា ទាហាន លន់ នល់ ត្រូវបានគេសម្លាប់មានហើម អ៊ំ! មានការស្លាប់។ តើលោកឃើញនៅកន្លែងណាដែរ លោកចាំបានទេ? បើគិតពីរវាងការធ្វើដំណើរពីទីក្រុងភ្នំពេញចេញរហូតតាមផ្លូវរហូតដល់ពេលព្រែកក្ដាមនោះ?

**ឆ៖** ខ្ញុំឃើញប្រហែលជា ដូចជា តាមស្មានមើលរបស់ខ្ញុំទៅ ហួសព្រែកក្ដាមទៅបន្តិចទៅ ខ្ញុំឃើញមានទាហានបីនាក់ស្លាប់នៅហ្នឹង តែហើមហើយ ប៉ុន្តែនៅចិញ្ចើមផ្លូវណ៎ះ មិនមែននៅចំកណ្ដាលផ្លូវទេ នៅចិញ្ចើមផ្លូវ ចិញ្ចើមយើងអ៊ីចឹង វាស្លាប់នៅអ៊ីចឹង។ ឃើញឯកសណ្ឋានប៉ារ៉ា។

**ស៖** ក្រៅពីឃើញទាហានស្លាប់ តើលោកមានប្រទះឃើញសាកសពជនស៊ីវិលដែរឬទេ ឬក៏មានឃើញជនស៊ីវិលណាម្នាក់ដែលត្រូវរបួសអីនៅតាមផ្លូវអីដែរឬទេ?

**ឆ៖** ខ្ញុំឃើញម្នាក់នៅក្រោមដើម ខ្ញុំ ដើមហ្នឹងខ្ញុំអត់ចាំឈ្មោះទេ ឃើញម្នាក់ឃើញដាក់ចោលនៅហ្នឹង ក៏ប៉ុន្តែវាឆ្ងាយពីភ្នែកខ្ញុំ។ ប៉ុន្តែមិនដឹងជាស្លាប់ ឬរស់ទេ តែក្នុងហ្នឹងខ្ញុំឃើញដូចជាបិទបង់អានៅខាងមុខនេះមួយ ហើយបោះដៃផុតនេះមួយ។ បាទ បិទបង់ បាទ ខ្ញុំឃើញ ក៏ប៉ុន្តែវាមិនជិតខ្ញុំ វានៅឆ្ងាយពីខ្ញុំ នៅក្រោមដើមឈើ។ បាទ ខ្ញុំចាំបានប៉ុណ្ណឹង។

**ស៖** ខ្ញុំសូមសួរលោកបកក្រោយបន្តិច ទាក់ទងទៅនឹងលោកថា លោកធ្លាប់រស់នៅម្ដុំច្រាំង -- កំពង់ចម្លង តើស្ថានភាពនៅកំពង់ចម្លងនាពេលនោះហ្នឹង លោកមានដែលប្រទះឃើញថា មានសាកសពដែលមានស្លាប់នៅលើ -- នៅក្នុងទន្លេអីដែរឬទេ មានអណ្ដែតនៅក្នុងទន្លេអីដែរឬទេ?

[១៥:៤៦:២៥]

**ឆ៖** បាទ ខ្ញុំអត់បានដែលឃើញផង។ ព្រោះខ្ញុំមិនសូវចុះមកមាត់ទន្លេហ្នឹងញឹកញាប់ណ៎ះ បាទធ្វើឲ្យខ្ញុំអត់បានឃើញអីទាំងអស់។

**ស៖** អ៊ីចឹងខ្ញុំសូមសួរមួយទៀត ទាក់ទងទៅនឹងរឿង លោកតែងតែនិយាយថា ក្រុមគ្រួសារលោកមានក្ដីសង្ឃឹមក្នុងការចូលមកទីក្រុងភ្នំពេញវិញ តើក្រុមគ្រួសារលោកមានដែលឮ ឬក៏ការប្រកាសឲ្យប្រជាជនចូលទីក្រុងភ្នំពេញ ក្នុងរយៈពេល៣ថ្ងៃវិញដែរឬទេ?

**ឆ៖** ទេ ដូចអត់ទេ។ មានតែប្រកាសឱ្យចេញ មានតែប្រកាសឱ្យទៅស្រុកកំណើត តែដល់ប្រកាសឱ្យចូលទីក្រុងភ្នំពេញវិញ អត់ឮៗតាមគេស្រែកតាមមីក្រូមេអី ពេលដែលអង្គាល់ប្រកាសឱ្យចេញពីទីក្រុងភ្នំពេញមានមីក្រូស្រែក ដល់ពេលអាប្រកាសឱ្យចូលហ្នឹងដូចគ្មានឮសំឡេងអីទេ ស្មាត់ឈឹង មានតែដេញឱ្យចេញទៅតាមស្រុកឆ្ងាយៗ ទៅតាមជនបទអីអ៊ីចឹងមាន បើថាឱ្យចូលទីក្រុងភ្នំពេញវិញដូចអត់មាន។

**ស៖** សូមអរគុណ។ ខ្ញុំសូមធ្វើការបន្តសំណួរទៀត មុននឹងបន្តិចលោកបានលើកឡើងថា ក្រុមគ្រួសាររបស់លោកហ្នឹង គេមិនឱ្យស្នាក់នៅខាងស្រុកបាធាយនោះទេ អ៊ីចឹងគេរុញឱ្យទៅស្រុកកំណើតនៅឯកំពត។ តើលោកចំណាយរយៈពេលប៉ុន្មានថ្ងៃដែរ ទើបធ្វើដំណើរទៅដល់ស្រុកកំណើតនៅឯខេត្តកំពតនោះ?

[១៥:៤៧:៥៧]

**ឆ៖** អាហ្នឹងខ្ញុំអត់បានគិតគូរថា ធ្វើដំណើរប៉ុន្មានថ្ងៃ ប៉ុន្មានខែអីទេ ក៏ប៉ុន្តែគិតដឹងថា ពីចេះតែដើរៗតាមៗទៅ យប់ត្រឹមម៉ាន ដេកត្រឹមហ្នឹង បាទ។ ភ្លឺឡើងទៅទៀត ពេលណាដែលធ្វើដំណើរដូចជាគេហៅថា អស់ជើង ភាសាគេហៅថាអស់ជើងទៅមុខលែងរួច ទៅសម្រាកកន្លែងហ្នឹង១ថ្ងៃ ឬក៏២ថ្ងៃ អ៊ីចឹងទៅបានមានកម្លាំងស្រួលបន្តិចបន្តដំណើរទៅទៀត។ ក៏ប៉ុន្តែខ្ញុំមិនបានចាំ មិនបានរាប់ថា ធ្វើដំណើរហ្នឹងប៉ុន្មានថ្ងៃទេ ប៉ុន្មានខែទេបានដល់។ បើការពិតទៅខ្ញុំគិតឃើញថា វាយូរ បើសម្រាប់ខ្ញុំ ខ្ញុំថាយូរអីយូរ។ ខ្ញុំចេះតែរអ៊ូរទាំដាក់ឪពុកដាក់ម្ដាយខ្ញុំ ចុះយូរអីក៏យូរម្ល៉េះ ក្រដល់អាស្រុកកំណើតហ្នឹងម្ល៉េះ។ ខ្ញុំចេះតែថាអ៊ីចឹង គាត់ក៏ -- ម្ដាយឪពុកខ្ញុំក៏ "អើយ ទ្រាំៗទៅកូនអើយៗ! ចាំទៅដល់ស្រុកកំណើតយើងហ្នឹងវាស្រួលវិញហើយ"។ គាត់បានចាំប្រាប់ខ្ញុំ អង្វរទទូចខ្ញុំអ៊ីចឹង ឱ្យខ្ញុំនិយាយអ៊ីចឹង កុំឱ្យដូចថា ឱ្យខ្ញុំមានទឹកចិត្តដើរ ព្រោះធ្វើដំណើរដោយថ្មើរជើងគ្មានស្អីជិះ គ្មានស្អីទេ។ ហើយខាងអង្គការ ឬក៏ខាងខ្មែររំដោះអីហ្នឹង គេគ្មានអីមកដឹកយើងយកទៅដាក់អីឱ្យចំគោលដៅដែរ អត់ទេ។ បាទ ខ្ញុំនៅចាំបានប៉ុណ្ណឹង។

[១៥:៤៩:២៣]

**ស៖** ពេលដែលក្រុមគ្រួសារលោកហ្នឹង ធ្វើដំណើរទៅដល់ស្រុកកំណើត តើពេលនុំងមានការទទួលរាក់ទាក់ ឬក៏ទទួលដូចថា រៀបចំឱ្យក្រុមគ្រួសាររបស់លោកហ្នឹងរស់នៅទីនោះដែរឬទេ? ដូចការរំពឹងទុករបស់ក្រុមស្ទួររបស់លោកដែរឬទេ?

**ឆ៖** ស្ដាប់សំណួរអត់ច្បាស់អំមិញ។

**សះ** ខ្ញុំសូមរៀបចំសំណួរឡើងវិញ។ ខ្ញុំចង់សួរថា ម្ដាយរបស់លោកប្រាប់លោកថា ឲ្យលោកទ្រាំៗទៅ នៅពេលដែលទៅដល់ស្រុកកំណើតយើងនឹងបានស្រួលឡើងវិញហើយ។ អ៊ីចឹងពេលដែលក្រុមគ្រួសាររបស់លោកហ្នឹងធ្វើដំណើរទៅដល់ស្រុកកំណើត តើពេលទៅដល់ទីនោះហ្នឹងមានអ្នកដែលគេចាំទទួលយើង ដូចការរំពឹងទុករបស់ម្ដាយរបស់លោកដែរឬទេ ដូចថាការរំពឹងទុកថា ទៅដល់ទីនោះនឹងបានសុខសប្បាយ ហើយនិងបានស្រួលឡើងវិញ? ហើយមានអ្នកគេចាំទទួលយើងអត់? ដូចជាសាច់ញាតិ បងប្អូនអី? ហើយស្ថានភាពនៅពេលនោះយ៉ាងម៉េចដែរ? សូមលោកជួយរៀបរាប់ឲ្យបានលម្អិតអំពីដំណើរជីវិតរបស់លោកនៅពេលហ្នឹង?

**ឆះ** បាទ ពេលដែលខ្ញុំធ្វើដំណើរទៅដល់ស្រុក គេហៅថាស្រុកកំណើតនោះ។ ក៏ប៉ុន្តែទៅហ្នឹងវាអត់ចាំគោលដៅទេ វាអត់ចំគោលដៅយ៉ាងម៉េច? ព្រោះស្រុកកំណើតខ្ញុំនៅស្រុកអង្គរជ័យ ពេលហ្នឹងគេឲ្យខ្ញុំទៅនៅស្រុក គេហៅថា ស្រុកប៉ាឡៃឡៃ ៗនោះទេ។ អ៊ីចឹងឃើញវាគន្លាតគ្នាហ្នឹង ខ្ញុំនៅតូចៗដែរមិនដឹងជាប្រវែងប៉ុន្មានគីឡូម៉ែត្រ ខ្ញុំអត់បានដឹង។ ពេលហ្នឹង គេឲ្យខ្ញុំទៅនៅស្រុកប៉ាឡៃឡៃ ឲ្យខ្ញុំទៅនៅស្រុកប៉ាឡៃឡៃ ហ្នឹង គ្មានជនមូលដ្ឋាន ដែលចំណាំគេហៅថា "ជន១៨" នោះ។ គ្មានរាក់ទាក់អីទេ ខុសតែពីយើងមានមាស ឬក៏មានរបស់បន្តិចបន្តួចយកទៅដូរជារបស់របរហូបហ្នឹង គឺអត់បានទេ គឺគ្មានអ្នកណារាក់ទាក់ឲ្យយើងទេ។

[១៥:៥១:៣៥]

ហើយពេលហ្នឹង ក្រុមគ្រួសារខ្ញុំ ក៏ដូចជាក្រុមគ្រួសារអ្នកដទៃដែរហ្នឹងដែរហ្នឹង គេបានចាត់តាំងឲ្យនៅស្រុកប៉ាឡៃឡៃហ្នឹង។ បាទ ដោយឡែកហ្នឹង គេបែងចែកទៀត គេបែងចែកថា ជន១៧មេសាហ្នឹងនៅម្ដុំ គេមិនឲ្យរស់នៅច្រឡូកច្រឡំជាមួយជន១៨មេសា ទេ។ ហើយនិងពេលនោះ ប្រធានភូមិៗហ្នឹងឈ្មោះ ខ្ញុំនៅចាំដល់រហូតដល់សព្វថ្ងៃហ្នឹង ឈ្មោះ នៅ ប៉ុន្តែមិនដឹងជាស្អី នៅ ទេ។ គាត់ហ្នឹងខាងកាន់១៧មេសា ជន១៧មេសា។ អ៊ីចឹងទេ គេបង្ខំចិត្តថា ឲ្យខ្ញុំ ឲ្យជន១៧មេសាហ្នឹងទាំងអស់ ទៅធ្វើស្រែធ្វើស្រែហ្នឹងគ្មានទេ គ្មានគោ គ្មានក្របីអីក្ដួរ គ្មានដីដែលគាស់សារួចអត់ទេ។ គឺឲ្យខ្ញុំទៅរុករានដីថ្មីតែម្ដងដីហ្នឹង វាមានដីមិនមែនជាដើមឈើធំៗទេ ដើមឈើហ្នឹងតូចៗទេ ដូចជាដើមត្នោ ដើមព្រេចដែលខ្ញុំនៅចាំបានហ្នឹង។ ហើយក្នុងមួយនាក់ហ្នឹងដាក់កាប់ដីឲ្យទៅដល់១០ម៉ែត្របួនជ្រុង ៗទើបបានអង្ករមួយកំប៉ុងឬក៏ពីរកំប៉ុង តាមសមាជិកតិច សមាជិកច្រើន។ ពេលនុ៎ង ខាងក្រុមគ្រួសារខ្ញុំកាប់អត់បានទេ កាប់មិនបានទេ ព្រោះម្នាក់ដល់១០ម៉ែត្របួនជ្រុង ហើយឪពុកខ្ញុំមួយ ម្ដាយខ្ញុំមួយ វាចូល២០ម៉ែត្របួនជ្រុង។

អ៊ីចឹងមិនអាចធ្វើបាន។ ដល់មិនអាចធ្វើបានទៅ លោកប្រធានភូមិ នៅ, ឈ្មោះ នៅ ហ្នឹងគាត់គឺថា រកអាគំនិតផ្សេងៗ។ ដល់តែគាត់រកគំនិតផ្សេងអ៊ីចឹង គាត់ថាអ៊ីចឹងឲ្យដាក់ជាគ្រួសារ កាប់គាស់ឲ្យជាគ្រួសារ។ ពេលហ្នឹង ខ្ញុំហ្នឹងគេបង្កើនឲ្យឡើងអាមួយគ្រួសារខ្ញុំហ្នឹង ឲ្យឡើង១២ម៉ែត្រៗ ប្អូនជ្រុង ទើបបានអង្ករពីរកំប៉ុងយកមកសម្រាប់ទទួលទាន។

[១៥:៥៣:៤៥]

ពេលអ៊ីចឹ ខ្ញុំឃើញឪពុក ឃើញម្ដាយខ្ញុំ ខ្លោចផ្សាណាស់ ដែលគាត់ខំកាប់ ខំគាស់ ញើសហូរជោកពេញទាំងខ្លួន ក៏ដូចជាអ្នកដទៃដែរ គ្មានពេលសម្រាកទេ ទម្រាំបានអង្ករពីរកំប៉ុងយកមកទទួលទាន ហើយសមាជិកខ្ញុំមានបីប្អូនប្រាំនាក់ហ្នឹង។ ទទួលទាន គឺមិនគ្រប់ទេ ថែមៗ បន្លែផ្លែឈើ។ ពេលហ្នឹងខ្ញុំដូចជាថា កូនព្រលិតចុះ ខ្ញុំថាអាហ្នឹងដូចព្រលិតហើយ ប៉ុន្តែស្លឹកវាខុសគ្នាពណ៌ខៀវៗ។ ដល់ពេលក្រោយមកទៀត បានខ្ញុំដឹងចាំឈ្មោះ សួរគេ សួរឯងទៅ គេថា អាហ្នឹង ស្គន់ៗ ដើមសរសៃរអំបោះតូចៗ តែប្រភេទដូចព្រលិតដែរ យកមកច្រូតដាក់បបរហូបល្វឹងតិចៗ។ យកមកធ្វើការទទួលទាន។ បាទ ខ្ញុំនៅចាំបានប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំចង់បន្តសំណួរទៀតថា រវាង -- លោកបានលើកអំពីមូលដ្ឋានចាស់និងមូលដ្ឋានថ្មី។ អ៊ីចឹងរវាងពួកមូលដ្ឋានចាស់និងមូលដ្ឋានថ្មី តើលោកបានលើករៀបរាប់អំពីពួកមូលដ្ឋានថ្មីហើយ។ ចុះការហូបចុករបស់ពួកមូលដ្ឋានចាស់យ៉ាងម៉េចដែរពេលនុ៎ង? មានភាពខុសគ្នាជាមួយក្រុមគ្រួសាររបស់លោកដែលជាមូលដ្ឋានថ្មីហ្នឹងកម្រិតណាដែរពេលនោះ?

**ឆ៖** មូលដ្ឋានចាស់ហ្នឹង គេអ៊ីចេះ! គេធ្វើការហ្នឹងមិនច្រឡូកច្រឡំជាមួយអាខាង១៧មេសា ទេ គេធ្វើជាក្រុមគ្នាគេ ធ្វើជាក្រុមនៅគ្នាគេ តែរបបអង្ករគេនុ៎ង គេអាចទទួលទានហូបគ្រប់គ្រាន់បាទ។ អ្នកណាចេញទៅធ្វើការ គឺក្នុងម្នាក់បានមួយកំប៉ុង។ គេគិតឲ្យខាង ដូចថា គេហៅថាជន១៨មេសានោះ ដែលមានឯកសណ្ឋានជាពណ៌ខ្មៅនោះ។ បាទ អាហ្នឹងខ្ញុំឃើញអ៊ីចឹង។

[១៥:៥៥:៥៧]

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំសូមបន្តទៀត។ ខ្ញុំសូមសួរលោកថា តើនៅពេលនោះក្រុមគ្រួសាររបស់លោកដែលជាពួកមូលដ្ឋានថ្មីហ្នឹង គេមានធ្វើស្ថិតិសម្រាប់ក្រុមគ្រួសារដែលមកថ្មី ដូចជាក្រុមគ្រួសាររបស់លោកដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានដឹងថា ពេលហ្នឹងដូចអត់មានថ្នាក់ពីណាពីណីមកធ្វើទេ មានតែគេហៅប្រធានភូមិឈ្មោះ នៅ ហ្នឹង បានចុះមកកត់សមាជិកខ្ញុំមានប៉ុន្មាននាក់ សមាជិកអ្នកដទៃមានប៉ុន្មាននាក់អ៊ីចឹង។ គេចុះមកកត់តែប៉ុណ្ណឹងឯង។ គេអត់មានធ្វើស្អីដូចយើងសព្វថ្ងៃហ្នឹងទេបាទ។ ខ្ញុំនៅចាំបានប៉ុណ្ណឹង។

**ស៖** តើលោកមានចាំបានឬទេ មូលហេតុអ្វីបានជាគេធ្វើស្ថិតិចំពោះក្រុមគ្រួសាររបស់លោកដូច្នេះ?

**ស៖** ពីព្រោះអីហ្នឹង ខ្ញុំដូចថានៅចាំបានថា មិនជាគេធ្វើហ្នឹង គេធ្វើរបៀបម៉េចអី របៀបម៉េចទេ? ក៏ប៉ុន្តែប្រហែលជា បើតាមខ្ញុំគិតមើលបន្តិចម្តងៗ ហើយខ្ញុំលួចសួរម្តាយឪពុកខ្ញុំហ្នឹង គឺថាប្រហែលជាគេកត់យកចំនួន ឬក៏ស្រួលងាយអ្វីផ្សេងដែលគេតម្រូវការមិនដឹង អីមិនដឹង ឃើញឪពុកខ្ញុំលួចប្រាប់ខ្ញុំអ៊ីចឹង។

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំសូមបន្តទៀត។ អំឡុងពេលដែលលោករស់នៅទីនោះ តើមានអ្វីកើតឡើងចំពោះក្រុមគ្រួសារលោកដែរឬទេ នៅពេលនោះ?

[១៥:៥៨:០៦]

**ឆ៖** បាទ មាន មានកើតឡើងចំពោះក្រុមគ្រួសារខ្ញុំ។ ពេលហ្នឹង ខាងអង្គការ តែខ្ញុំអត់ស្គាល់អង្គការមិនដឹងមួយណា ព្រោះពេលមកដល់ គេដាក់ប្រជុំអ៊ីចឹង គេថាខាងអង្គការយើងហ្នឹង បានរៀបចំហើយ។ រៀបចំបងប្អូនហ្នឹងលែងឲ្យនៅ គេហៅៗ កម្មសិទ្ធិៗក្រាស់ឃ្មឹក។ ហើយខ្ញុំពេលហ្នឹងដូចអត់យល់ទេអាភាសាកម្មសិទ្ធិក្រាស់ឃ្មឹកហ្នឹង មិនដឹងគេចង់ផ្តោងសំដៅទៅនិយាយពីរឿងអីទេ។ គេអ៊ីចឹងគេប្រមូលឲ្យយើងហ្នឹងប្រមូលចាន ប្រមូលឆ្នាំង ចូលៗហូបរួម ហូបបាយរួម បាទ ហូបបាយរួម។ ពេលហ្នឹងចូលហូបបាយរួមហ្នឹង ក៏ប៉ុន្តែនៅៗមានបែងចែកទៀត។ ជន១៧មេសា ហ្នឹងមានរោងបាយមួយផ្សេង។ ជន១៨មេសា ហ្នឹងមានរោងបាយផ្សេង តែរោងដាំស្លតែមួយទេ។ តែក្នុងនុំងទៅទៀត គេមិនដឹងជាធ្វើអីទៀត ព្រោះគេអត់ឲ្យអនុញ្ញាតឲ្យយើងចូលទេ។ ឃើញថាក្រោយពេលហូបបាយ បានហូបបាយរួមហ្នឹង ពេលហ្នឹងគេបែងចែកជាក្រុមជាអីហ្នឹងដូចខាងខ្ញុំក្រុមគ្រួសារខ្ញុំហ្នឹង គេបែងចែកជាក្រុមកងចល័តទៅ។

[១៥:៥៩:២៥]

ក្រោយមកទៀតបានកងឈ្លបហ្នឹង គេចាប់ឪពុកខ្ញុំៗហ្នឹងចងស្លាបសេកៗបណ្តើរ។ ពេលហ្នឹងខ្ញុំឃើញជាក់ស្តែង និងច្បាស់នឹងភ្នែកដោយសារខ្ញុំឈរមើលគោ ដៃម្ខាងកាន់ពូថៅ កូនពូថៅមួយ

សម្រាប់ដំស្ទឹងគោ ដៃម្ខាងទៀតកាន់ខ្សែគោ បាទឈរមើលៗអ៊ីចឹង។ តែមានចិត្តពុះកញ្ជ្រោលណាស់ តែមិនដឹងទៅជួយរបៀបម៉េច។ ខ្ញុំឈានជើងមួយជំហានដើរបានមួយជំហាន។ ពេលនុ៎ង ឪពុកខ្ញុំនិយាយថា "ខ្ញុំថែរក្សាខ្លួនកូន។ ឪពុកទៅហ្នឹង មិនមែន -- ពុកទៅបែកពីកូនហ្នឹង គឺពុកទៅថ្នាក់លើបន្តទៀត"។ ពេលនោះ ខ្ញុំដូចជាលែងនិយាយអីចេញហើយ ដឹងតែបង្ហូរទឹកភ្នែក។ ពេលហ្នឹង ដែលឃើញទាហានខ្មែរក្រហមហ្នឹង បានវ៉ៃឪពុកខ្ញុំហ្នឹង បែកក្បាលហូរឈាម ហើយបាននិយាយថា "ពីមុនអ្នែង មានបង់បិទ។ ឥឡូវអត់មានទេ មានតែដីខ្សាច់"។ គាត់លើកដីខ្សាច់ហ្នឹង ដាក់បិទ។ ពេលហ្នឹង ខ្ញុំឈរភាំងហូរទឹកភ្នែកដោយមិនដឹងខ្លួន។ បាទ ខ្ញុំនៅចាំបានប៉ុណ្ណឹង។

[១៦:០១:០៤]

**សៈ** អ៊ីចឹងអង្កាល់ហ្នឹង លោកមានចាំបានឬទេ មូលហេតុអ្វីបានជាគេចាប់ឪពុករបស់លោក?

**ឆៈ** ខ្ញុំចាំបានអ៊ីចេះ ថ្ងៃមួយហ្នឹង ឃើញគេប្រជុំប្រាប់ បាទ ក្រោយពីហូបបាយហើយថ្ងៃល្ងាចនោះ។ គេប្រកាសថា "ស្អែកចុះឆែកឆេរ ចុះឆែកផ្ទះសម្បែង"។ ពេលនោះ ដែលខ្ញុំមិនបានចាំអារម្មណ៍ដែរ។ ខ្ញុំក៏ទៅមើលគោនៅកៀនៗផ្ទះហ្នឹង ដល់ពេលហើយអ៊ីចឹង ពេលនោះ គេឆែក គេដើរឆែកខាងជន១៧មេសាមុន។ ប៉ុន្តែមិនដឹងជាគេសម្គាល់របៀបម៉េចទេ បានជាគេឆែកខាងហ្នឹងមុខ។ ពេលហ្នឹងឆែកឃើញអារូបថតរបស់ប៉ាខ្ញុំហ្នឹង គាត់តឺនុយ ដូចថាតឺនុយជាឯកសណ្ឋានជើងទឹក ថតនៅលើកប៉ាល់ៗហ្នឹង ពេលហ្នឹងគេបញ្ជូនគាត់ទៅនៅ គេហៅភូមិឡាំដាំ ខេត្តកោះកុង។ គាត់ថតនៅហ្នឹងៗ។ ដល់ពេលហើយអ៊ីចឹង គាត់ ទន្ទឹមនឹង មុននឹងបន្តិច មានប្រធានភូមិហ្នឹង គេមកសួរខ្ញុំថា "ឪពុកឯងធ្វើអ្វីៗអ៊ីចឹង? ហើយប្រាប់អំឲ្យច្បាស់មក ចាំអំឲ្យបាយ ឲ្យសាច់ជ្រូក ឲ្យអីយកទៅហូប"។ ពេលហ្នឹង ខ្ញុំឃើញគាត់ហ្នឹងវាល់អង្ករ មិនដឹងជាប៉ុន្មានកំប៉ុងទេ ដាក់ក្រមា ហើយគាត់ដាក់សាច់ជ្រូកហ្នឹង ឲ្យៗខ្ញុំឆ្លើយ។ អង្កាល់ហ្នឹង ខ្ញុំថា អត់ទេ ប៉ាខ្ញុំធាក់ស៊ីក្លូៗ។ ខ្ញុំនៅចាំតែស៊ីក្លូតែមួយមុខហ្នឹង។ ដល់គាត់ថាម៉េច ក៏ខ្ញុំថានៅស៊ីក្លូដែរ។

[១៦:០៣:០៤]

ដល់ថ្ងៃមួយទៅ គាត់ថា គាត់ក៏លែងសួរលែងអីទៅ គាត់ក៏ហុចអង្ករហ្នឹងឲ្យទៅ ខ្ញុំក៏រត់យកទៅផ្ទះយកទៅអីទៅ ចែកបងប្អូនដាំហូបអ៊ីចឹង។ ថ្ងៃមួយ គេរុះរើអាផ្ទះសម្បែកហ្នឹង ក៏ឃើញរូបថត ដល់ពេលហ្នឹងគេឃើញរូបថតៗ គេចាប់ទុកខ្ញុំ។ គេទុក ដល់ពេលហើយហ្នឹង គេក៏ចេះតែដៀមដាមៗ។ ភាសាដៀមដាមហ្នឹង ប៉ុន្តែខ្ញុំវាមិនបានចាំដែរ ដូចថា "មើលកូនអាក្បត់ អានេះប៊ិនកុហកណាស់ មុខឯង

នេះ បានសមតែពីរបីកំផ្លៀង ប៉ុណ្ណឹងសោះ ចេះកុហក ចេះភូតភរ។ អ្អែង ដឹងសង្គមនេះទេ សង្គមនេះគឺសង្គមស្អាតស្អំណាស់។ គេគ្មានដូចនៅសង្គមអ្អែង នាយទុនស្អីណា” និយាយច្រើនណាស់ ហួរហែណាស់ ដែលខ្ញុំមិនអាចរៀបរាប់ពាក្យពិបាកៗហ្នឹង ច្រើនបានច្រើន។ ពេលយប់ឡើងហ្នឹង ក៏ថាខ្ញុំជាកូនក្បត់ កូនអីហ្នឹង គេដាក់ឲ្យខ្ញុំនៅខ្នោះជើង។ យប់ឡើងគេដាក់ខ្នោះជើងខ្ញុំ ហើយគេចេញផាក់ចូលផាក់។ ប្រហែលជាខ្ទង់១អាទិត្យដែលបានទើបបានគេដោះលែងខ្ញុំនោះ។ ឲ្យខ្ញុំដេកយប់ទៅ មានសេរីភាពមិនជាប់ខ្នោះជើងវិញ។ បាទ ខ្ញុំធ្វើពិស្តារបានតែប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់។ ឥឡូវដល់ពេលនេះហើយ។

បាទ កិច្ចដំណើរការសវនាការថ្ងៃនេះ ដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ទី០៦ ខែធ្នូ ឆ្នាំ២០១២ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។

សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី គឹម វ៉ាន់ឌី និងសាក្សីដែលមានរហស្សនាម TCW-247។ សូមភាគី និងសាធារណជនជ្រាប។

លោក គឹម វ៉ាន់ឌី ការស្ដាប់សក្ខីកម្មរបស់លោក នៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្ដាប់សក្ខីកម្មរបស់លោក នៅថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។

មន្ត្រីរដ្ឋបាលតុលាការសម្រាបសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះវិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួន។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញចុះ ហើយនិងបង្គាប់ឲ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ ដោយឡែក លោក អៀង សារី ឲ្យនាំគាត់មកត្រឹមបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការនេះ ដែលរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍ សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៦ នាទី)*